ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

# សៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមគោ



ខែ សីហា ឆ្នាំ ២០១៩

សៀវភៅនេះរៀបរៀង និងបោះពុម្ពដោយនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្មនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
រក្សាសិទ្ធិដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរាល់ការផលិតឡើងវិញនៃផ្នែកខ្លះ ឬទាំងស្រុងសៀវភៅនេះត្រូវបានការអនុញ្ញាតពីអ្នកបោះពុម្ពជាមុនជាលាយលក្ខណ៍អក្សរ។

**អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**
ខែសីហា ឆ្នាំ២០១៩
អាស័យដ្ឋាន: ផ្លូវលេខ៣៧១ ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ។
លេខទូរស័ព្ទ: ០២៣ ៨៨៤ ៣៤៥/០១២ ៩៨២ ៩២៧

# អារម្ភកថា

សៀវភៅ " ណែនាំស្តីពីបច្ចេកទេសចិញ្ចឹមគោ " ត្រូវបានចងក្រងឡើងដោយផ្អែកលើបទពិសោធន៍ជាក់ស្តែង សៀវភៅដែលមានស្រាប់ និងឯកសារបច្ចេកទេសពីបណ្តាប្រទេសផ្សេងៗស្តីពីការចិញ្ចឹមគោ ជំងឺឆ្លង និងបទពិសោធន៍អនុវត្តជាក់ស្តែងរបស់អ្នកចិញ្ចឹម។ បន្ថែមលើខ្លឹមសារបច្ចេកទេស ក្រុមការងារបានរៀបចំបញ្ចូលនូវរូបភាពអនុវត្តជាក់ស្តែង និងប្រើពាក្យបច្ចេកទេសសាមញ្ញៗដែលងាយស្រួលយល់ និងអាចយកទៅអនុវត្តបាន។

ឯកសារនេះមានគោលបំណង ជួយជំរុញផលិតកម្មគោដែលស្របទៅនឹងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បសុសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ២០១៦-២០២៥ ក្នុងការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ដែលចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ ការលើកកម្ពស់សន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងអនុផលផ្សេងៗទៀត សម្រាប់តម្រូវការម្ហូបអាហារ ដែលកំពុងមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសការលើកកម្ពស់អាហារូបត្ថម្ភ និងជីវភាពកសិករខ្នាតតូច និងសហគមន៍ជនបទ។

ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះស្នាដៃរៀបចំនិពន្ធសៀវភៅនេះឡើងដោយលោក **តា ថា** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះអ្នកពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមផ្តល់គំនិតផ្តួចផ្តើម និងកែសម្រួលដល់ការរៀបចំតាក់តែងសៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមគោ ដែលរួមមាន៖ លោក **គីម សាឿន** អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ, លោក **ម៉ុក គីមស្រួយ** ប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម, លោកអនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម, លោក លោកស្រីប្រធាន អនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងមន្ត្រីជំនាញមួយចំនួនដែលបានអញ្ជើញចូលរួមកែសម្រួលដូចជា ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញមកពីនាយកដ្ឋានផលិតកម្មសត្វ, នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ត្រីជំនាញថ្នាក់ខេត្តមួយចំនួន ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមកែលម្អសៀវភៅ ណែនាំស្តីពីបច្ចេកទេសចិញ្ចឹមគោនេះ ដើម្បីបម្រើផលប្រយោជន៍នៃការអភិវឌ្ឍអនុវិស័យផលិតកម្មសត្វនៅកម្ពុជា។

ខ្ញុំសង្ឃឹមជឿជាក់ថា សៀវភៅនេះនឹងក្លាយជាមូលដ្ឋានគ្រឹះ សម្រាប់អ្នកចិញ្ចឹមសត្វ សិស្ស និស្សិតក្នុងការបង្កើនចំណេះដឹង និងជំរុញលើកកម្ពស់ការចិញ្ចឹមសត្វ ជាពិសេស ពង្រឹងការគ្រប់គ្រងខ្សែច្រវាក់ផលិតកម្មគោ ឱ្យមានលក្ខណៈប្រកួតប្រជែង និងប្រែក្លាយជាមុខរបរសម្រាប់សេដ្ឋកិច្ចគ្រួសារ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**

**តាន់ ផាន់ណារ៉ា**

# មាតិកា


**ជំពូកទី១. បច្ចេកទេសចិញ្ចឹមគោ** ............ ១
១. សេចក្តីផ្តើម ............ ១
២. ទីជម្រក ឬក្រោលគោ ............ ២
ក/ ទ្រុង/ស្នូកចំណី និងស្នូកទឹក ............ ៣
ខ/ ការបន្ថែមរបបចំណី និងទឹក ............ ៤
**ជំពូកទី២. ពូជ និងការបង្កាត់ពូជ** ............ ៥
១. កត្តាពូជ ............ ៥
១.១. ពូជក្នុងស្រុក ............ ៥
១.២. ពូជនាំចូល ............ ៦
២. ការបង្កាត់ពូជ ............ ៦
២.១. ការបង្កាត់ពូជដោយធម្មជាតិ ............ ៨
២.២. ការបង្កាត់ពូជដោយសិប្បនិម្មិត ............ ៨
៣. ប្រជាប់បន្តពូជគោមេ ............ ១០
៤. ភាពរកឈ្មោលរបស់មេគោ ............ ១១
៤.១. អ្វីទៅជាភាពនៃការរកឈ្មោល(ដោយឈ្មោល) ? ............ ១១
៤.២. សារៈប្រយោជន៍នៃការតាមដានភាពរកឈ្មោលរបស់គោមេ ............ ១២
៤.៣. សញ្ញានៃការរកឈ្មោលរបស់មេគោ ............ ១២
៤.៤. ការតាមដានការរកឈ្មោលរបស់មេគោ ............ ១៤
៤.៥. កម្មវិធីជោគជ័យសំខាន់ៗក្នុងការតាមដានភាពរកឈ្មោលរបស់សត្វ ............ ១៥
៥. ពេលវេលាសមស្របក្នុងការបង្កាត់ពូជ ............ ១៥
៦. ការធ្វើឱ្យគោមេរកឈ្មោលក្នុងពេលតែមួយ ............ ១៦
៧. ការផ្តល់ព័ត៌មានទាន់ពេលវេលាក្នុងការបង្កាត់ពូជ ............ ១៨
៨. មេគោមានលក្ខណៈសមស្របក្នុងការបង្កាត់ពូជ ............ ១៨
៩. បច្ចេកទេសនៃការបង្កាត់ពូជ ............ ១៨
៩.១. សម្ភារៈសម្រាប់ធ្វើការបង្កាត់ពូជ ............ ១៨
៩.២. បច្ចេកទេសនៃការបង្កាត់ ............ ១៩
១០. ការរក្សាទុកទឹកមេជីវិត ............ ២២
១១. ការគ្រប់គ្រងធុងនីត្រូសែន ............ ២៣
១២. ការយកទឹកមេជីវិតមកប្រើប្រាស់ ............ ២៤
១៣. វិធីធ្វើឱ្យរំលាយទឹកមេជីវិត ............ ២៥

១៤. ការរក្សាទឹកមេជីវិតនៅពេលធ្វើការបង្កាត់ ....... ២៥
១៥. ការផ្ទេរទឹកមេជីវិត ....... ២៦
១៦. ការផើមរបស់មេគោ ....... ២៧
១៧. ការចិញ្ចឹមមេគោបំបៅកូន ....... ២៧
១៨. ការចិញ្ចឹមកូនគោ ....... ២៨
**ជំពូកទី៣. ចំណីសត្វ** ....... ២៩
១. កត្តាចំណី ....... ២៩
១.១. ការផ្តល់ចំណី ....... ២៩
១.២. ការដាំដំណាំចំណីសត្វ ....... ២៩
២. បច្ចេកទេសដាំដំណាំចំណីសត្វ ....... ៤៣
ក. ការជ្រើសរើសទីតាំង ....... ៤៣
គ. បច្ចេកទេសដាំដំណាំចំណីសត្វ ....... ៤៩
ឃ. ការថែទាំ និងការគ្រប់គ្រងដំណាំចំណីសត្វក្រោយពេលដាំ ....... ៥៥
**ជំពូកទី៤. សុខភាព ជំងឺគោ ជំងឺឈាមខ្មៅ** ....... ៦៧
១. មេរោគបង្កជំងឺ និងការចម្លង ....... ៦៧
២. រោគសញ្ញា ....... ៦៧
ក. សណ្ឋានស្រួចស្រាវបំផុត ....... ៦៧
ខ. សណ្ឋានស្រួចស្រាវ ....... ៦៨
៣. ស្លាកស្នាម ....... ៦៨
៤. ការព្យាបាល ....... ៦៨
៥. ការការពារ និងការហាមឃាត់ ....... ៦៩
ក. ការការពារ ....... ៦៩
ខ. ការហាមឃាត់ ....... ៦៩
៦. ជំងឺដែលកើតទៅលើសត្វគោ ....... ៧០
១. ជំងឺបួសខ្យល់ ....... ៧០
២. ជំងឺសារទឹក Hemorrhagic septicemia: (HS) ....... ៧៣
៣. ការពុលជីអ៊ុយរ៉េ ....... ៧៦
៤. ជំងឺអុតក្តាម Foot and Mouth Disease (FMD) ....... ៧៨
៥. ជំងឺផ្លូវដង្ហើម ជំងឺរលាកសួត (Pneumonia) ....... ៨២
៦. ព្រូនក្នុងសួត ....... ៨៤
៧. ជំងឺរលាកពោះវៀន ដង្កូវថ្លើម ( fasciola ) ....... ៨៥
៨. ព្រូនខាងក្នុង ព្រូនក្នុងពោះវៀន ....... ៨៧
៩. ជំងឺកុកស៊ីដ្យូស៊ីស Coccidiosis ....... ៨៨

១០. ជំងឺអ៊ីកូលី E.Coli ... ៨៩
១១. ជំងឺសាល់ម៉ូណែឡា Salmonellosis ... ៩០
១២. ជំងឺរាគដោយឱកាស ... ៩១
១៣. ជំងឺហើមពោះ ... ៩២
១៤. បញ្ហាស្បែក បា៉សិតខាងក្រៅ ពពួកសត្វរុយ ... ៩៣
១៥. ពពួកសត្វមូស ... ៩៣
១៦. ពពួកសត្វដង្កែ ... ៩៤
១៧. ជំងឺបង្កដោយពពួកសត្វចៃ ... ៩៥
១៨. ជំងឺចាញ់ពន្លឺថ្ងៃ ... ៩៥
១៩. ការប្រែពណ៌ ... ៩៦
២០. ជំងឺដំបៅ ... ៩៦
២១. ជំងឺឫស ... ៩៧
២២. ជំងឺខ្វកជើង ... ៩៨
២៣. ជំងឺរលួយស្អុយជើង ... ៩៩
២៤. ជំងឺស្លាក់ ... ១០០
២៥. ជំងឺខ្វិនជើង ... ១០០
២៦. លក្ខខណ្ឌដងខ្លួនដែលទទួលមហន្តរាយ DISASTROUS BODY CONDITION ... ១០១
២៧. ជំងឺបន្តពូជ ជំងឺរលាកស្បូន / ហូរទឹកតាមយោនី ... ១០៣
២៨. ការមិនរកឈ្មោល ... ១០៤
២៩. ការរកឈ្មោលឡើងវិញ ... ១០៥
៣០. ជំងឺលាសដោះ Mastitis ... ១០៦

# ជំពូកទី១
# បច្ចេកទេសចិញ្ចឹមគោ

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍប្រជាជនប្រមាណជាង៨៥% ជាកសិកររស់នៅតាមជនបទដោយពឹងផ្អែកវិស័យកសិកម្ម ដើម្បីដោះស្រាយជីវភាពក្នុងគ្រួសារ និងសង្គមជាតិ។ បច្ចុប្បន្នរាជរដ្ឋាភិបាលមានគោលនយោបាយច្បាស់លាស់ ដើម្បីកែលម្អនិន្នាការមិនល្អនេះ ដោយផ្តោតយកចិត្តទុកដាក់លើវិស័យកសិកម្ម។ យ៉ាងណាមិញ វិស័យចិញ្ចឹមសត្វ ជាវិស័យគន្លឹះមួយក្នុងវិស័យកសិកម្ម ដែលបាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ដល់ការធានាសន្តិសុខស្បៀង កំណើនសេដ្ឋកិច្ច និងបង្កើនការងារ ជាពិសេសនៅតាមជនបទ ។

ប៉ុន្តែកន្លងមក ការចិញ្ចឹមសត្វរបស់កសិករភាគច្រើនចិញ្ចឹមជាលក្ខណៈគ្រួសារ ការផ្តល់ចំណីតាមបែបយថាផល ធ្វើឲ្យច្រវ៉ាក់ផលិតកម្មសត្វមានការយឺតយាវដោយបន្លាយពេលវែងធ្វើឲ្យកសិករទទួលផលមិនស័ក្តិសមទៅនឹងការបញ្ចេញកម្លាំងពលកម្ម លក់បានតម្លៃថោក។ នៅប្រទេសកម្ពុជា គោភាគច្រើនជាប្រភេទគោប៉ូសអេនឌីគូស (Bos Indicus) ដែលគេចិញ្ចឹមក្នុងគោលបំណងសំខាន់ជាកម្លាំងអូសទាញសម្រាប់ធ្វើស្រែចម្ការ។ គោទាំងនេះមានដូចជាៈពូជគោប្រាម៉ាន់ (Brahman) និងពូជគោហារីយាណា( Hariana) ពូជទាំងនេះ ត្រូវបាននាំចូលនាឆ្នាំ១៨៥៤ និងឆ្នាំ១៩៥៤ គោលបំណងនាំពូជគោទាំងនោះមកធ្វើការបង្កាត់ពូជដើម្បីកែលម្អពូជគោចិញ្ចឹមធ្វើជាកម្លាំងអូសទាញ។ នៅឆ្នាំ១៩៨៥នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅតាមរយៈអង្គការ LWS បាននាំនូវគោពូជប្រភេទប្រមាណចំនួន១៥៨ក្បាលមកដើម្បីធ្វើការកែលម្អពូជជូនប្រជាពលរដ្ឋក្នុងនោះមានគោបាពូជចំនួន១៨ក្បាល និងគោញីចំនួន១៤០ក្បាល ដែលបាននាំមកពីប្រទេសហ្វីលីពីនមកធ្វើការបង្កាត់ពូជ និងធ្វើការផ្សព្វផ្សាយទៅតាមបណ្តាខេត្តមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហេតុដូច្នេះ ទើបគេសង្កេតឃើញមានប្រភេទគោប៉ូសអេនឌីគូសខ្មែរ និងគោខ្មែររហូតមកដល់សព្វថ្ងៃនេះ។ តាមការចុះអង្កេតនៅឆ្នាំ២០០៦ បានឱ្យដឹងថា គោប្រភេទប៉ូសអេនឌីគូសខ្មែរមានប្រមាណ៧០% និងប្រភេទគោខ្មែរមានប្រមាណ៣០% នៃបរិមាណគោសរុបទាំងអស់។ នៅឆ្នាំ២០០៨ ឯកឧត្តមអ្នកឧកញ៉ាបណ្ឌិត **ច័ន្ទ សារុន** ទេសរដ្ឋមន្ត្រីនិងជាអនុប្រធានក្រុមការងារស្តារ និងអភិវឌ្ឍវិស័យកសិកម្ម អតីតរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននាំចូលពូជគោប្រភេទពូជកំផែងសែន ជាប្រភេទគោយកសាច់មកពីប្រទេសថៃចំនួន២៤ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល និងគោញីចំនួន២០ក្បាល មកធ្វើការបង្កាត់ពូជនៅក្នុងស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅផងដែរ។ ហើយរហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១២នេះ បានកើនរហូតដល់៤៣ក្បាល ក្នុងនោះញីចំនួន២៧ក្បាល និងឈ្មោល១៦ក្បាល។ កាលពីឆ្នាំ២០០៨ គម្រោងចិញ្ចឹមសត្វកម្ពុជាសហគមន៍អឺរ៉ុប (SLPP) បាននាំចូលទឹកមេជីវិតបង្កកពូជគោយកសាច់ប្រភេទសាន់តាហ្គឺទ្រូឌីស (Santa Gertrudis) និងប្រភេទស៊ីមប្រា(Simbra)ពីប្រទេសអូស្ត្រាលី និងប្រទេសអាមេរិក ដើម្បីមកធ្វើការបង្កាត់ពូជសិប្បនិម្មិតជាមួយពូជគោក្នុងស្រុក ជាពិសេសនៅខេត្តពោធិ៍សាត់ និងខេត្តតាកែវ។ ថ្មីៗនេះការកែលម្អពូជគោបានទទួលស្គាល់ និងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគទុន និងកសិករទូទាំងប្រទេសដែលថ្មីៗនេះមានក្រុមហ៊ុន និងភ្នាក់ងារឯកជនមួយចំនួនបាននាំពូជគោ និងទឹកមេជីវិតបង្កកប្រភេទផ្សេងៗពីបណ្តាប្រទេសនានាលើពិភពលោកក្នុងការកែលម្អពូជគោនៅកម្ពុជា។ ទោះជាយ៉ាងនេះក្តី ការសិក្សាអំពីការវិវត្តសេដ្ឋកិច្ចនៃពូជ ការបង្កាត់ពូជ និងការបង្កើតកម្មវិធីបង្កាត់ពូជច្បាស់លាស់ដែលមានសារៈសំខាន់ក្នុងការអភិវឌ្ឍការកែលម្អពូជគោនៅកម្ពុជា ដើម្បីជាគុណប្រយោជន៍ដល់សេដ្ឋកិច្ច ក៏ដូចជាកសិករដែលរស់នៅតាមជនបទផងដែរ។ នៅក្នុងអាជីវកម្មចិញ្ចឹមសត្វ ជាពិសេសការចិញ្ចឹមគោដែលជាកត្តាសំខាន់ ដើម្បីធានាបាននូវការផ្តល់កូន មានសុខភាពល្អ ការលូតលាស់លឿន និងធ្វើឲ្យប្រសើរឡើងនូវគុណភាពសាច់ទៅតាមតម្រូវ

ការទីផ្សារ និងដើម្បីជាឱកាសចូលរួមក្នុងការប្រកួតប្រជែងទីផ្សារជាមួយប្រទេសជិតខាង។ ម្យ៉ាងទៀត ដូចដែលយើងបានដឹងស្រាប់ហើយថា កសិករចិញ្ចឹមសត្វភាគច្រើនមិនទទួលបានប្រាក់ចំណូលខ្ពស់ពីការចិញ្ចឹមសត្វ ដោយសារការចិញ្ចឹមពុំសមស្របតាមលក្ខណៈបច្ចេកទេសទាំងការជ្រើសរើសពូជ ការសាងសង់ទ្រុង ការផ្តល់ចំណី ការថែទាំ ជំងឺឆ្លងសត្វ ជីវសុវត្ថិភាព និងការការពារ។

## ២. ទីជម្រក ឬក្រោលគោ

ជម្រក ឬក្រោលគោមានសារៈសំខាន់ណាស់សម្រាប់ការពារទប់ទល់ជាមួយកម្តៅព្រះអាទិត្យ ទឹកភ្លៀង និងកត្តាចង្រៃផ្សេងៗទៀត។ ទីតាំងជម្រក ឬក្រោល ត្រូវស្ថិតនៅលើដីទីទួលមិនលិចទឹក ឬទឹកហូរកាត់ ហើយបាតនៃជម្រក ឬក្រោលត្រូវស្ងួតជានិច្ច និងត្រូវសម្អាតលាមកចេញរៀងរាល់ថ្ងៃ ដើម្បីរក្សាឲ្យកម្រាលដីនៃជម្រកមានសភាពស្ងួត។ ជម្រក ឬក្រោល គួរស្ថិតនៅខាងក្រោមខ្យល់នៃផ្ទះ ដើម្បីកុំឲ្យជះក្លិនដល់ផ្ទះ។ មិនគួរចិញ្ចឹមគោក្រោមផ្ទះនោះទេ ព្រោះវាអាចមានផលមិនល្អ និងប៉ះពាល់ដល់សុខភាពអ្នកចិញ្ចឹម។ ជម្រក ឬក្រោល មានគុណសម្បត្តិដ៏ធំធេងចំពោះសត្វ វាជួយបង្កើនសុខភាពសត្វដែលអាចជម្នះបានរាល់ការរាតត្បាតនៃជំងឺឆ្លងផ្សេងៗ។ សម្ភារៈសាងសង់ យើងអាចរកបាននៅតាមមូលដ្ឋានដូចជា ដើមឬស្សី កូនឈើ និងដំបូលប្រកស្លឹកត្នោត ស្បូវ ឬស័ង្កសី។ល។




ក្រោលគោ-ក្របីដំបូលប្រក់ស័ង្កសី



ក្រោលគោ-ក្របីដំបូលប្រក់ស្លឹកត្នោត



ក្រោលគោ-ក្របីដំបូលប្រក់ស្បូវ




ក្រោលគោ-ក្របីដំបូលប្រក់ស័ង្កសីលក្ខណៈពាណិជ្ជកម្ម

### ផ្ទៃក្រឡាសម្រាប់ ១ក្បាល

| ល.រ | សត្វ | ផ្ទៃក្រឡា ម៉ែត្រការ៉េ | ផ្សេងៗ |
|---|---|---|---|
| ❖ **របៀបសាងសង់ក្រោល** | | | |
| ១ | គោ-ក្របីឈ្មោល | ៥ - ៦ម²/១ក្បាល | |
| ២ | គោ-ក្របីញី | ៤ម²/១ក្បាល | |
| ៣ | គោ-ក្របីបំបៅកូន | ៨ - ៩ម²/១ក្បាល | |
| ៤ | កូនគោ-ក្របី | ២ - ២.៥ម²/១ក្បាល | |
| ❖ **កម្ពស់ក្រោល** | | | |
| ៥ | គោ-ក្របីឈ្មោល | ១.៦០ - ២.២០ម | |
| ៦ | គោ-ក្របីញី | ១.៥០ - ១.៦០ម | |

### គ/ ទ្រុង/ស្នូកចំណី និងស្នូកទឹក

ទ្រុង/ស្នូកចំណី និងស្នូកទឹក ជាកត្តាសំខាន់ណាស់ចំពោះសត្វ សម្រាប់រក្សាចំណីឲ្យស្ថិតក្នុងសភាពស្អាត មិនធ្វើឲ្យចំណីជ្រុះមកលើដី ទ្រុងដាក់ចំណីមិនចាំបាច់មានសោភណ្ឌភាពស្អាតល្អពេកទេ យើងអាចធ្វើវាដោយសម្ភារៈដែលអាចរកបាននៅតាមមូលដ្ឋាន ប៉ុន្តែវាអាចសន្សំការបាត់បង់ចំណី។ ដោយឡែកប្រសិនបើកសិករមិនបានធ្វើទ្រុងដាក់ចំណីទេនោះ វាធ្វើឲ្យមានការបាត់បង់ចំណីរហូតដល់ទៅ ២៥%។ ចំពោះស្នូកទឹកក៏ជាកត្តាចាំបាច់សម្រាប់រក្សាទឹកឲ្យបានស្អាត និងមានទឹកជាប្រចាំ ដើម្បីឲ្យគោអាចផឹក និងជួយសម្រួលដល់ការរំលាយអាហារយ៉ាងមានប្រសិទ្ធភាព។ យើងអាចដាក់ទឹកក្នុងធុងប៉េត្រូ និងធ្វើអាងតូចៗនៅក្នុងទ្រុងសម្រាប់គោផឹក។ ម្យ៉ាងទៀត ដើម្បីប្រាកដថា សត្វមានសុខភាពល្អ និងធំធាត់លឿន ស្នូកចំណី និងស្នូកទឹកត្រូវតែស្អាត និងមានអនាម័យល្អ ហើយត្រូវធ្វើការប្រមូលចំណី និងទឹកដែលនៅសល់ចេញជាប្រចាំ ។



ស្នូកចំណីធ្វើអំពីបន្ទះឬស្សី



ស្នូកចំណីធ្វើពីពីក្តារបន្ទះ





ស្នូកចំណីធ្វើអំពីស៊ីម៉ង់ត៍



ស្នូកទឹកធ្វើអំពីដែក



ស្នូកទឹកធ្វើអំពីជ័រ

### ខ/ ការបន្ថែមរបបចំណី និងទឹក

គោត្រូវផ្តល់ចំណីឲ្យបានច្រើននៅស្មៅខ្ចី និងទឹកស្អាត ជាពិសេសនៅរដូវប្រាំង គឺត្រូវបន្ថែមចំណី និងទឹកឲ្យបានគ្រប់គ្រាន់ជាការចាំបាច់ ព្រោះសត្វមិនអាចរកស៊ីស្មៅខ្ចី និងផឹកទឹកបានគ្រប់គ្រាន់ដោយខ្លួនឯងបានទេ យើងត្រូវមានចំបើងដើម្បីផ្តល់ដល់គោពេញមួយឆ្នាំ។ កសិករត្រូវផ្តល់ចំណីបន្ថែមដល់គោនូវចំណីដែលសំបូរជាតិ ប្រូតេអ៊ីន វីតាមីន ជាតិដែក និងថាមពល ដូចជាៈ ស្មៅខ្ចី ស្លឹករុក្ខជាតិខ្ចីៗ ដំឡូងមីចំណិត ពោត ដើមសណ្តែកដីហាលស្ងួត ស្លឹកដំឡូងជ្វា និងកាកសណ្តែសៀង។ កសិករអាចធ្វើចំបើងផ្អាប់ជាមួយអ៊ុយរ៉េ ផ្អកស្មៅ និងផ្តល់ចំណីផ្សេងៗទៀតដែលអាចរកបាន ។









# ជំពូកទី២
# ពូជ និងការបង្កាត់ពូជ

## ១. កត្តាពូជ

ពូជសត្វបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចិញ្ចឹមសត្វ យើងដឹងហើយថាពូជគោមានច្រើនប្រភេទដូចជាៈ ពូជគោចិញ្ចឹមយកសាច់ និងកម្លាំងអូសទាញ ពូជគោចិញ្ចឹមយកទឹកដោះ និងពូជគោចិញ្ចឹមយកសាច់ផង និងទឹកដោះផង។ បច្ចុប្បន្ននេះ ពូជគោនៅក្នុងប្រទេសកម្ពុជាយើងមានពីរប្រភេទគឺៈ ពូជគោនាំចូល និងពូជគោក្នុងស្រុក។

### ១.១. ពូជក្នុងស្រុក

ពូជគោក្នុងស្រុកមានពីរប្រភេទគឺ ពូជគោតំបន់ទំនាបកណ្តាល និងពូជគោតំបន់ខ្ពង់រាប ពូជទាំងនេះជាពូជងាយស្រួលក្នុងការចិញ្ចឹម ព្រោះវាធន់ទៅនឹងអាកាសធាតុក្នុងតំបន់ និងជំងឺ។ ប៉ុន្តែពូជគោក្នុងស្រុកមានមាឌតូចក្រធំ និងលក់បានតម្លៃថោក។

#### ក. ពូជគោតំបន់ទំនាបកណ្តាល

ជាពូជដែលមានមាឌធំល្មម មានដងខ្លួនវែងប្រមាណពី ១៥០-១៨០សម កខ្លី ឬរពុំសូវធ្លាក់ បូកតូច ស្នែងវែងល្មមស្រួចចុង (២២-២៧សម) ពោះធំ សម្បុរត្នោត ក្រហម ចំប៉ា ឬខ្មៅ ទម្ងន់ជាមធ្យមពី ២៥០-៣៥០គ.ក្រ ពូជគោទាំងនេះគឺសម្បូរនៅខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពត កំពង់ស្ពឺ កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង និងខេត្តកណ្តាល។



ពូជគោតំបន់ទំនាបកណ្តាល

#### ខ. ពូជគោតំបន់ខ្ពង់រាប

ជាពូជដែលមានមាឌតូច ដងខ្លួនតូច ប្រវែងប្រមាណពី ១២០-១៧០សម កខ្លី គ្មានឬរ បូករាងជើបបន្តិច ត្រចៀកធំ ខ្នងកោង ភ្លែកលៀនបន្តិច ពោះធំល្មម ស្នែងខ្លី សម្បុរក្រហមត្នោត ទម្ងន់ពី១៥០-២០០គ.ក្រ។ ពូជគោប្រភេទនេះ គឺជួបប្រទះនៅខេត្តក្រចេះ ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី ឧត្តរមានជ័យ ព្រះវិហារ សៀមរាប និងតំបន់មួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។





ពូជគោតំបន់ខ្ពង់រាប

## ១.២. ពូជនាំចូល

ពូជគោនាំចូលមាន: ពូជប្រាម៉ាន់ និងពូជអារីយ៉ាណា ប៉ុន្តែបច្ចុប្បន្ននេះ យើងបានធ្វើការនាំចូលពូជថ្មីៗមួយចំនួនទៀតដូចជា: ពូជកំផែងសែន ពូជស៊ីមប្រា និងពូជសាន់តា មកធ្វើការបង្កាត់ជាមួយគោមេពូជក្នុងស្រុក ពូជទាំងនេះមួយចំនួនត្រូវបានបង្កាត់ដោយសប្បនិម្មិត។ ពូជនេះមានមាឌធំ ចិញ្ចឹមឆាប់ធំ និងលក់បានតម្លៃថ្លៃ ដែលអាចប្រកួតប្រជែងនៅលើទីផ្សារប្រទេសជិតខាងបាន ប៉ុន្តែពូជនាំចូលមានការលំបាកក្នុងការចិញ្ចឹម ព្រោះវាមិនធន់ទៅនឹងអាកាសធាតុនៅក្នុងតំបន់ ជំងឺឆ្លង ពិបាកក្នុងការថែទាំ ត្រូវការចំណីច្រើន និងមានគុណភាព។





## ក. ការជ្រើសរើសពូជ

ដើម្បីជានានូវការបង្កាត់មួយមានប្រសិទ្ធភាពខ្ពស់ យើងគប្បីអនុវត្តន៍ដូចខាងក្រោម:

### ការជ្រើសរើសបាគោ

ត្រូវធ្វើការជ្រើសរើសគោដែលមានមេបាល្អ និងស្គាល់ពីប្រវត្តិពូជច្បាស់លាស់ ហើយមានរូបរាងដូចខាងក្រោម:

- រូបរាងស្អាត មាឌធំ មានជើងរឹងមាំ និងមានក្រចកល្អ
- ពងស្វាសធំ និងមានទំហំប្រហាក់ប្រហែលគ្នា (មិនទក ឬកោប)
- មានសុខភាពល្អ និងមិនធ្លាប់កើតជំងឺឆ្លងផ្សេងៗ និងជាពិសេសជំងឺផ្លូវបន្តពូជ។





### ការជ្រើសរើសគោមេ

- មានរូបរាងស្អាត និងក្បាលរាងវេើបបន្តិច
- ប្រមុះរាងក្តោងទន្សាយ
- មានកន្សោមដោះធំល្អ និងចុងដោះស្មើគ្នាទាំងបួន
- មានសុខភាពល្អ និងមិនធ្លាប់កើតជំងឺឆ្លងផ្សេងៗ ជាពិសេសជំងឺផ្លូវបន្តពូជ (រលូតកូន) និងមានមាឌធំ។





## ខ. ភាពពេញវ័យរបស់គោ

ចំពោះគោមេពេញវ័យនូវអាយុ១៨ខែ ប៉ុន្តែយើងមិនអាចធ្វើការបង្កាត់បានទេ ព្រោះសរីរាង្គប្រដាប់បន្តពូជរបស់វាមិនទាន់ពេញលក្ខណៈនៅឡើយ យើងត្រូវធ្វើការបង្កាត់ក្រោយវាមានអាយុ ២ឆ្នាំកន្លះ ទៅ៣ឆ្នាំ ដើម្បីឲ្យសរីរាង្គប្រដាប់បន្តពូជរបស់វាពេញលក្ខណៈ។ គោដែលត្រូវធ្វើការបង្កាត់នោះ ត្រូវធានាថាមានសុខភាពល្អ ទទួលការថែទាំបានត្រឹមត្រូវ និងទទួលការផ្តល់ចំណីគ្រប់គ្រាន់ទាំងបរិ មាណ និងគុណភាព។

ចំពោះគោបា អាចធ្វើការបង្កាត់បានក្រោយវាមានអាយុ៣ឆ្នាំ ដើម្បីឱ្យសរីរាង្គប្រដាប់បន្តពូជរបស់វាពេញលក្ខណៈ។ ដូច្នេះ ចំពោះការចិញ្ចឹមគោជាលក្ខណៈគ្រួសារ ការបង្កាត់ពូជដែលទទួលបានលទ្ធផលល្អ គឺនៅក្នុងកំឡុងពេលសម្បូរស្មៅ។

## ២. ការបង្កាត់ពូជ

កសិករគួរមានការប្រុងប្រយ័ត្នក្នុងការបង្កាត់ពូជគោ ព្រោះវាអាចខាតបង់ពេលវេលា និងថវិកាបើមេគោមិនផើម។ កសិករត្រូវអង្កេតតាមដានត្រួតពិនិត្យឲ្យបានត្រឹមត្រូវនូវស្ថានភាព និងពេលវេលាមេគោរកឈ្មោល និងការថែរក្សាមេក្រោយពេលបង្កាត់រួច។ ការបង្កាត់ពូជ គឺយើងធ្វើឡើងមានពីររបៀបគឺៈ

### ២.១. ការបង្កាត់ពូជដោយធម្មជាតិ

ការបង្កាត់ពូជដោយធម្មជាតិ ត្រូវបានអនុវត្តឡើងដោយយកគោបាមកធ្វើការបង្កាត់ជាមួយមេគោដោយផ្ទាល់។ ការបង្កាត់បែបនេះគោបានឹងងាយបាត់បង់សមត្ថភាពបង្កាត់ក្នុងរយៈពេលខ្លី ព្រោះគោបាយើងអាចប្រើប្រាស់ធ្វើការបង្កាត់ក្នុងរង្វង់រយៈពេលតែ ៦.៨ឆ្នាំតែប៉ុណ្ណោះ និងធ្វើឱ្យមានការបាត់បង់មេជីវិតក្នុងការបង្កាត់មេគោដ៏ច្រើនទៀតផង។ ម្យ៉ាងទៀតគោបាដែលធ្វើការបង្កាត់ពូជតាមធម្មជាតិ ជាទូទៅ អាចបង្កាត់ជាមួយមេគោគិតជាមធ្យមក្នុង ១ថ្ងៃ បានតែ ២.៣ក្បាល។ ប៉ុន្តែយើងអាចបង្កាត់បានរហូតដល់ ៥ក្បាល។ ដូច្នេះ ប្រសិនបើយើងធ្វើការបង្កាត់លើសពី ៥ក្បាល/មួយថ្ងៃ គោបានោះនឹងបាត់បង់សមត្ថភាពក្នុងការបង្កាត់ពី ១ឆ្នាំ ទៅ២ឆ្នាំ ក្នុងរយៈពេលប្រើប្រាស់ខាងមុខមិនខាន។ ចំពោះការបង្កាត់ពូជដោយធម្មជាតិនេះ គឺយើងធ្វើការបង្កាត់មេបានចំនួនតិច បើធៀបទៅនឹងការបង្កាត់ពូជសិប្បនិម្មិត។ ក្នុងការបង្កាត់ដោយធម្មជាតិ គោបាត្រូវបានបញ្ចេញទឹកមេជីវិតក្នុងបរិមាណច្រើនលើសតម្រូវការក្នុងការធ្វើឱ្យមេគោផើម។ ម្យ៉ាងទៀតការបង្កាត់ពូជដោយធម្មជាតិធ្វើឱ្យសត្វទទួលរងនូវស្ត្រេសដល់រាងកាយយ៉ាងច្រើនក្នុងពេលធ្វើការបង្កាត់ពូជម្តងៗ លទ្ធផលនៃការផើមខ្សោយ ដោយសារគោបាបង្កាត់មេច្រើនពេកក្នុងថ្ងៃតែមួយ ងាយចម្លងមេរោគពីបាដោយសារបាបានចម្លងជំងឺពីមេដែលបានបង្កាត់មុន ពិសេសជំងឺផ្លូវបន្តពូជ (ជំងឺរលាកស្បូន រលូតកូន និងងាប់កូនក្នុងពោះ) គោបាមិនបានត្រួតពិនិត្យពីគុណភាពទឹកមេជីវិត អាចបណ្តាលឲ្យការបង្កកំណើតខ្សោយត្រូវដឹកមេគោទៅជួបបា ដែលធ្វើឲ្យមេគោហត់ និងចុះខ្សោយ ជាពិសេសពេលមេគោត្រឡប់មកដល់ផ្ទះវិញមានចម្ងាយផ្លូវឆ្ងាយអាចបណ្តាលឲ្យហៀរទឹកមេជីវិតចេញមកក្រៅវិញអាចមានគ្រោះថ្នាក់ដល់គោមេពេលធ្វើការបង្កាត់។ កត្តាទាំងនេះគឺត្រូវបានជំរុញឱ្យយើងកំណត់នូវបរិមាណដែលគោបាអាចបង្កាត់ពូជដោយធម្មជាតិបាន។




### ២.២. ការបង្កាត់ពូជដោយសិប្បនិម្មិត

#### ក. គុណសម្បត្តិ

ការបង្កាត់ពូជដោយសិប្បនិម្មិត គឺជាដំណើរការនៃការប្រមូលកោសិការមេជីវិតសត្វឈ្មោល បន្ទាប់មកដាក់បញ្ចូលកោសិការមេជីវិតទាំងនោះទៅក្នុងប្រដាប់បន្តពូជសត្វញី ដើម្បីកែលម្អពូជដូចជាៈ

- ការកែលម្អគុណភាពពូជ(សេនេទិក)នៃសត្វ
- បង្កើនប្រាក់ចំណូលពីការចិញ្ចឹមសត្វ
- ទទួលបានពូជអ្នកចង់បានតាមតម្រូវការ ទទួលបានពូជគោបាដែលមានគុណភាព និងលក្ខណៈល្អប្រសើរក្នុងតម្លៃសមរម្យ
- កាត់បន្ថយលើការចំណាយទិញ ការថែរក្សា និងការផ្តល់ចំណីដល់គោបា
- កាត់បន្ថយគម្លាតពេលវេលានៃការបង្កាត់ពូជ និងការបង្កើតកូន
- កាត់បន្ថយកម្លាំងពលកម្ម និងការចំណាយទាក់ទងទៅនឹងភាពងាយស្រួលកើតកូន និងសមត្ថភាពក្នុងការផ្តល់ទឹកដោះ
- កាត់បន្ថយការឆ្លងជំងឺ និងបង្កើនប្រសិទ្ធភាពនៃការបង្កាត់ដូចជាៈ ការបង្កាត់ពូជដោយធម្មជាតិបានផ្តល់ឱកាសក្នុងការចម្លងជំងឺផ្សេងៗរវាងគោបា និងមេគោ។ មេរោគចម្លងជំងឺ ឬជំងឺឆ្លងខ្លះបណ្តាលឱ្យសត្វរលូតកូន និងមិនអាចមានកូនបាន។ ប៉ុន្តែបច្ចេកទេសបង្កាត់ពូជសិប្បនិម្មិត យើងបានធ្វើការពិនិត្យជាប្រចាំនូវមេរោគចម្លងជំងឺ បន្ទាប់ពីធ្វើការប្រមូលទឹកមេជីវិត និងពិនិត្យផងដែរនូវភាពអាចបង្ករកំណើតរបស់គោបាដែលធ្វើឱ្យយើងអាចធានាបាននូវប្រសិទ្ធភាពនៃការបង្កាត់ និងការពារការឆ្លងរាលដាលនៃជំងឺឆ្លងបាន
- ទឹកមេជីវិតអាចប្រើប្រាស់បានយូរអង្វែងទោះបីជាបាបានស្លាប់ទៅហើយក៏ដោយ
- ទឹកមេជីវិតងាយស្រួលធ្វើការដឹកជញ្ជូនទៅទីឆ្ងាយ ឬទៅតាមជនបទដាច់ស្រយាល ដើម្បីធ្វើការបង្កាត់
- អាចធ្វើការបង្កាត់មេគោគ្រប់ប្រភេទ ដោយមិនបង្កឱ្យមានគ្រោះថ្នាក់ឡើយ
- អាចធ្វើការបង្កាត់ពូជមេគោដោយមិនចាំបាច់ប្រើប្រាស់បាមកពាក់ផ្ទាល់ឡើយ
- អាចឱ្យយើងធ្វើការកត់ត្រាបានត្រឹមត្រូវក្នុងការបង្កាត់ពូជ និងការកើតកូន។

**ការបង្កាត់ពូជដោយសិប្បនិម្មិតគោ មានសារៈប្រយោជន៍គួរឱ្យកត់សម្គាល់ដូចខាងក្រោមៈ**

- **បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់គោបាៈ** ក្នុងការបង្កាត់ពូជដោយសិប្បនិម្មិតគោ ត្រូវបានជំរុញឱ្យយើងកំណត់នូវបរិមាណដែលគោបាអាចបង្កាត់ពូជដោយធម្មជាតិបាន។ ប៉ុន្តែបើតាមរយៈនៃការបង្កាត់ពូជសិប្បនិម្មិត ទឹកមេជីវិតប្រមូលបានពីគោបាម្តងយកមកលាយជាមួយសារធាតុចិញ្ចឹមអាចបង្កាត់បានរាប់រយដង។ ម្យ៉ាងវិញទៀត ទឹកមេជីវិតមានភាពងាយស្រួលក្នុងការដឹកជញ្ជូនហើយអាចធ្វើការបង្កាត់ពូជមេគោជាច្រើនក្នុងពេលតែមួយ ហើយទឹកមេជីវិតអាចរក្សាទុកបានយូរអង្វែង មានន័យថាគោបាអាចបង្កើតកូនបានច្រើនក្នុងរយៈពេលវែងជាងក្នុងអាយុជីវិតបន្តពូជរបស់វា។

- **បង្កើនសក្តានុពលក្នុងការជ្រើសរើសពូជៈ** ដោយសារការបង្កាត់ពូជសិប្បនិម្មិតអាចធ្វើឱ្យគោបាផលិតកូនបានច្រើន គេត្រូវការគោបាក្នុងចំនួនតិចតួចប៉ុណ្ណោះក្នុងការបង្កាត់ពូជ។ ដូច្នេះគេអាចធ្វើការជ្រើសរើសយកតែគោបាក្នុងបរិមាណកំណត់ណាមួយដែលមានលក្ខណៈល្អប្រសើរប្រើប្រាស់ជាបា ដើម្បីធ្វើការបង្កាត់ពូជដោយបង្កើននូវសក្តានុពលនៃជម្រើស។ ជាងនេះទៀតដោយសារគោបាអាចផលិតបានកូនច្រើន គេអាចធ្វើការសិក្សាអំពីតំណពូជក្នុងការវាយតម្លៃអំពីគុណភាពរបស់គោបា។ ជាចុងក្រោយ អ្នកវិនិយោគ អ្នកចិញ្ចឹម និងកសិករអាចប្រើប្រាស់នូវការបង្កាត់ពូជដោយសិប្បនិម្មិតក្នុងការបង្កើនសេនេទិកហ្វូងសត្វរបស់ខ្លួន និងអាចកាត់បន្ថយ ឬជៀសវាងបាននូវការជាន់ឈាម និងជំងឺឆ្លងផ្សេងៗ។

- **ការកាត់បន្ថយការចំណាយៈ** ជាធម្មតាគោបាលូតលាស់លឿន ស៊ីចំណីច្រើនជាងមេគោ មានកម្លាំងខ្លាំង ឆាប់ទទួលឈឺ ដូចនេះត្រូវការថែរក្សាក្នុងទ្រុងពិសេស និងត្រូវការបំពាក់ដោយឧបករណ៍ពិសេស។

- **បង្កើនសុវត្ថិភាពចំពោះសត្វ និងកសិករៈ** គោបាភាគច្រើនមានមាឌធំ និងមានលក្ខណៈចរិតកាចសាហាវ។ នេះមានន័យថាការចិញ្ចឹម និងថែរក្សាគោបាអាចមានគ្រោះថ្នាក់ ដោយសារគោបាភាគច្រើនធំជាងមេគោ។ ការបង្កាត់ពូជ

ដោយធម្មជាតិមានភាពគ្រោះថ្នាក់ចំពោះមេគោ ឬគោបាផ្ទាល់តែម្តង ជាងការធ្វើការបង្កាត់ពូជដោយសិប្បនិម្មិត។



## ខ. គុណវិបត្តិ

- ត្រូវការអ្នកបច្ចេកទេសជំនាញក្នុងការអនុវត្តការបង្កាត់ពូជ និងឧបករណ៍ទំនើបៗជាចាំបាច់
- ចំណាយពេល និងកម្លាំងពលកម្មច្រើន ជាធម្មតាក្នុងការបង្កាត់ពូជដោយធម្មជាតិ គោបាតាមដានដោយសភាវគតិនូវមេគោដែលស្ថិតក្នុងស្ថានភាពត្រឹមត្រូវមួយដែលអាចបង្កកំណើតបាន។ ប៉ុន្តែចំពោះការបង្កាត់ពូជដោយសិប្បនិម្មិតវិញ ការងារតាមដានគឺជាបន្ទុករបស់កសិករ។ ការតាមដានមិនបានល្អ និងទាន់ពេលវេលាក្នុងការរកឈ្មោលរបស់សត្វញី វានឹងកាត់បន្ថយនៅអត្រាបង្កកំណើតមេជីវិតសត្វឈ្មោល
- ត្រូវការពេលវេលាច្រើនជាងការបង្កាត់ពូជដោយធម្មជាតិ
- អ្នកបង្កាត់ពូជត្រូវទាមទារការយល់ដឹងអំពីប្រដាប់បន្តពូជ និងមុខងាររបស់វា
- ប្រសិនបើយើងមិនបានធ្វើការត្រួតពិនិត្យជំងឺគោបាឱ្យបានត្រឹមត្រូវនោះទេ វានឹងបង្កើន ការរាលដាលជំងឺបន្តពូជយ៉ាងឆាប់រហ័ស
- ទីផ្សារសត្វគោបា ជាធម្មតានឹងមានការថយចុះ ប៉ុន្តែទីផ្សារចំពោះគោបាដែលមានលក្ខណៈល្អនឹងកើនឡើង
- ការបង្កើតកូនបានច្រើនចំពោះគោបាអាចនឹងមានផលប្រយោជន៍ច្រើន ប្រសិនបើការជ្រើសរើសគោបាបានល្អប្រសើរ ត្រឹមត្រូវ និងមានភាពសុក្រឹត ប៉ុន្តែបើពុំនោះទេវានឹងគ្រាន់តែកាត់បន្ថយនូវប្រភេទសេនេទិកផ្សេងៗក្នុងហ្វូងសត្វតែប៉ុណ្ណោះ។ ការបង្កើនកូនចំពោះគោបា វានឹងកាត់បន្ថយផងដែរដល់ការបណ្តុំសេនេទិក។ ផលប្រយោជន៍នៃការជ្រើសរើសបានល្អប្រសើរនូវគោបា ត្រូវតែធ្វើឱ្យមានតុល្យភាពជាមួយនឹងឥទ្ធិពលអវិជ្ជមាននៃការថយចុះនៅប្រភេទសេនេទិកផ្សេងៗ។

# ៣. ប្រដាប់បន្តពូជគោមេ

ប្រដាប់បន្តពូជគោមេរួមមាន:

- ប្រដាប់ភេទខាងក្រៅ-យោនី( Vulva)
- Vestibule
- ផ្លូវរួមភេទ(សង្វាស) (Vagina)
- កស្បូន(Cervix)
- ស្បូន(Uterus)
  - ដៃស្បូន(Uterine horns)
  - តួស្បូន(uterine body
- បំពង់នាំអូវ៉ុល(Oviducts) ។






- អូវែ(Ovaries)





## ៤. ភាពរកឈ្មោលរបស់មេគោ

### ៤.១. អ្វីទៅជាភាពនៃការរកឈ្មោល(ដោយឈ្មោល) ?

ការរកឈ្មោល គឺជាស្ថានភាព ឬរយៈពេលនៃភាពទំរោរផ្លូវភេទដែលក្នុងរយៈពេលនោះមេគោ ទទួលយកនូវការពាក់ ឬការហក់ឡើងពាក់ពីលើរបស់គោបា ឬមេគោដទៃផ្សេងទៀតដែលស្ថិតនៅជាមួយ ឬនៅជិតគ្នា។ វដ្តនៃការរកឈ្មោលរបស់មេគោ កើតឡើងក្នុងរយៈពេលប្រមាណ ៣អាទិត្យម្តង(១៨ ទៅ២៤ថ្ងៃ) ហើយមេគោ ជាធម្មតារកឈ្មោល(ដោយឈ្មោល) ក្នុងរយៈពេលពី១៥ ទៅ១៨ម៉ោង ហើយអូវុល(មេជីវិតញី)នឹងធ្លាក់ក្នុងរយៈពេលប្រមាណពី១២ម៉ោង បន្ទាប់ពីរកឈ្មោល(ដោយឈ្មោល)។






### ៤.២. សារៈប្រយោជន៍នៃការតាមដានភាពរកឈ្មោលរបស់គោមេ

ការតាមដាននៃភាពរកឈ្មោលរបស់មេគោបានត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលាក្នុងកំឡុងពេលមេគោរកឈ្មោលនោះ គឺវាមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យយើងអាចធ្វើការបង្កាត់ពូជមេគោនោះទាន់ពេលវេលាដែលធ្វើឱ្យអត្រាមានកូនក្នុងកម្រិតខ្ពស់ គឺមានន័យថា មេគោអាចកើនកូនក្នុងចន្លោះពី១២ ទៅ១៥.៥ខែម្តង។ ប៉ុន្តែប្រសិនបើយើងមិនអាចតាមដានរកឃើញការរកឈ្មោលរបស់មេគោបានត្រឹមត្រូវ និងទាន់ពេលវេលាទេនោះ ធ្វើឱ្យយើងនឹងខាតបង់ពេលវេលាច្រើនក្នុងការចំណាយលើភាពទំនេររបស់មេគោ ដែលមិនអាចផើមម្តងទៀត។ កត្តាទាំងនេះបានធ្វើឱ្យចន្លោះ ឬ គម្លាតនៃការកើតកូននីមួយៗមានរយៈពេលវែងជាងធម្មតាដែលធ្វើឱ្យការចំណាយកាន់តែច្រើន ជាពិសេសលើចំណី និងការថែរក្សា។



### ៤.៣. សញ្ញានៃការរកឈ្មោលរបស់មេគោ

រយៈពេលនៃការរកឈ្មោលរបស់មេគោ គឺ ១ ទៅ ២ថ្ងៃ ហើយការរកឈ្មោលឡើងវិញរៀងរាល់ ២១ថ្ងៃ បន្ទាប់ពីដាក់បាមិនទទួលបានលទ្ធផល(ជាប់)។ គេត្រូវធ្វើការបង្កាត់ ឬដាក់បានៅក្នុងរយៈពេល ១៨ម៉ោង នៃការមានសញ្ញាប្រាប់ថារកឈ្មោល។ ស្ថានភាពនៃការរកឈ្មោលមេគោមានលក្ខណៈប្រាស់ប្រាលនៅមិនស្ងៀមឡើងពាក់គោដទៃដែលនៅជិតខ្លួន ទោះញី ឬឈ្មោលក្តី ស្រែកពោទ៏ មិនសូវស៊ីចំណី យោនីឡើងក្រហមព្រឿងៗរលោងមានចេញទឹករំអិលថ្លា រយៈពេលនេះ គឺជាពេលត្រូវដាក់ ឬធ្វើការបង្កាត់ ព្រោះពេលនោះមាត់ស្បូនកំពុងតែបើក ហើយប្រសិនបើហួសពេលនោះមាត់ស្បូននឹងត្រូវបានបិទវិញ ប្រសិនបើធ្វើការបង្កាត់នៅពេលនោះពុំទទួលបានលទ្ធផលទេ ព្រោះចំណង់ភេទសត្វញីមានការថយចុះជាបន្តបន្ទាប់រហូតដល់វាអស់ចំណង់ភេទ។ ដូច្នេះ ត្រូវរង់ចាំរហូតរយៈពេល ២១ថ្ងៃក្រោយ ទើបវារកឈ្មោលម្តងទៀត។

- **សញ្ញាចំបង:** គោមេឈរឱ្យគោបា ឬគោមេដទៃឡើងពាក់ សកម្មភាពនេះយើងអាចធ្វើការអង្កេតតាមរយៈការមើលឃើញផ្ទាល់ពេលគោផ្សេងៗទៀតឡើងពាក់ និងតាមរយៈការអង្កេតមើលឃើញនូវលក្ខណៈមួយចំនួនដូចខាងក្រោម:
  - រោមគុម្ពកន្ទុយប៉ះ ឬស្នាមសឹក
  - ស្នាមរលាតស្បែកម្ភុំប្រដាប់បន្តពូជ
  - ផ្នែកខាងក្រោមប្រឡាក់ភក់។

 

- សញ្ញាលើរាងកាយ
  - ប្រដាប់ភេទក្រហម ប៉ោង និងក្តៅ
  - មានទឹករំអិលពណ៌សស្អិតតោងដូចជាទឹកថ្លាចេញពីប្រដាប់ភេទ។

 

- សញ្ញាបន្ទាប់បន្សំដទៃទៀត
  - សត្វនៅប្រមូលផ្តុំគ្នា
  - កាត់បន្ថយការឃ្លានចំណី ពេលវេលា ចំណាយលើការស៊ីស្មៅ សម្រាក និងទំពារអៀង
  - ការផលិតទឹកដោះថយចុះ
  - លិឍ ឬហិតផ្នែកខាងក្រោយ ឬប្រដាប់ភេទគោដទៃទៀត
  - កញ្ច្រោល ឬមានសកម្មភាពជាងមុន
  - បញ្ចេញសំឡេង ឬស្រែកខ្លាំងៗ ហើយអាចដើរចេញឆ្ងាយពីហ្វូង
  - កន្ទុយនឹងមានភាពលើកឡើងខ្ពស់ជាងមុន
  - មានឈាមហូរចេញពីប្រដាប់ភេទ (៣៥ម៉ោងទៅ៤០ម៉ោងក្រោយពីការរកឈ្មោល) នេះបានបញ្ជាក់ថាជាពេលយឺតក្នុងការបង្កាត់ពូជ។





## ៤.៤. ការតាមដានការរកឈ្មោលរបស់មេគោ

ការតាមដានភាពរកឈ្មោលរបស់គោមេ យើងត្រូវការធ្វើការអង្កេតដោយផ្ទាល់របស់មនុស្ស។ ជាទូទៅគេធ្វើការអង្កេតតាមដានមេគោក្នុងរយៈពេលយ៉ាងតិច៣០នាទីនៅពេលព្រឹកព្រលឹម និង៣០នាទីនៅពេលថ្ងៃរៀបលិច និងពេលខ្លះយើងអាចធ្វើការអង្កេតនៅពេលថ្ងៃត្រង់ផងដែរ។ ម្យ៉ាងទៀតយើងអាចដឹងនូវភាពរកឈ្មោលរបស់មេគោដោយធ្វើការសង្កេតដោយភ្នែកផ្ទាល់បានតែ ៨០ ទៅ ៨៥% តែប៉ុណ្ណោះ។ ហើយធ្វើការកត់ត្រាដោយប្រុងប្រយ័ត្នគឺមានសារៈសំខាន់ណាស់ ដែលធ្វើឱ្យយើងអាចប៉ាន់ស្មានបានថា មេគោរកឈ្មោល ឬមិនទាន់ដល់ពេលរកឈ្មោល។ ការអង្កេតតាមដានភាពរកឈ្មោលរបស់មេគោយកទឹកដោះ មានភាពងាយស្រួលជាងមេគោយកសាច់ ព្រោះមេគោចិញ្ចឹមយកទឹកដោះស្ថិតក្នុងក្រោលជាប្រចាំ និងយកទឹកដោះជាប្រចាំពី ២ ទៅ ៣ ដងក្នុង ១ថ្ងៃ ចំណែកមេគោចិញ្ចឹមយកសាច់យើងមិនបាននៅជាប់ជាមួយវាជាប្រចាំនោះទេ។ ពោលគឺ ពេលខ្លះយើងត្រូវប្រើប្រាស់ឧបករណ៍ផ្សេងៗជាជំនួយក្នុងការអង្កេតតាមដានភាពរកឈ្មោលរបស់មេគោ និងការវាស់នូវបរិមាណអ័រម៉ូនប្រូហ្គេស្តេរ៉ូនក្នុងទឹកដោះ ឬក្នុងឈាមរបស់មេគោ។ តាមរបាយការណ៍ សិក្សាស្រាវជ្រាវបានបង្ហាញឱ្យដឹងថា មេគោបង្ហាញនូវភាពរកឈ្មោលទៅតាមពេលវេលា ហើយភាគច្រើនកើតមានឡើងនៅពេលយប់រហូតដល់ទៅ៤៣%។ ភាពរកឈ្មោលរបស់មេគោមានដូចខាងក្រោម:

- ពេលព្រឹក(ចាប់ពីម៉ោង៦ព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់) អត្រារកឈ្មោលប្រមាណ២២%
- ពេលល្ងាច(ចាប់ពីម៉ោង១២ថ្ងៃត្រង់រហូតដល់ម៉ោង៦ល្ងាច) អត្រារកឈ្មោលប្រមាណ១០%
- ពេលយប់(ចាប់ពីម៉ោង៦ល្ងាចរហូតដល់ម៉ោង១២អាធ្រាត) អត្រារកឈ្មោលប្រមាណ២៥%
- ពេលព្រលឹម(ចាប់ពីម៉ោង១២អាធ្រាតរហូតដល់ម៉ោង៦ព្រឹក) អត្រារកឈ្មោលប្រមាណ៤៣%។





### ៤.៥. កម្មវិធីជោគជ័យសំខាន់ៗក្នុងការតាមដានភាពរកឈ្មោលរបស់សត្វ

- ត្រូវអនុវត្តនូវកម្មវិធីអត្តសញ្ញាណកម្មសត្វ (ដូចជាការកិបត្រចៀក) ក្នុងការតាមដានមេគោនីមួយៗ ក្នុងវដ្តជីវិតរបស់វា។ ចំពោះការចិញ្ចឹមជាលក្ខណៈគ្រួសារដែលមានចំនួនតិចក៏ត្រូវចំណាំភិនសត្វឱ្យបានច្បាស់ដែរ
- ត្រូវកត់ត្រាឱ្យបានច្បាស់លាស់និងទៀងទាត់
- ត្រូវចាត់អ្នកណាម្នាក់ ដើម្បីទទួលខុសត្រូវក្នុងការតាមដានភាពរកឈ្មោល និងកត់ត្រានូវរាល់ព័ត៌មានដូចជាលេខសម្គាល់ ឬភិនសត្វ ពេលវេលានៃការអង្កេត និងសកម្មភាពនៃការឡើងពាក់សត្វដទៃ
- ត្រូវពិនិត្យមើលពីសកម្មភាពជាក្រុមរបស់សត្វ។ មេគោដែលរកឈ្មោលភាគច្រើនផ្លាស់ប្តូរនូវអាកប្បកិរិយាធម្មតារបស់ពួកវា ហើយជាធម្មតាវានៅផ្តុំគ្នា
- យើងអាចប្រើប្រាស់ពពួកអ័រម៉ូនប្រូស្តាហ្គ្លង់ឌីនធ្វើឱ្យសត្វរកឈ្មោលក្នុងពេលតែមួយ ការប្រើប្រាស់ពពួកអ័រម៉ូននេះអាចជួយដល់អ្នកតាមដាននៃភាពរកឈ្មោលរបស់សត្វ
- ត្រូវធ្វើការព្យាបាលមេគោដែលអាការៈឈឺជើងឱ្យបានរហ័ស ព្រោះមេគោឈឺមិនអនុញ្ញាតឱ្យសត្វដទៃទៀតឡើងពាក់និងពាក់សត្វផ្សេងទៀតទេ។

## ៥. ពេលវេលាសមស្របក្នុងការបង្កាត់ពូជ

មេគោបង្ហាញនូវភាពរកឈ្មោលរបស់វាក្នុងកំឡុងពេលពី ១៨ ទៅ ២៤ថ្ងៃម្តង គិតជាមធ្យមគឺ ២១ថ្ងៃ ឬ៣អាទិត្យម្តង។ សកម្មភាពរកឈ្មោលភាគច្រើនកើតមានឡើងរវាងអំឡុងពេលចាប់ពីម៉ោង ៦ល្ងាច និងម៉ោង ៦ព្រឹក។ មេគោបង្ហាញភាពរកឈ្មោលមានរយៈពេលប្រមាណ២៤ម៉ោង។ រយៈពេលនៃការរកឈ្មោលស៊ីបរបស់មេគោ (Standing heat) គឺជាពេលដែលគោមេមានសភាពនៅស្ងៀមព្រមឱ្យគោដទៃទៀតឡើងពាក់វាចាប់ផ្តើមពី១២ ទៅ១៨ម៉ោង បន្ទាប់ពីពេលចាប់ផ្តើមរកឈ្មោលដំបូង(៦ ទៅ១០ម៉ោង)។ មេជីវិតញី(អូវុល)នឹងចាប់ផ្តើមបញ្ចេញនៅជិតចុងបញ្ចប់នៃការរកឈ្មោលស៊ីប និងបង្កកំណើតបានរហូតដល់ពី៦ទៅ១០ម៉ោងបន្ទាប់មក។ ដើម្បីទទួលបាននូវអត្រាជាប់(មានកូន)ខ្ពស់ យើងគួរអនុវត្តការបង្កាត់ពូជនូវពេលជិតចប់នៃការរកឈ្មោលស៊ីប (ប្រមាណ១៥ម៉ោង បន្ទាប់ពីចាប់ផ្តើមរកឈ្មោលស៊ីប)។ សូមមើលដ្យាក្រាមបំប្រួញពន្យល់បន្ថែម។ ដើម្បីមានភាពងាយស្រួល យើងគួរអនុវត្តការបង្កាត់ពូជទៅតាមគោលការណ៍ព្រឹក និងល្ងាច ដូចខាងក្រោម៖

- ប្រសិនបើមេគោរកឈ្មោលស៊ីបនៅពេលព្រឹកយើងគួរតែធ្វើការបង្កាត់ពូជក្នុងកំឡុងពេល១២ម៉ោងក្រោយនៃការចាប់ផ្តើមមេគោរកឈ្មោលដំបូង គឺនៅពេលល្ងាចនៅក្នុងថ្ងៃតែមួយ
- ប្រសិនបើមេគោរកឈ្មោលស៊ីបនៅពេលល្ងាចយើងគួរតែធ្វើការបង្កាត់ពូជក្នុងកំឡុងពេល១២ម៉ោងក្រោយនៃការចាប់ផ្តើមមេគោរកឈ្មោលដំបូង គឺនៅពេលព្រឹកនៃថ្ងៃបន្ទាប់។

ប្រសិនបើពុំមានឃើញសញ្ញានៃការរកឈ្មោលរបស់មេគោពិតប្រាកដណាមួយដែលយើងអាចមើលឃើញនិងការរាយការណ៍ណាមួយអំពីភាពរកឈ្មោលរបស់មេគោពិតប្រាកដទេ យើងអាចធ្វើតេស្តមេគោ ដើម្បីដឹងពីភាពរកឈ្មោល និងពេលវេលាដែលត្រូវធ្វើការបង្កាត់ពូជដូចខាងក្រោមៈ

- ត្រូវប្រើបច្ចេកទេសពិនិត្យមើល ការរកឈ្មោលរបស់មេគោ ដោយពាក់ស្រោមដៃ រួចលូកដៃចូលតាមរយៈ ផ្លូវលាមក ដើម្បីលូកចាប់ និងធ្វើការសង្កត់កស្បូន ធ្វើដូច្នេះទឹករំអិលនឹងធ្លាក់ចេញពីប្រដាប់ភេទមកក្រៅ
- ដើម្បីដឹងថា តើមេគោនេះដល់ពេលធ្វើការបង្កាត់ហើយឬនៅ យើងត្រូវយកដំណក់ទឹករំអិលនេះមកដាក់លើមេដៃ និងមេដៃរួចយើងទាញពន្លាតវា ក្នុងន័យនេះប្រសិនបើទឹករំអិលនេះអាចលាតសន្ធឹង(ស្អិតយឺត)បានប្រមាណ ១០សង់ទីម៉ែត្រមិនដាច់នោះ យើងអាចសន្និដ្ឋានបានថាមេគោនោះកំពុងរកឈ្មោល ហើយយើងអាចធ្វើការបង្កាត់បាន។

| បញ្ចេញអូវុល<br>ម៉ោងទី២៥-២៨ | អូវុលមានជីវិតក្នុងរយៈពេល៦ម៉ោង<br>ម៉ោងទី២៨-៣៣ |
| --- | --- |
| ពេលវេលាសមស្របបំផុតក្នុងការបង្កាត់ពូជ ជិតពេល ចុងបញ្ចប់នៃការរកឈ្មោលស៊ុបម៉ោងទី២០-២៨ | |

ម៉ោង០ —— ១០ —— ២០ —— ៣០ —— ៤០

| ចាប់ផ្ដើមរកឈ្មោល ម៉ោងទី៦-១០ | រកឈ្មោលស៊ុប ១២-១៨ម៉ោងបន្ទាប់ពីការចាប់ផ្ដើមរកឈ្មោល | រកឈ្មោលស៊ុប | ចេញឈាមតាមប្រដាប់ភេទ ត្រូវរង់ចាំវដ្ដរកឈ្មោលម្ដងទៀត ១៨-២៤ថ្ងៃក្រោយ ។ | ដោយខកខានក្នុងការបង្កាត់ពូជ |
| --- | --- | --- | --- | --- |




## ៦. ការធ្វើឱ្យគោមេរកឈ្មោលក្នុងពេលតែមួយ

ដោយបច្ចុប្បន្ននេះ ផ្នែកវិទ្យាសាស្ត្រជឿនលឿន គេអាចធ្វើឱ្យមេគោរកឈ្មោលក្នុងពេលតែមួយបានដោយប្រើប្រាស់អ័រម៉ូន។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការជួយយើងដើម្បីកាត់បន្ថយពេលតាមដានភាពរកឈ្មោល ហើយគោមេទាំងអស់អាចធ្វើការបង្កាត់ពូជក្នុងពេលតែមួយបាន និងធ្វើឱ្យយើងចំណេញពេលវេលាក្នុងការបង្កាត់ពូជ។ ដូចនេះ អ័រម៉ូនដែលបានប្រើប្រាស់សម្រាប់ធ្វើឱ្យគោមេរកឈ្មោលនោះ មានដូចជាៈ ប្រូស្តាហ្គ្លង់ឌីន(Prostaglandin) ប្រូហ្គេស្ត្រូន(Progeste-rone) ឬហ្គូណាដូត្រូពីន(Gonadotropine-GNRH)។ ខាងក្រោមនេះ គឺជាវិធីមួយសាមញ្ញ និងមានភាពងាយស្រួល។




## ✚ ប្រូស្តាហ្គ្លង់ឌីន (Prostaglandin $PGF_{2}a$)

អ័រម៉ូននេះ គឺវាមានប្រសិទ្ធភាពក្នុងការជំរុញមេគោឱ្យមានវដ្តរកឈ្មោលប៉ុណ្ណោះ ហើយវាមិនជំរុញឱ្យមេគោគ្មានវដ្តរកឈ្មោលបានទេ។ ជាទូទៅការប្រើប្រាស់ការចាក់អ័រម៉ូនប្រភេទនេះក្នុងការធ្វើមេឱ្យគោរកឈ្មោលចំនួន ១ដងតែប៉ុណ្ណោះដែលជាវិធីសាស្រ្តសាមញ្ញងាយស្រួល និងអាចចំណាយថវិកាតិច និងពេលវេលាខ្លី។ ប៉ុន្តែយើងត្រូវមានការប្រុងប្រយ័ត្នខ្ពស់ដោយកុំចាក់លើមេគោពើម (ត្រូវប្រាកដថាចំពោះបញ្ហានេះ) ព្រោះវាអាចធ្វើឱ្យមេគោពើមរលូតកូនបាន។ ចំពោះការប្រើប្រាស់អ័រម៉ូននេះ ត្រូវគោរពតាមការណែនាំដែលបានភ្ជាប់មកជាមួយនឹងដបថ្នាំ និងភ្នាក់ងារជំនាញផ្តល់សេវាកម្មក្នុងការបង្កាត់ពូជដោយសិប្បនិម្មិតនេះ។

✚ វិធីចាក់អ័រម៉ូនប្រូស្តាហ្គ្លង់ឌីន(Prostaglandin)១ដងជាមួយនឹងកម្មវិធីបង្កាត់ពូជ៥ថ្ងៃ:

ការចាក់ប្រូស្តាហ្គ្លង់ឌីន (Prostaglandin) ដល់មេគោទាំងអស់នៅក្នុងថ្ងៃដំបូង(ថ្ងៃ០)បន្ទាប់មកត្រូវពិនិត្យតាមដានការរកឈ្មោល និងធ្វើការបង្កាត់ពូជ ១២ម៉ោងក្រោយពីមេគោរកឈ្មោលស៊ុប។ វិធីចាក់អ័រម៉ូនប្រូស្តាហ្គ្លង់ឌីន (Prostaglandin) ១ដងនេះនឹងធ្វើឱ្យមេគោដែលមានវដ្តរដូវ ឬរកឈ្មោល បង្ហាញពីសញ្ញានៃការរកឈ្មោលក្នុងកំឡុងពេលពី២ ទៅ៥ថ្ងៃបន្ទាប់ពីបានចាក់រួច។ ដូច្នេះ យើងត្រូវតាមដានភាពរកឈ្មោលចាប់ពីពេលចាក់អ័រម៉ូនប្រូស្តាហ្គ្លង់ឌីន (Prostaglandin) នៅថ្ងៃ ០ រហូតដល់ថ្ងៃទី៥ និងធ្វើការបង្កាត់ពូជបន្ទាប់ពីមេគោរកឈ្មោលស៊ុប១២ម៉ោង។ វិធីនេះនឹងអាចធ្វើឱ្យមេគោបង្ហាញសញ្ញានៃការរកឈ្មោល (ចំពោះសត្វដែលមានវដ្តរដូវ) បានរហូតដល់ ៧៥%ក្នុងកំឡុងពេលពី ២ ទៅ ៥ថ្ងៃបន្ទាប់។




✚ វិធីសាស្រ្តនៃការចាក់អ័រម៉ូនប្រូស្តាហ្គ្លង់ឌីន(Prostaglandin) និងកម្មវិធីបង្កាត់ពូជ១០ថ្ងៃ:

ក្នុងការបង្កាត់ពូជ យើងត្រូវពិនិត្យតាមដានមេគោនៅភាពរកឈ្មោលស៊ុបរបស់វាក្នុងកំឡុងពេល៥ថ្ងៃដំបូង និងធ្វើការបង្កាត់ពូជមេគោណាដែលរកឈ្មោល១២ម៉ោងបន្ទាប់ពីរកឈ្មោលស៊ុប។ ការចាក់អ័រម៉ូនប្រូស្តាហ្គ្លង់ឌីន(Prostaglandin) លើមេគោដែលមិនបានបង្កាត់ក្នុងកំឡុង៥ថ្ងៃដំបូង បន្ទាប់មកធ្វើការតាមដានភាពរកឈ្មោល និងធ្វើការបង្កាត់ពូជក្រោយពីរកឈ្មោលស៊ុប១២ម៉ោង។ មេគោដែលមានវដ្តរដូវនឹងបង្ហាញសញ្ញារកឈ្មោលពី២ ទៅ៥ថ្ងៃ បន្ទាប់ពីចាក់អ័រម៉ូនប្រូស្តាហ្គ្លង់ឌីន(Prosta -glandin)។ វិធីនេះនឹងអាចធ្វើឱ្យយើងធ្វើការបង្កាត់ពូជមេគោដែលមានវដ្តរដូវបានលើសពី៩%ក្នុងកំឡុងពេល១០ថ្ងៃនៃរដូវបង្កាត់ពូជ។

ចាក់ប្រូស្តាហ្គ្លង់ឌីន(Prostaglandin)តាមដានពិនិត្យភាពរកឈ្មោល និងធ្វើការបង្កាត់ពូជ តាមដានពិនិត្យភាពរកឈ្មោល និងធ្វើការបង្កាត់ពូជ



## ៧. ការផ្តល់ព័ត៌មានទាន់ពេលវេលាក្នុងការបង្កាត់ពូជ

កសិករ ឬម្ចាស់សត្វ ត្រូវតាមដានភាពរកឈ្មោលរបស់មេគោជាប្រចាំ និងធ្វើការសម្គាល់នូវលក្ខណៈនៃការរកឈ្មោលស៊ុបរបស់មេគោដូចខាងលើ(ឡើងពាក់ និងពាក់គោដទៃទៀត និងប្រដាប់ភេទឡើងប៉ោងក្តៅ ក្រហម និងមានទឹករំអិលស្អិតហូរចេញពីប្រដាប់ភេទ)។ ប្រសិនបើមេគោរកឈ្មោលត្រូវរាយការណ៍ជាបន្ទាន់ដល់អ្នកផ្តល់សេវាបង្កាត់ពូជ ដើម្បីផ្តល់សេវាបង្កាត់ពូជទាន់ពេលវេលា។ ប្រសិនបើមេគោរកឈ្មោលស៊ុបនៅពេលព្រឹក ឬល្ងាច ត្រូវទូរស័ព្ទភ្លាមទៅភ្នាក់ងារបង្កាត់ពូជដើម្បីឱ្យគេអាចមានពេលវេលាសាកសួរ រៀបចំសម្ភារៈបង្កាត់ពូជ និងធ្វើដំណើរមកបង្កាត់ពូជឱ្យបានទាន់ពេលវេលា។ ម្ចាស់សត្វដែលនៅមើលថែទាំជាមួយសត្វជាប្រចាំត្រូវរៀនអង្កេតសត្វរកឈ្មោលឱ្យបានពិតប្រាកដ ពុំនោះទេការបង្កាត់ពូជមិនអាចទទួលបានជោគជ័យនោះឡើយ និងធ្វើឱ្យខាតបង់ពេលវេលា និងថវិកាជាច្រើន ប្រសិនបើការបង្កាត់មិនជាប់ ឬមិនអាចបង្កកំណើតកូនបាន។ អ្នកអាចផ្តល់ពេលវេលាក្នុងការបង្កាត់ពូជអាចជួយកសិករ ឬម្ចាស់សត្វក្នុងការតាមដានភាពរកឈ្មោលរបស់សត្វ។

## ៨. មេគោមានលក្ខណៈសមស្របក្នុងការបង្កាត់ពូជ

- មេគោក្រមុំ មានសភាពរាងកាយ ការលូតលាស់ល្អ និងមានទម្ងន់សមស្រប និងធ្លាប់បង្ហាញនូវវដ្តរដូវរកឈ្មោលយ៉ាងតិច២ដង
- មេគោអាចធ្វើការបង្កាត់ពូជក្នុងវដ្តរដូវទី១ ៦០ថ្ងៃបន្ទាប់ពីបង្កើតកូន
- មេគោមិនចាស់ពេក គឺអាយុក្រោមប្រមាណ១០ឆ្នាំ មានវដ្តរកឈ្មោល និងមានលទ្ធភាពផ្តល់កូនបន្ថែម
- មេគោគ្មានជំងឺ ឬបញ្ហាប្រដាប់បន្តពូជ។

## ៩. បច្ចេកទេសនៃការបង្កាត់ពូជ

### ៩.១. សម្ភារៈសម្រាប់ធ្វើការបង្កាត់ពូជ

១. ស្រោមដៃ
២. ក្រដាសជូត
៣. កាំភ្លើងបង្កាត់ពូជ
៤. ស្រោមប្លាស្ទិកស្រោបកាំភ្លើង
៥. ធុងទឹកនីត្រូសែន
៦. ដង្កៀប
៧. កន្ត្រៃសម្រាប់កាត់
៨. ដបទឹកសម្រាប់រំលាយមេជីវិតឈ្មោល
៩. ទឹករំអិល។




## ៩.២. បច្ចេកទេសនៃការបង្កាត់

- ការរៀបចំសត្វ
- ការរំលាយទឹកមេជីវិត
- ការបញ្ចូលកាំភ្លើងដើម្បីធ្វើការបង្កាត់ពូជ
- ការបង្កាត់ពូជមេគោ។




### ៩.២.១. ការរៀបចំសត្វ

- បញ្ចូលសត្វនៅក្នុងសាឡុង ហើយគៀបឱ្យបានល្អកុំឱ្យសត្វមានការស្រែស គ្រោះថ្នាក់ ធ្វើយ៉ាងណាឱ្យមានការងាយស្រួលក្នុងការបង្កាត់ និងឱ្យមានសុវត្ថិភាពទាំងមនុស្ស និងសត្វ
- សាឡុងសត្វ ត្រូវស្ថិតក្នុងកន្លែងមានបរិស្ថានល្អ មានដំបូល និងងាយស្រួលក្នុងការបង្កាត់
- ត្រូវពិនិត្យលើឯកសារកត់ត្រា តើមេគោដែលត្រូវធ្វើការបង្កាត់ពូជនោះពិតជាសមស្របក្នុងការធ្វើការបង្កាត់ដែរ ឬទេ?
- ត្រូវពិនិត្យមើលថាតើមេគោដែលត្រូវធ្វើការបង្កាត់នោះដើម ឬយើងអាចលូកស្ទាបតាមរយៈទ្វារលាមក ថាតើមេគោនោះដើម ឬអត់?។




### ៩.២.២. ការរំលាយទឹកមេជីវិត

- ត្រូវធ្វើការរៀបចំដបដែលមានទឹកក្ដៅឧណ្ឌៗ ដែលមានកំដៅ ៣៧អង្សារសេ
- ត្រូវប្រើប្រាស់ដង្កៀបគាបយកបំពង់ទឹកមេជីវិតពីធុងនីត្រូសែនដាក់ចូលទៅក្នុងដបទឹកក្ដៅ ឧណ្ឌៗប្រមាណ ១៥វិនាទី
- ត្រូវជូតសម្អាតបំពង់ទឹកមេជីវិតដោយប្រើក្រដាសជូត
- ត្រូវបញ្ជាក់ថាយើងប្រើប្រាស់ទឹកមេជីវិតណាដែលយើងត្រូវប្រើ។





### ៩.២.៣. ការបញ្ចូលកាំភ្លើងដើម្បីធ្វើការបង្កាត់

- ទាញស្នូលកាំភ្លើងមកក្រោយប្រមាណ១៥០ម.ម
- ស៊កបំពង់មេជីវិតផ្នែកមានសំឡីចូលក្នុងកាំភ្លើង
- កាន់កាំភ្លើងដែលបញ្ចូលបំពង់មេជីវិតហើយបញ្ឈរទៅលើ
- ប្រើប្រាស់នូវកន្ត្រៃមុតស្អាតល្អសម្រាប់កាត់បំពង់ទឹកមេជីវិតប្រមាណ១០ម.ម ពីចុងកាំភ្លើង
- ស៊កស្រោមប្លាស្ទិកកាំភ្លើងពីលើដោយរំកិលបន្តិចម្តងៗ
- ខាំដោយមាត់នូវកាំភ្លើងដែលបញ្ចូលបំពង់ទឹកមេជីវិតហើយកាំភ្លើងសម្រាប់បង្កាត់ពូជសិប្បនិម្មិតដែលមានកងចាក់សោររាងជាអក្សរ(O)។





### ៩.២.៤. ការបង្កាត់ពូជមេគោ

- យើងគួរប្រើប្រាស់ដៃឆ្វេង(ទោះបីជាយើងទម្លាប់ប្រើប្រាស់ដៃឆ្វេង ឬដៃស្តាំក្នុងការរស់នៅប្រចាំថ្ងៃក៏ដោយ) ក្នុងការលូកចូលទៅក្នុងពោះតាមរយៈទ្វារលាមក ដើម្បីស្ទាបប្រដាប់បន្តពូជ ក្នុងការបង្កាត់ពូជមេគោដោយប្រើប្រាស់ដៃស្តាំកាន់ និងធ្វើចលនាកាំភ្លើងនៅពេលធ្វើការបង្កាត់ពូជដោយសិប្បនិម្មិតនេះ ពីព្រោះ ពោះធំ ឬក្រពះសត្វស្ថិតនៅផ្នែកខាងឆ្វេងនៃផ្នែកពោះ ដើម្បីរុញប្រដាប់បន្តពូជមេគោឱ្យទៅផ្នែកខាងស្តាំបន្តិចធ្វើឱ្យយើងងាយស្រួលក្នុងការស្ទាបប្រដាប់បន្តពូជដោយប្រើប្រាស់ដៃឆ្វេងជាជាងដៃស្តាំ
- ធ្វើការទះ ឬអង្អែលថ្នមៗលើត្រគាកមេគោ ឬប្រើប្រាស់សម្តីទន់ភ្លន់អាចជួយឱ្យមេគោ មិនភ្ញាក់ផ្អើល ឬចម្លែកនៅពេលមុនអនុវត្តធ្វើការបង្កាត់ពូជ
- ធ្វើការពាក់ស្រោមដៃខាងឆ្វេង និងលាបទឹករំអិលលើស្រោមដៃបន្តិចដើម្បីជួយបន្ថយការកកិតពេលយើងធ្វើការលូកដៃចូលក្នុងទ្វារលាមកមេគោ

- ត្រៀមក្រដាស់ស្អាតសម្រាប់ជូតទឹកបត់ដាក់ក្នុងហោប៉ៅអាវខាងឆ្វេង និងកាំភ្លើងដែលបញ្ចូល បំពង់ទឹកមេជីវិតហើយ(អាចខាំនឹងមាត់នៅផ្នែកខាងដើមនៃគល់កាំភ្លើងបន្តិច)
- ផ្តុំម្រាមដៃឆ្វេងចូលគ្នារាងស្រួចទៅមុខរាងជាសាជីរួចស៊កដៃតាមទ្វារលាមកថ្នមៗបាយក លាមកចេញក្នុងបរិមាណមួយចំនួនដែលអាចសម្រួលក្នុងការលូកស្ទាបកស្បូន(ពុំចាំបាច់បាលាមកចេញមកទេ ប្រសិនបើអាចស្ទាបកស្បូនបានស្រួល)
- ជូតប្រដាប់ភេទខាងក្រៅ(យោនី)ដោយដៃខាងស្តាំជាមួយនឹងក្រដាសស្អាតជ្រួកទឹក ដើម្បីយកចេញនូវលាមក និងកម្ទេចកំទីផ្សេងៗឱ្យស្អាត។ ការជូតអនុវត្តលើយោនីតាមទិសដៅ តែមួយពីលើចុះក្រោម និងផ្លាស់ប្តូរក្រដាសស្អាតជាប្រចាំ ឬបត់ក្រដាសរហូតដល់ស្អាត
- ត្រូវចងចាំ! កុំប្រើកម្លាំងសង្កត់ធ្ងន់ពេកដែលអាចគៀស ឬរុញលាមកគោចូលក្នុងយោនី និងផ្លូវរួមសង្វាស (ផ្លូវភេទ)
- ទាញកន្ទុយគោមេដោយប្រើដៃស្តាំហើយដាក់នូវផ្នែកខាងក្រោមនៃដើមដៃឆ្វេង(ធ្វើឱ្យយើងងាយស្រួលក្នុងការអនុវត្តការបង្កាត់ពូជ)
- ដាក់ដៃក្នុងទ្វារលាមកដល់ត្រឹមកដៃបន្ទាប់មកសង្កត់ដៃចុះក្រោមបន្តិច សង្កត់លើយោនីដើម្បីធ្វើឱ្យបបូរមាត់យោនីបើកបន្តិចងាយស្រួលក្នុងបញ្ចូលកាំភ្លើង
- បញ្ចូលកាំភ្លើង (ដែលបានរៀបចំបញ្ចូលបំពង់ទឹកមេជីវិតរួចហើយ)រវាងបបូរយោនីទាំងពីរក្នុងទិសដៅទៅលើមុំ៣០អង្សារ។ ធ្វើយ៉ាងនេះអាចជៀសវាងចុងកាំភ្លើងកុំឲ្យចូលក្នុងផ្លូវទឹក នោម និងប្លោកនោម។ នៅពេលរុញកាំភ្លើងចូលក្នុងផ្លូវរួមសង្វាសហើយ(vagina)ដៃរបស់យើងត្រូវតាមស្ទាបជាប់ចុងកាំភ្លើង (ងាយស្រួលដឹងពីទីតាំងរបស់កាំភ្លើង)
- នៅពេលដែលកាំភ្លើងចូលទៅក្នុងប្រដាប់ភេទ(ផ្លូវរួមសង្វាស)បានប្រមាណ១៥ទៅ២០សម(៦-៨ inches) យើងត្រូវតម្រង់កាំភ្លើងផ្តេកវិញ និងធ្វើចលនាទៅមុខសន្សឹមៗទន្ទឹមគ្នានេះដែរយើងត្រូវរុញកស្បូន (ដោយដៃឆ្វេងដែលចាប់កស្បូន) ទៅមុខបន្តិចដើម្បីកុំឲ្យមានរបត់ផ្លូវរួមសង្វាស (vagina folds) ងាយស្រួលក្នុងការរុញកាំភ្លើងទៅចំកស្បូនផ្ទាល់តែម្តង។ (កស្បូនមានសភាពរឹងគួរឲ្យកត់សម្គាល់នៅពេលយើងប៉ះវាប្រៀបធៀបទៅនឹងសារពាង្គកាយដែលនៅជុំវិញ ហើយយើងនឹងមានអារម្មណ៍រឹងបែបនេះនៅពេលដែលចុងកាំភ្លើងប៉ះនិងមុខកស្បូន។ កស្បូនផ្សំឡើងដោយជាលិកាសន្ធាន និងសាច់ដុំណែនដែលមានកង់ ឬគន្លាក់៣ ឬ៤ និងទំហំប្រែប្រួលទៅតាមភាពរឹងប្រហាក់ប្រហែល និងកមាន់ប្រហោងកស្បូនមានប្រើសបញ្ច្រាស់មករកផ្លូវរួមសង្វាស) ចំណុចសំខាន់នៅត្រង់នេះគឺធ្វើយ៉ាងណាឲ្យចុងកាំភ្លើងប៉ះមុខកស្បូនផ្ទាល់។ ក្នុងនាមជាអ្នកផ្តល់សេវាបង្កាត់យើងត្រូវដឹងឲ្យបានច្បាស់ពីទីតាំងរបស់ចុងកាំភ្លើងដែលធ្វើចលនា។ លាមកនៅក្នុងពេលខ្លះធ្វើឲ្យមានការលំបាកក្នុងការស្ទាបរកស្បូន និងចុងកាំភ្លើង ប៉ុន្តែយើងមិនចាំបាច់បាលាមកចេញឲ្យអស់ពីពោះគោនោះទេគឺ យើងគ្រាន់តែពន្លាដៃយើងឲ្យស្រប នឹងជញ្ជាំងពោះធំខាងក្រោមឲ្យលាមកនៅលើដៃនិងប្រអប់ដៃរបស់យើង។
- នៅពេលកាំភ្លើងទៅប៉ះមាត់កស្បូនយើងនឹងមានអារម្មណ៍គ្រាតៗ (នេះបញ្ជាក់ថាចុងកាំភ្លើងបានទៅដល់មុខកស្បូនពិតប្រាកដហើយ) ពេលនេះយើងត្រូវកាន់កស្បូនដោយម្រាមដៃ
- ដាក់កស្បូនមកចុងកាំភ្លើង (មិនមែនរុញចុងកាំភ្លើងឆ្លងកាត់កស្បូនទេ) និងធ្វើចលនាកស្បូនថ្នមៗ(ដៃឆ្វេង)។ នៅពេលដែលកាំភ្លើងចូលក្នុងកង់ទី១យើងនឹងមានអារម្មណ៍ថា កាំភ្លើងធ្វើចលនាទៅមុខសន្សឹមៗយើងត្រូវរក្សាការរុញកាំភ្លើងទៅមុខថ្នមៗផងដែរជាមួយនឹងបំលាស់ទីមេដៃ និងម្រាមដៃដែលចាប់កស្បូនទៅមុខចុង

កាំភ្លើង និងការធ្វើចលនាកស្បូនថ្នមៗរហូតដល់កាំភ្លើងអាចឆ្លងកាត់កស្បូនបានតែម្តង។ កាំភ្លើងនិងធ្វើចលនាធូរជាងមុន ឬដោយសេរីនៅពេលដែលវាបានឆ្លងកាត់កងនៃកស្បូនទាំងអស់។ ព្យាយាមកុំបំបោលត្រូវធ្វើយ៉ាងណាឱ្យមានលក្ខណៈទន់ភ្លន់ និងអត់ធ្មត់

- ស្ទាបមើលចុងកាំភ្លើងដោយប្រើប្រាស់ម្រាមចង្អុលដៃឆ្វេង។ ចុងកាំភ្លើងគួរហួសចុងកស្បូនតែបន្តិចប្រមាណ ០,៦សម (០,២៥inche) (គឺទៅដល់ប្រហោងតួស្បូន-uterus body)។ យើងអាចប្រើវិធីដូចរូបភាពក្នុងកំណត់ចុងប្រវែងកាំភ្លើងពីកស្បូនដោយប្រើចង្អុលដៃចុចស្ទាបចុងកាណុងនៅចំណុចចុងនៃកស្បូន ពីព្រោះមានសភាពទន់ស្តើង និងគ្មានកស្បូនទៀតទេ
- ធ្វើការបាញ់ទឹកមេជីវិតសន្សឹមៗរហូតដល់អស់ (កុំភ្លេចដកចង្អុលដៃចេញកុំសង្កត់ទៀត)។ ការបង្កាត់បានល្អប្រសើរគឺចុងកាំភ្លើងត្រូវស្ថិតនៅក្នុងប្រហោងតួស្បូន (uterine body) និងទឹកមេជីវិតត្រូវបានបាញ់បញ្ចូលនៅទីនោះទាំងអស់
- ការកន្ត្រាក់របស់ស្បូន និងនាំមេជីវិតឈ្មោលទៅកាន់ដៃស្បូន និងបំពង់នាំអូវុលទាំងសងខាងស្មើៗគ្នា
- បន្ទាប់ពីបាញ់ទឹកមេជីវិតអស់ហើយដកកាំភ្លើងចេញសន្សឹមៗចេញពីប្រដាប់ភេទ រួចសម្រួលផ្លូវប្រដាប់ភេទថ្នមៗបន្តិចដើម្បីឱ្យទឹកមេជីវិតធ្វើចលនាទៅមុខតាមសម្រួល និងតាមការកន្ត្រាក់នៃប្រដាប់ភេទ។ ដកដៃឆ្វេងដែលពាក់ស្រោមដៃចេញពីទ្វាលាមក និងបន្ទាប់មកត្រូវត្រួតពិនិត្យមើលចុងកាំភ្លើង ប្រសិនមានឈាមការឆ្លងរលិចទឹកមេជីវិតក្នុងស្រោមកាំភ្លើង។ ត្រូវធ្វើការកត់ត្រាទុកប្រសិនបើមានបញ្ហាខុសធម្មតា។ ទីបញ្ចប់ត្រូវបញ្ជាក់សារជាថ្មីនៅបំពង់ទឹកមេជីវិត (លេខកូត) ដែលបានប្រើប្រាស់។ បត់មូលស្រោមដៃដោយត្រឡប់ក្រៅចូលក្នុង បញ្ចូលស្រោមកាំភ្លើងដែលបានប្រើប្រាស់រួចបន្ទាប់មកគួចស្រោមដៃចងជាការស្រេចដើម្បីបោះចោលនៅកន្លែងសមរម្យណាមួយ។



## ១០. ការរក្សាទុកទឹកមេជីវិត

គុណភាពរបស់ទឹកមេជីវិតបង្កកនៅពេលមកដល់កន្លែង ឬកសិដ្ឋានកំណត់ដោយគោបា និងក្រុមហ៊ុន ឬស្ថាប័នដែលផលិត។ ប៉ុន្តែពេលមកដល់កន្លែង ឬកសិដ្ឋាននោះវាជាភារកិច្ចរបស់យើងក្នុងការថែរក្សាឱ្យបានត្រឹមត្រូវក្នុងការធានានូវគុណភាពទឹកមេជីវិតបង្កក។ មេជីវិតបង្កកអាចទុកបានរហូត ប្រសិនបើយើងអាចរក្សាទុកក្នុងសីតុណ្ហភាពថេរ និងទាបខ្លាំង។ ចំណុចសីតុណ្ហភាពដែលសមស្របបំផុត(ស្លាប់រស់)គឺប្រមាណ-១១២អង្សាហ្វារ៉ាត។ ទឹកមេជីវិតដាក់ក្នុងសីតុណ្ហភាពក្តៅជាង-១១២អង្សាហ្វារ៉ាត(ទោះបីស្ថិតក្នុងរយៈពេលខ្លីក៏ដោយ) បន្ទាប់មកដាក់រក្សាក្នុងធុងនីត្រូសែនវិញគឺវានឹងទទួលការខូចខាត ធ្វើឱ្យយើងមិនអាចយកទៅប្រើប្រាស់សម្រាប់ធ្វើការបង្កាត់ពូជបានឡើយ។ ទំហំនៃការខូចខាតរបស់មេជីវិតអាស្រ័យទៅនឹងរយៈពេលដែលវាស្ថិតនៅក្នុងសីតុណ្ហភាពដែលកើនឡើង។ ទឹកមេជីវិតមានការងាយស្រួល

ក្នុងការថែរក្សាទុកនៅសីតុណ្ហភាពដែលមានសុវត្ថិភាពណាស់ ប៉ុន្តែវានឹងងាយទទួលរងការខូចខាតក្នុងពេលដ៏ខ្លី ប្រសិនបើយើងមានការធ្វេសប្រហែស។





## ១១. ការគ្រប់គ្រងធុងនីត្រូសែន

ធុងនីត្រូសែនស្តុកទឹកមេជីវិតគឺជាធុងធ្វើអំពីដែក គ្របជិតដោយមជ្ឈដ្ឋានគ្មានខ្យល់(សុញ្ញាអាកាស) និងមានប្រព័ន្ធទ្រនាប់ល្អ និងមានប្រសិទ្ធភាព ដែលអាចរក្សាសីតុណ្ហភាពឱ្យនៅថេរបាននៅ-៣២០អង្សារហ្វារ៉ាត(ជាសីតុណ្ហភាពនៃទឹកនីត្រូសែន) នៅពេលដែលទឹកនីត្រូសែនមានយ៉ាងតិច២អ៊ីង។ បច្ចេកទេសទំនើបផលិតធុងស្តុកដែលអាចរក្សាទឹកនីត្រូសែនបានពី៦ទៅ៩ខែ។ ទោះបីជាធុងស្តុកផលិតបានល្អក៏ដោយ ក៏វានៅតែទទួលរងការខូចខាតនៅពេលយើងប្រើប្រាស់វាមិនបានល្អ។ ធុងស្តុកមេជីវិត គួររក្សាទុកនៅក្នុងកន្លែងស្អាត ស្ងួត មានខ្យល់ចេញចូលល្អ ជៀសវាងការបំលាស់ទីច្រើនដង។ ទឹកនីត្រូសែនដែលនៅផ្នែកខាងក្នុងធុង ត្រូវបានរាំងខ្ទប់មិនឱ្យចេញដោយបំពង់កធុង។ ការធ្វើឱ្យប៉ះពាល់ដល់បំពង់កធុងដោយសារការចាក់ទឹកនីត្រូសែនមិនបានប្រុងប្រយ័ត្ន ឬចលនាយោគខ្លាំងខុសធម្មតា អាចធ្វើឱ្យបំពង់កធុងបាក់បែកហើយនឹងអាចធ្វើឱ្យបាត់បង់មជ្ឈដ្ឋានគ្មានខ្យល់នៅផ្នែកស្រទាប់បន្ទាប់នៃធុង។

ដើម្បីរក្សាទុកទឹកនីត្រូសែនឱ្យបានយូរ យើងត្រូវរក្សាធុងស្តុកនៅក្នុងទីតាំងត្រជាក់ពីកម្តៅពន្លឺថ្ងៃផ្ទាល់ ការពារកុំឱ្យមានខ្យល់ស្ងួតពីឡកម្តៅ និងខ្យល់ខាងក្រៅនឹងអាចជួយកាត់បន្ថយការបំភាយទឹកនីត្រូសែន។ ប៉ុន្តែយើងត្រូវធ្វើយ៉ាងណាឱ្យមានខ្យល់ចេញចូលល្អនៅក្នុងបន្ទប់ដាក់ធុងស្តុក ដើម្បីជៀសវាងការថប់ដង្ហើមដែលបណ្តាលមកពីវត្តមានឧស្ម័ននីត្រូសែនលើសលុបក្នុងខ្យល់។ ធុងស្តុកនីត្រូសែនត្រូវដាក់ឱ្យខ្ពស់ពីដី ឬទីសើមដោយប្រើប្រាស់ក្តារ ឬទ្រនាប់ ដើម្បីជៀសវាងការច្រេះស៊ី ឬសំណឹក។ ទីតាំងរក្សាធុងស្តុកត្រូវមានសុវត្ថិភាពដាក់ឲ្យផុតពីដៃក្មេង និងជៀសវាងពីការបំផ្លាញ មិនត្រូវលាក់ទុកនៅកន្លែងណាមួយឡើយ ប៉ុន្តែត្រូវរក្សាទុកនៅកន្លែងណាដែលយើងអាចមើលឃើញជារៀងរាល់ថ្ងៃ និងធ្វើការត្រួតពិនិត្យនូវកម្រិតកម្ពស់ទឹកនីត្រូសែនជាប្រចាំ។

ជាចុងក្រោយ យើងត្រូវពិនិត្យមើលជាប្រចាំនូវគម្របដែលដាក់ចោល និងកំណក ឬញើសនៅលើធុងស្តុក។ យើងត្រូវប្រុងប្រយ័ត្នជាពិសេសលើភាពសមស្របនៃកធុង និងភាពសុញ្ញាកាស។ ភាពកំណកបង្ហាញថាមានការបាត់បង់ទ្រនាប់សុញ្ញាកាស និងទឹកនីត្រូសែនត្រូវបាននឹងកំពុងសាយភាយយ៉ាងរហ័ស។ ប្រសិនបើអ្នកសង្ស័យថាមានបញ្ហានេះកើតឡើង អ្នកត្រូវប្រើប្រាស់រំពាត់ឈើដើម្បីវាស់កម្រិតទឹកនីត្រូសែន។ ប្រសិនបើទឹកនីត្រូសែននៅមាននៅក្នុងធុងស្តុក អ្នកត្រូវផ្ទេរទឹកមេជីវិតទៅដាក់ក្នុងធុងល្អភ្លាមៗ។ ប្រសិនបើ ធុងស្តុកគ្មានទឹកនីត្រូសែន ឬយើងសង្ស័យថាទឹកមេជីវិតនៅរស់ ឬអត់ ដូច្នេះយើងត្រូវធ្វើការត្រួតពិនិត្យវាយតម្លៃទឹកមេជីវិតសិនមុននឹងយកទៅធ្វើការប្រើប្រាស់ក្នុងការបង្កាត់ពូជ។




## ១២. ការយកទឹកមេជីវិតមកប្រើប្រាស់

សីតុណ្ហភាពដែលគ្រោះថ្នាក់ចំពោះធុងស្តុកនីត្រូសែន ជាទូទៅ គឺស្ថិតនៅផ្នែកពាក់កណ្តាលខាងលើនៃកធុង។ នៅពេលយើងដកយកផ្នែកណាមួយនៃទឹកមេជីវិតមកប្រើប្រាស់ ឬផ្ទេរទឹកមេជីវិតពីធុងស្តុកមួយទៅធុងស្តុកមួយ ទឹកមេជីវិតតែងតែឆ្លងកាត់នូវកន្លែងដែលមានសីតុណ្ហភាពគ្រោះថ្នាក់នេះ។ ការខូចខាតទឹកមេជីវិតបណ្តាលមកពីកម្តៅមិនអាចវិលមកវិញបានទេ និងមិនអាចកែតម្រូវបានដោយយកទឹកមេជីវិតមកដាក់ក្នុងទឹកនីត្រូសែនបានឡើយ។

ដើម្បីកាត់បន្ថយការខូចខាតបណ្តាលមកពីកម្តៅយើងត្រូវ:

- កំណត់សម្គាល់ឡូតដែលដាក់ទឹកមេជីវិតដែលយើងចង់បាន។ ការធ្វើបញ្ជីទឹកមេជីវិតអាចជួយឱ្យយើងដឹងពីទីតាំងរបស់ទឹកមេជីវិតគោបានីមួយៗ និងជួយសម្រួលដោយមិនបាច់រុករកវានោះទេ
- ដកយកចេញនៅឡូតទឹកមេជីវិត ពីទីតាំងស្តុកទុកមកត្រឹមកណ្តាលធុងស្តុករួចលើកឡូតខ្ពស់ល្មមមកកន្លែងតំបន់កធុងដែលយើងអាចចាប់យកកំប៉ុងទឹកមេជីវិតដែលយើងចង់បាន ត្រូវរក្សាចំណុចខ្ពស់បំផុតនៃឡូតទឹកមេជីវិតកុំឱ្យខ្ពស់ជាងខ្សែចំហាយសន្សើមកំណក ឬរក្សាចុងនៃឡូតទឹកមេជីវិតមិនឱ្យខ្ពស់ជាងពី៥ទៅ៨សង់ទីម៉ែត្រពីមាត់ធុងស្តុក
- ចាប់យកកំប៉ុងទឹកមេជីវិត និងភ្លាមៗនោះត្រូវបន្ទាបឡូតទឹកមេជីវិតទៅទីតាំងដើមវិញ។ ត្រូវរក្សាកំប៉ុងទាបនៅក្នុងធុងស្តុកដែលអាចធ្វើទៅបាន នៅពេលដកយកទឹកមេជីវិត ដោយប្រើដង្កៀបគៀបចាប់យកចេញបំពង់មេជីវិត។ បំពង់មេជីវិតត្រូវចាប់យកចេញក្នុងរយៈពេលប្រមាណ១០នាទី
- បន្ទាប់ពីយកចេញនូវទឹកមេជីវិតហើយ ត្រូវដាក់កំប៉ុងទឹកមេជីវិតទៅរកទីតាំងស្តុកដូចដើមវិញ ដោយលើកឡូតដាក់ចូលកំប៉ុងរួចហើយបន្ទាបឡូតទៅរកទីតាំងស្តុកដូចដើមវិញ
- ជាធម្មតា យើងត្រូវចំណាយពេលលើសពី៨ទៅ១០វិនាទី ដើម្បីយកចេញនូវកំប៉ុងណាមួយ ហើយឡូតត្រូវបន្ទាបទៅរកកន្លែងដើមវិញ ដើម្បីឱ្យវាត្រជាក់ពេញលេញ។ កុំដាក់ចូលវិញនូវបំពង់ទឹកមេជីវិតដែលបានដកចេញពីកំប៉ុងរួចហើយ។




## ១៣. វិធីធ្វើឱ្យរំលាយទឹកមេជីវិត

វិធីធ្វើឱ្យរលាយទឹកមេជីវិតនៅក្នុងបំពង់ មានលក្ខណៈមិនដូចគ្នាទេ គឺអាស្រ័យទៅនឹងការអនុវត្តរបស់មជ្ឈមណ្ឌលបង្កាត់ពូជដោយសិប្បនិម្មិត។ ប៉ុន្តែបច្ចុប្បន្នភាគច្រើនគេអនុវត្តដោយប្រើប្រាស់ទឹកក្ដៅឧណ្ហៗដើម្បីរំលាយទឹកមេជីវិតក្នុងរយៈពេលពី១០ទៅ៦០វិនាទី។ ជាការល្អយើងគួរអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតទឹកមេជីវិត។ ចំណុចសំខាន់ៗក្នុងការរំលាយទឹកមេជីវិតមានដូចខាងក្រោម៖

- រក្សាឧបករណ៍បង្កាត់ពូជឱ្យបានស្អាត ស្ងួត និងក្ដៅឧណ្ហៗ
- ប្រើប្រាស់នូវឧបករណ៍វាស់ស្ទង់កម្ដៅឱ្យបានត្រឹមត្រូវ កុំប៉ាន់ស្មានកម្ដៅដោយភ្នែក ឬដោយការស្ទាបដោយគ្មានប្រដាប់វាស់ស្ទង់កម្ដៅ
- ត្រូវធ្វើការពិនិត្យមើលឧបករណ៍វាស់ស្ទង់ឱ្យបានត្រឹមត្រូវ និងសុក្រឹត ដោយធ្វើការប្រៀបធៀបជាមួយឧបករណ៍វាស់ស្ទង់កម្ដៅផ្សេងៗទៀត
- ត្រូវប្រើប្រាស់បំពង់ទឹកក្ដៅក្នុងការរក្សាទឹកក្ដៅ ដើម្បីរំលាយទឹកមេជីវិតដែលបានបង្កក។ បំពង់ទឹកមេជីវិតត្រូវដាក់ត្រាំក្នុងទឹកឱ្យបានសព្វ
- គួររំលាយបរិមាណស្ដែមទៅតាមតម្រូវការក្នុងពេលអនុវត្តការបង្កាត់ពូជម្ដងៗ
- ការរំលាយទឹកមេជីវិត ត្រូវអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិត ហើយប្រសិនបើគ្មានជម្រើសទេ យើងគួរត្រាំវាក្នុងទឹកក្ដៅឧណ្ហៗដែលមានសីតុណ្ហភាពពី៩០ទៅ៩៥អង្សាហ្វារ៉ែតក្នុងរយៈពេល៤០វិនាទីយ៉ាងតិច។



## ១៤. ការរក្សាទឹកមេជីវិតនៅពេលធ្វើការបង្កាត់

នៅក្នុងប្រទេសកម្ពុជាយើង ពុំមានការពិបាកក្នុងការគ្រប់គ្រងទឹកមេជីវិតដែលបានរំលាយហើយនោះទេ ពីព្រោះដោយសារសីតុណ្ហភាពបរិស្ថានជុំវិញប្រហាក់ប្រហែលទៅនឹងសីតុណ្ហភាពទឹកមេជីវិតដែលត្រូវរំលាយ។ លក្ខណៈនេះវាមិនបង្កឱ្យទឹកមេជីវិតងាប់ ឬខូចភ្លាមៗនោះទេ គឺការរំលាយទឹកមេជីវិតគួរធ្វើឡើងនៅក្នុងទីម្លប់ផងដែរ ពីព្រោះពន្លឺថ្ងៃអាចសម្លាប់មេជីវិតបាន។

ចំណុចគន្លឹះសំខាន់ៗខ្លះក្នុងការរៀបចំទឹកមេជីវិតមានដូចខាងក្រោម៖

- ត្រូវធ្វើការដុសចុងកាំភ្លើងបន្តិចក្នុងកំឡុងពេលដែលយើងធ្វើការរំលាយទឹកមេជីវិត។ ធ្វើដូច្នេះវានឹងធ្វើឱ្យសីតុណ្ហភាពចុងកាំភ្លើងក្ដៅឧណ្ហៗពេលយើងដាក់ទឹកមេជីវិតដែលបានរំលាយរួចចូលក្នុងកាំភ្លើង ដើម្បីធ្វើការបង្កាត់ពូជ
- ជូតសម្អាតបំពង់ទឹកមេជីវិតដែលរំលាយហើយឱ្យស្ងួតដោយប្រើប្រាស់ក្រដាសជូតទឹក

- តម្រូវការខ្យល់ក្នុងបំពង់ទឹកមេជីវិតដោយធ្វើយ៉ាងណាកុំឱ្យបាត់បង់ទឹកមេជីវិត នៅពេលដែលយើងកាត់ចុងបំពង់ទឹកមេជីវិត។ យើងអាចកាន់ចុងបំពង់ទឹកមេជីវិតខាងផ្នែកដែលមានសំឡីបញ្ឈរហើយផ្ទាត់ ឬបង្វិលកដៃថ្នមៗបន្តិច ដើម្បីខ្យល់នៅខាងក្នុងឡើងមកលើ
- ត្រូវដាក់ទឹកមេជីវិតដែលបានរំលាយរួច និងជូតស្អាតហើយទៅក្នុងកាំភ្លើង បន្ទាប់មកត្រូវប្រើប្រាស់នូវកន្ត្រៃមុតល្អកាត់ចុងបំពង់ទឹកមេជីវិត (ផ្នែកដែលគ្មានសំឡី) នៅកន្លែងដែលមានខ្យល់ ចំពោះការកាត់នេះត្រូវធ្វើយ៉ាងណាឱ្យបានស្មើល្អ ដើម្បីឱ្យស៊ីត្រូវគ្នាទៅនឹងចុងស្រោមប្លាស្ទិកកាំភ្លើង
- ត្រូវខ្ចប់កាំភ្លើងដែលបញ្ចូលទឹកមេជីវិតរួចដោយប្រើក្រដាសស្អាតជៀសវាងខាំនឹងមាត់ដែលអាចឱ្យប្រឡាក់ប្រឡូកនៅពេលដែលយើងកាន់យកទៅធ្វើការបង្កាត់។ ជាការល្អកន្លែងរៀបចំការរំលាយទឹកមេជីវិតគួរនៅជិតគោមេដែលត្រូវធ្វើការបង្កាត់
- ត្រូវធ្វើការបង្កាត់ពូជដោយទឹកមេជីវិតដែលបានរំលាយរួចក្នុងរយៈពេលប៉ុន្មាននាទីប៉ុណ្ណោះ បន្ទាប់ពីរំលាយហើយធ្វើយ៉ាងណាត្រូវធ្វើការបង្កាត់ឱ្យបានលឿនកាន់តែល្អ។ រយៈពេលចាប់ពីដកយកចេញទឹកមេជីវិតចេញពីធុងស្តុករហូតដល់ការបាញ់បញ្ចូលទឹកមេជីវិតមិនគួរឱ្យលើស១៥នាទីឡើយ។




## ១៥. ការផ្ទេរទឹកមេជីវិត

នៅពេលធ្វើការផ្ទេរទឹកមេជីវិតពីធុងស្តុក(បង្កក)មួយទៅធុងស្តុក(បង្កក)មួយទៀត យើងគួរចងចាំដូចខាងក្រោម:

- ត្រូវដាក់ធុងនៅជិតគ្នាដែលអាចធ្វើទៅបាន និងត្រូវធ្វើការបំពេញទឹកនីត្រូសែនមុននឹងធ្វើការផ្ទេរប្រសិនបើអាចធ្វើទៅបាន
- ត្រូវមានឡតសមស្របក្នុងធុងស្តុក(បង្កក)នីមួយៗនៅចំកណ្តាល
- ត្រូវធ្វើការផ្ទេរកំប៉ុងទឹកមេជីវិតយ៉ាងលឿន(ក្នុងរយៈពេល៣ទៅ៥វិនាទី)កុំប៉ះពាល់កំប៉ុងទឹកមេជីវិតដោយដៃទទេឡើយ។




## ១៦. ការផើមរបស់មេគោ

មេគោក្រោយពេលបង្កាត់ ឬដាក់បា ២១ថ្ងៃ បើមេគោនោះឈប់បង្ហាញសញ្ញានៃការរកឈ្មោល មានន័យថាមេគោនោះចាប់ផ្តើមមានគភ៌(ផើម)ហើយ ។ មេគោផើមមានរយៈពេល ៩ ខែ ១០-១៥ថ្ងៃ ទើបកូនកើតមកចេញមកក្រៅ។ ក្នុងកំឡុងពេលមេគោផើម មានន័យថាវាមិនរកឈ្មោលទៀតទេ ។

ក្នុងរយៈពេលមេគោផើម ត្រូវផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញសេចក្តីត្រូវការទាំងមេ និងកូនក្នុងផ្ទៃ។ ការផ្តល់ចំណីមិនប្រក្រតីអាចបណ្តាលឲ្យមេគោរលូតកូន ឬកូនក្នុងផ្ទៃលូតលាស់មិនល្អ។ ប៉ុន្តែកន្លងមកមានមេគោមួយចំនួនមិនរកឈ្មោល ឬដាក់ឈ្មោលមិនជាប់គឺដោយសារបណ្តាលមកពីការផ្តល់ចំណីមិនគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព កត្តាជំងឺដែលបណ្តាលឲ្យមានគ្រុនក្តៅខ្លាំង មានជំងឺប៉ារ៉ាសិតធ្ងន់ធ្ងរ ប្រដាប់បន្តពូជរបស់មេគោមិនប្រក្រតី មេគោមានជំងឺសរីរាង្គបន្តពូជ ជំងឺរលាកស្បូនរ៉ាំរ៉ៃ និងមានទទួលជំងឺរលូតកូន ។





## ១៧. ការចិញ្ចឹមមេគោបំបៅកូន

ការចិញ្ចឹមមេគោបំបៅកូនកន្លងមក នៅតាមផ្ទះកសិករតែងតែជួបនូវផលិតកម្មទាប ព្រោះនៅចន្លោះពេលមេគោឲ្យកូនបៅដោះក្នុងរយៈពេលយូរ កង្វះខាតចំណីទាំងបរិមាណ និងគុណភាព នៅពេលបំបៅកូន និងកង្វះខាតការថែទាំបំប៉នមេគោបំបៅកូន មេគោស្គមខ្លាំង ឬមានជំងឺផ្សេងៗ ដូចជាពពួកប៉ារ៉ាសិត។ ដើម្បីឲ្យមេគោឆាប់វិលទៅរកឈ្មោល យើងគប្បីផ្តល់ចំណីឲ្យមេគោបំបៅកូននូវចំណីដែលមានជីវជាតិ និងបរិមាណគ្រប់គ្រាន់ ជាពិសេសស្មៅពណ៌បៃតង កុំព្យាយាមឲ្យមេគោស៊ីចំបើងច្រើនពេក។ ត្រូវផ្លាស់ប្តូរទម្លាប់ការបំបៅកូនក្នុងរយៈពេលយូរឲ្យមកនៅរយៈពេលខ្លី ដើម្បីធ្វើយ៉ាងណាឲ្យមេគោឆាប់រកឈ្មោលឡើងវិញ ។





## ១៨. ការចិញ្ចឹមកូនគោ

កូនគោក្រោយពេលកើត ត្រូវបៅដោះមេ នៅពេលងើបឈរបាន ពីព្រោះទឹកដោះដំបូងមានសារៈសំខាន់ណាស់សម្រាប់ការលូតលាស់ និងការការពារសុខភាពកូនឲ្យមានភាពរឹងមាំ និងបង្កើតភាពស៊ាំ ដើម្បីការពារជំងឺផ្សេងៗ។ កូនគោកើតបានក្នុងរយៈពេល ១០ថ្ងៃដំបូង ត្រូវបៅដោះមេឲ្យបានគ្រប់គ្រាន់ មិនត្រូវលែងមេគោឲ្យទៅរកស៊ីចំណីនៅតាមវាលទេ ត្រូវផ្តល់ចំណីឲ្យមេគោនូវក្នុងទ្រុងឲ្យបានគ្រប់គ្រាន់។ ម្យ៉ាងទៀត ការដាក់ចំណីឲ្យមេគោនៅក្នុងទ្រុងហាក់ដូចជាជួយធ្វើឲ្យកូនគោរៀនស៊ី ចំណីដោយខ្លួនឯងមុនយើងធ្វើការផ្តាច់ដោះ។ ការផ្តាច់ដោះត្រូវធ្វើឡើងក្នុងកំឡុងពេល ៣ទៅ៥ខែ នៅពេលផ្តាច់ដោះកូនគឺមិនត្រូវផ្តាច់ភ្លាមតែម្តងនោះទេ។ នៅពេលថ្ងៃទី១ យើងត្រូវឲ្យកូនគោបៅដោះមេ ក្នុង១ថ្ងៃ ឲ្យបាន ២ដងគឺ នៅពេលព្រឹកម្តង និងពេលល្ងាចម្តង។ នៅថ្ងៃទី៥ យើងត្រូវឲ្យកូនគោបៅដោះមេក្នុង១ថ្ងៃ ឲ្យបាន ១ដងគឺ នៅពេលព្រឹករហូតដល់ថ្ងៃទី ១០ ទើបធ្វើការផ្តាច់ដោះឈប់ឲ្យបៅដោះតែម្តង។ ហើយយើងធ្វើរបៀបនេះកូនគោមិនបាក់។ ប៉ុន្តែនៅពេលផ្តាច់ដោះ កូនគោត្រូវឲ្យស៊ីចំណី និងទឹកគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព ។





# ជំពូកទី៣
# ចំណីសត្វ

## ១. កត្តាចំណី

ចំណីគឺជាកត្តាចាំបាច់សម្រាប់ការទ្រទ្រង់សរពាង្គកាយ ការលូតលាស់ និងផលិតកម្ម។ ដូច្នេះចំណីចាំបាច់ត្រូវមានទាំងបរិមាណ និងគុណភាព សម្រាប់ផ្តល់ឲ្យសត្វ។

### ១.១. ការផ្តល់ចំណី

គ្រប់សត្វទាំងឡាយមិនថាតែគោទេ គឺត្រូវការផ្តល់របបអាហារ និងទឹកឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់វា។ យើងដឹងហើយថាគោត្រូវការចំណីអាហារច្រើនប្រកបដោយគុណភាព ព្រោះតម្រូវការចំណីអាហាររបស់វាគឺគិតទៅតាមទម្ងន់ដងខ្លួនរបស់វា។ បើគោមានទម្ងន់ដងខ្លួន ១០០គីឡូក្រាម វាត្រូវការរបបចំណីអាហារប្រមាណ ១៥ គីឡូក្រាមក្នុង ១ថ្ងៃ និងស្មៅស្រស់ដែលមានគុណភាពជារៀងរាល់ថ្ងៃសម្រាប់ការលូតលាស់ និងការធំធាត់របស់វា។ ចំពោះមេគោបំបៅកូនវាត្រូវការចំណីទ្វេដង បើធៀបទៅនឹងមេគោមិនបំបៅកូន។ ដូច្នេះដើម្បីបង្កើនបរិមាណ និងគុណភាពចំណី កសិករត្រូវមានជម្រើសផ្សេងៗដូចជា៖

### ១.២. ការដាំដំណាំចំណីសត្វ

វិធីនេះ គឺមានភាពងាយស្រួលដើម្បីមានចំណីគ្រប់គ្រាន់ និងមានគុណភាពល្អអាចឲ្យគោលូតលាស់ឆាប់រហ័ស និងធំធាត់លឿន។ កន្លងមកមានប្រជាពលរដ្ឋមួយចំនួនបាននឹងកំពុងអនុវត្តលើការងារដាំដំណាំចំណីសត្វនេះសម្រាប់ផ្គត់ផ្គង់ចំណីអាហារដល់សត្វរបស់ពួកគាត់ ។

#### ក. ស្ថានភាពទូទៅដំណាំចំណីសត្វ

ជាទូទៅ បានបង្ហាញឱ្យឃើញថា ពូជដំណាំចំណីសត្វថ្មីៗជាច្រើនប្រភេទ ត្រូវបានគេនាំចូលពីបរទេសមកអនុវត្តចាប់តាំងពីកំឡុងឆ្នាំ១៩៦០មកម្លេះ ហើយមួយចំនួនមានដុះស្រាប់នៅក្នុងប្រទេសកម្ពុជា ដែលជាលក្ខណៈពូជធម្មជាតិ។ ចំណែកពូជដំណាំចំណីសត្វដែលបាននាំចូលមួយចំនួនត្រូវបានបាត់ទៅវិញ ដោយការមិនទទួលយកពីសំណាក់កសិករដោយហេតុថា ពួកគាត់មិនបានគិតដល់បរិមាណ គុណភាព និងលក្ខណៈសមស្របក្នុងការដុះលូតលាស់ ឬបន្សាំទៅនឹងអាកាសធាតុក្នុងស្រុក។ បច្ចុប្បន្នយើងសង្កេតឃើញមានតែជាង ១០ពូជប៉ុណ្ណោះ ដែលកសិករកំពង់ដំណើរការដាំរួមមានដូចជា៖

- **ម៉ារ៉ាន់ឌូ** ( Marandu)

ដំណាំចំណីសត្វដែលមានឈ្មោះថា ម៉ារ៉ាន់ឌូ (Brachiaria-Marandu) ជាប្រភេទស្មៅសម្រាប់ ផ្តល់ជាចំណីឱ្យគោ-ក្របី ដែលមានប្រភពដើមនៅប្រទេសហ្ស៊ីមបាវេ(Zimbawe) ហើយ ត្រូវបាននាំគ្រាប់ចូលមកប្រទេសកម្ពុជានៅឆ្នាំ ២០០៣ ដោយអង្គការ CIAT-LLSP និងបានដាំនៅក្នុងស្រុកចំនួន៤ក្នុងខេត្តកំពង់ចាម គឺស្រុកព្រៃឈរ ត្បូងឃ្មុំ កំពង់សៀម និងស្រុកពញាក្រែក។

ក្រោយមកត្រូវបាននាំគ្រាប់ចូលមកប្រទេសកម្ពុជានៅឆ្នាំ២០០៧ ដោយអង្គការACIAR, AH /2005/086 និងបានដាំនៅក្នុងស្រុកចំនួន៣ គឺស្រុកព្រៃឈរ ខេត្តកំពង់ចាម, ស្រុកស្អាង ខេត្តកណ្តាល និងស្រុកត្រាំកក់ ខេត្តតាកែវ។ បន្ទាប់មក មានការសាយភាយពូជនេះទៅតាមបណ្តាខេត្តផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា។ ដំណាំចំណីសត្វដែលមានឈ្មោះថា ម៉ារ៉ាឌូ ជាប្រភេទស្មៅដែលមានកម្ពស់ដើមជាមធ្យម ហើយមានលក្ខណៈពិសេសមួយចំនួនមានដូចខាងក្រោម៖

- ជាប្រភេទស្មៅដែលអាចដាំដុះលូតលាស់ល្អនៅលើដីមានជីជាតិមធ្យម និងដីដែលមានជីជាតិ ជាក់ស្តែងក្នុងការដាំនៅលើដីប្រភេទក្រហម (ក្រុមដីឡាបាសៀក) វាដុះលូតលាស់ល្អបំផុត ហើយដាំលើដីឥដ្ឋខ្មៅការដុះលូតលាស់របស់វាមានលក្ខណៈល្អបង្គួរ
- មានការធន់ទ្រាំទៅនឹងអាកាសធាតុក្តៅ ជាពិសេស គឺនៅរដូវប្រាំង ប៉ុន្តែមិនអាចដុះលូតលាស់លើដីជាំទឹកបានទេ
- មានដើមរឹង ស្លឹកវែងហើយនៅជុំវិញគែមស្លឹក និងផ្ទៃស្លឹកមានស្លាមជរៗ
- គេអាចពង្រីកការដាំដោយគ្រាប់, សាបកូន និងគល់ឬស ដាំនៅរដូវវស្សា
- ស្មៅប្រភេទនេះវាមានលក្ខណៈសមស្របទៅនឹងការដាំកាត់ផ្តល់ឱ្យសត្វស៊ី
- ការកាត់កំពស់ពីដីពី ៧-១០ស.ម
- ទិន្នផលពី៨-២០តោន/ហិកតា/ឆ្នាំ(ស្ងួត)
- លទ្ធផលស្រាវជ្រាវរបស់អ្នកឯកទេសផ្នែកដំណាំចំណីសត្វបង្ហាញថា ស្លឹករបស់វានៅអាយុ២សប្តាហ៍ មានកំហាប់អាសូត(N) ២.៥% មានកំរិតប្រូតេអ៊ីនប្រមាណ៨.៤៤% និងសារធាតុស្ងួតដែលអាចរលាយបាន (DM) digestibilyty ៧៥% ហើយវានឹងថយចុះជាងនេះនៅពេលវាមានអាយុលើសពីនេះ( L'tman-netje and R.M. Jones (Edtors)1992។




**មូឡាតូ២** Brachiaria hibrid CV Mulato ២

ពូជដំណាំចំណីសត្វប្រភេទមូឡាតូ២ ឈ្មោះពេញគឺ Brachiaria hibrid CV Mulato ២ ជាពូជបង្កាត់រវាង Ruziziensis X Brachiaria brizantha មានប្រភពពីប្រទេសកូឡុំប៊ី ដែលបានបង្កាត់ដោយCIAT,នាឆ្នាំ១៩៨៩។ វាជាប្រភេទស្មៅកូនកាត់មិនអាចផលិតគ្រាប់សម្រាប់ការដាំបានទេនៅប្រទេសកម្ពុជា ព្រោះវាជាពូជដំណាំចំណីសត្វដែលត្រូវបានគេធ្វើការបង្កាត់ពូជពីរផ្សេងគ្នា។ ពូជដំណាំចំណីសត្វនេះគេដាំសម្រាប់ជាចំណីគោ-ក្របី ចៀម និងពពែ។ ពូជនេះវាស្ថិតក្នុងក្រុមមានកម្ពស់ដើមជាមធ្យម ហើយលក្ខណៈពិសេសរបស់ពូជដំណាំចំណីសត្វ Mulato ២ នេះគឺ:

- ពូជដំណាំចំណីសត្វ(ស្មៅ) មូឡាតូ២ នេះបាននាំចូលមកធ្វើការដាំជាចំណីសត្វ ក្នុងឆ្នាំ២០០៣ ដោយគម្រោង CIAT-LLSP និងនៅឆ្នាំ២០០៧ គម្រោងACIAR, AH/2005/086 បានដាំនៅក្នុងស្រុក ចំនួន៣ គឺស្រុកព្រៃឈរ ខេត្តកំពង់ចាម, ស្រុកស្អាង ខេត្តកណ្តាល និងស្រុកត្រាំកក់ ខេត្តតាកែវ
- ជាប្រភេទស្មៅធន់ទ្រាំបំផុតទៅនឹងសីតុណ្ហភាពក្តៅ(រដូវក្តៅ)
- ជាប្រភេទពូជស្មៅមានសារធាតុអង់ទីប៊ីយ៉ូទិក អាចការពារជំងឺបង្កឡើងដោយផ្សិត និងចៃ
- ស្មៅប្រភេទនេះវាមានលក្ខណៈសមស្របទៅនឹងការដាំកាត់ផ្តល់ឱ្យសត្វស៊ី
- ពូជស្មៅប្រភេទនេះមានគុណភាពល្អជាងពពួកស្មៅដទៃទៀត
- ពូជស្មៅប្រភេទនេះអាចផលិតគ្រាប់បាននៅក្នុងតំបន់មានរយៈកម្ពស់ខ្ពស់ដូចជាប្រទេសឡាវ

- ពង្រីកការដាំដុះនាពេលបច្ចុប្បន្ន ត្រូវគេអនុវត្តដោយប្រើប្រាស់គ្រាប់ពូជ, សាបកូន និងការបំបែកគល់ឬស ដោយដាំនៅរដូវវស្សាដែលមានទឹកស្រោចស្រពគ្រប់គ្រាន់
- ជាប្រភេទស្មៅដែលអាចដាំដុះលូតលាស់ល្អនៅលើដីមានជាតិអាស៊ីត និងដីមានជីជាតិមធ្យម ប៉ុន្តែវាត្រូវការជីបន្ថែមដើម្បីលូតលាស់ល្អ
- ជាប្រភេទពូជដំណាំចំណីសត្វប្រភេទនេះ មានដើមខ្លីមធ្យម មានស្លឹកច្រើន ហើយទន់ និងមានរោមច្រើន សត្វចូលចិត្តស៊ី
- ជាប្រភេទពូជមានលទ្ធភាពបែកគុម្ពធំ កូនច្រើន និងសំបូរខ្នែងអាចបំបែកយកទៅដាំបាន។
- ការកាត់កម្ពស់ពីដីពី ៧-១០ស.ម
- ទិន្នផលពី១០-២៧តោន/ហិកតា/ឆ្នាំ (ស្ងួត)

តាមលទ្ធផលស្រាវជ្រាវរបស់អ្នកឯកទេសផ្នែកដំណាំចំណីសត្វបង្ហាញថា ស្លឹករបស់វានៅអាយុ ២សប្តាហ៍មានកំហាប់អាសូត(N) ២.៥% មានកម្រិតប្រូតេអ៊ីនប្រមាណ៧.៨០%(៧.០-១៦.០ %) សារធាតុសោះទឹក ១៦.១១% និងសារធាតុស្ងួតដែលរលាយបាន(DM digestibilyty ៧0% ហើយវានឹងថយចុះជាងនេះនៅពេលវាមានអាយុលើសពីនេះ។




## ហ្គាមបា ( Gamba )

ជាប្រភេទដំណាំចំណីសត្វ (ស្មៅ) ស្ថិតក្នុងក្រុម អាគ្រូប៉ូហ្គុន ហ្គាយានូស ( Andropo gon gayanus)។ ពូជដំណាំចំណីសត្វប្រភេទនេះត្រូវបានគេនាំយកគ្រាប់មកដាំនៅប្រទេសកម្ពុជានៅឆ្នាំ២០០៣ ដោយគម្រោង LLSP-CIAT។ ជាប្រភេទដំណាំចំណីសត្វសម្រាប់ផ្តល់ឱ្យគោ-ក្របី ចៀម និងពពែគ្រប់វ័យ។ ជាស្មៅដែលមានដើម និងស្លឹកតូចវែងមានរោមច្រើន ហើយទន់។ ជាទូទៅតាមការវាយតម្លៃពីកសិករដែលបានដាំបញ្ជាក់ថា សត្វគោ-ក្របីចូលចិត្តស៊ី ពូជស្មៅប្រភេទនេះជាងគេ បើធ្វើការប្រៀបធៀបទៅនឹងពេលវានៅខ្ចីដូចគ្នា។ ចំពោះលក្ខណៈពិសេសរបស់ពូជដំណាំចំណីសត្វប្រភេទនេះមានដូចខាងក្រោម៖

- ពូជដំណាំចំណីសត្វប្រភេទនេះ វាអាចមានលទ្ធភាពដុះលូតលាស់លើដីគ្រប់ប្រភេទ រួមទាំងដីមានជាតិអាស៊ីតដែលមិនសូវសំបូរជីជាតិផងដែរ
- វាមានភាពធន់ទៅនឹងភាពរាំងស្ងួតរយៈពេលវែង និងអាកាសធាតុក្តៅ
- ប្រភេទដំណាំចំណីសត្វនេះ បើសិនជាដាំនៅប្រទេសកម្ពុជាគឺ វាមានសមត្ថភាពសម្រាប់ផលិតយកគ្រាប់ពូជបានល្អបង្គួរ ប៉ុន្តែគ្រាប់របស់វានៅពេលទុំងាយនឹងជ្រុះចេញពីទងដែលធ្វើឱ្យយើងមានការលំបាកក្នុងការប្រមូលផល
- ត្រូវបានគេដាំដោយប្រើគ្រាប់ សាបកូន និងដាំដោយរំលែកដើមក្នុងគុម្ពក្នុងរដូវវស្សាក៏បាន ហើយសមស្របទៅនឹងការដាំសម្រាប់កាត់ផ្តល់ឱ្យសត្វស៊ី

- មានកម្រិតលូតលាស់ល្អបង្គួរ លក្ខណៈអន់របស់វាគឺ ឆាប់ឡើងដើម និងមានផ្កាច្រើន គុម្ពរបស់វាឆាប់ថ្កោល ដូចនេះយើងត្រូវធ្វើការរំលែកដាំវាញឹកញាប់ជាងប្រភេទដំណាំចំណីសត្វប្រភេទផ្សេងៗទៀត។

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ជាមធ្យមនៅក្នុងស្លឹករបស់វាមានកម្រិតអាសូត(N)២.៥% និងកម្រិតសារធាតុស្ងួតរលាយ (DM diagestibility) ៦០%ពេលវានៅខ្ចីក្នុងរដូវវស្សា ហើយវានឹងថយចុះនៅពេលដើមរបស់វាចាស់ជាពិសេសនៅរដូវប្រាំង។




**បាស៊ីលីស Basilisk ឬ ស៊ីកណាល់** ( Signal Grass Brachiaria Decumbens)

ពូជដំណាំចំណីសត្វប្រភេទ បាស៊ីលីស ឬស៊ីកណាល់ ជាប្រភេទស្មៅមានដើមទាប ហើយវាជា ប្រភេទស្មៅសមស្របសម្រាប់ដាំលែងសត្វឱ្យចូលស៊ី និងអាចដាំសម្រាប់ច្រូតកាត់ផ្តល់ឱ្យសត្វស៊ី។

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ បាននាំចូលមកដាំនៅប្រទេសកម្ពុជាក្នុងកំឡុងពីឆ្នាំ១៩៨៧ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ក្នុងខេត្តតាកែវ។ ពិនិត្យជាទូទៅវាជាប្រភេទដំណាំចំណីសត្វ(ស្មៅ)ដែលមានលទ្ធភាពដុះលូតលាស់នៅលើដីស្ទើរតែគ្រប់ប្រភេទរួមទាំងដីដែលមិនសំបូរជីជាតិផងដែរ លក្ខណៈពិសេសរបស់ប្រភេទដំណាំចំណីសត្វ(ស្មៅ)នេះមានៈ

- ជាប្រភេទស្មៅដែលមានអាយុកាលវែងបង្គួរអាចធន់ទៅនឹងរដូវរាំងស្ងួត (រដូវប្រាំង)
- ប្រភេទស្មៅនេះការដុះលូតលាស់ល្អ ហើយក្រាស់ ដើមរបស់វាតូចឆ្មារ ស្លឹកទន់ល្មម សត្វចូលចិត្តស៊ីដំណាំចំណីសត្វប្រភេទនេះណាស់
- ត្រូវបានគេធ្វើការដាំដោយប្រើគ្រាប់ក្នុងកំរិត៤-១០គ.ក្រ/ហិកតា ជំរៅកប់គ្រាប់ ២ស.ម
- ដាំដោយរំលែកឬបំបែកដើមក្នុងគុម្ពមានការដុះលូតលាស់លឿន និងងាយស្រួលក្នុងការថែទាំជាងការដាំដោយប្រើគ្រាប់។

ដំណាំចំណីសត្វប្រភេទ បាស៊ីលីស ឬស៊ីកណាល់ ជាប្រភេទស្មៅភាគច្រើនដួលនៅរដូវ វស្សា ហើយការដួលនេះបណ្តាលឱ្យវារលួយស្លឹកមួយចំនួនដែលជាហេតុនាំឱ្យសត្វមិនសូវស៊ី។ ដូចនេះនៅរដូវវស្សាយើងគួរខឧស្សាហ៍កាត់បន្តិចជៀសវាងការដួល។ តាមការអង្កេតរបស់អ្នកបច្ចេកទេសបានឱ្យដឹងថា ជាទូទៅពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ វាចាប់ផ្តើមផ្តល់ផលទាបនៅឆ្នាំទី៣ និងឆ្នាំទី៤។ ហេតុដូច្នេះ យើងគួរតែរៀបចំធ្វើការដាំឡើងវិញ ដោយប្រើប្រាស់ដើមគល់ចាស់ ឬបំបែកកូនក្នុងគុម្ពរបស់វានៅរដូវវស្សាទើបជាការល្អ ដើម្បីងាយស្រួលក្នុងការថែទាំ។ ដំណាំចំណីសត្វប្រភេទបាស៊ីលីស ឬស៊ីកណាល់ ការដាំដើម្បីផលិតយកគ្រាប់ពុំបានផលល្អទេ ចំពោះពូជដែលយើងបាននឹងកំពុងធ្វើការដាំនៅប្រទេសកម្ពុជា។ ដូចនេះដើម្បីធ្វើការពង្រីកការដាំ ឱកាសល្អពង្រីកការដាំបន្តគឺ ការបំបែកកូនក្នុងគុម្ព និងធ្វើការបំបែកដើមគល់ចាស់ជាមធ្យោបាយមួយដ៏ប្រសើរបំផុត។






**ហ្គីណេ-ស៊ីមួង** ( Guinea-Panicum Maximum-Simuang )

ដំណាំចំណីសត្វប្រភេទហ្គីណេ-ស៊ីមួង (Panicum Maximum-Simuang)(ស្មៅ)នេះជាចំណីសម្រាប់គោ-ក្របី ចៀម ពពែ សេះ ដែលមានគុណភាពល្អ។ ដំណាំចំណីសត្វប្រភេទ ហ្គីណេ-ស៊ីមួង (Panicum Maximum-Simuang) ត្រូវបាននាំចូលពីប្រទេសកូតឌីវ័រ មកដាំនៅប្រទេសកម្ពុជាក្នុងកំឡុងឆ្នាំ១៩៨៦ ដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានដាំសម្រាប់ ផ្តល់ឱ្យគោពូជនៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ តែកំឡុងពេលនោះគឺមិនទាន់ត្រូវបានធ្វើការផ្សព្វផ្សាយ ដល់ជួរកសិករនៅឡើយ។ បន្ទាប់មក ដំណាំចំណីសត្វប្រភេទហ្គីណេ-ស៊ីមួង (Panicum Maximum-Simuang)នេះ ក្នុងកំឡុងឆ្នាំ១៩៩៨ ត្រូវបានអង្គការ CAAEP នាំមកដាំ និងបានធ្វើការផ្សព្វផ្សាយពូជនេះជាលើកដំបូងដល់កសិករ។ បច្ចុប្បន្ន ពូជដំណាំចំណីសត្វប្រភេទ ហ្គីណេ-ស៊ីមួង (Panicum Maximum-Simuang) បាននាំចូលមកបន្តទៀតដោយ CIAT-LLSP និងACIAR, AH/2005/086 និងបានធ្វើការដាំផ្សព្វផ្សាយតាមគ្រួសារកសិករនៅខេត្តកណ្តាល, ខេត្តតាកែវ, ខេត្តកំពង់ចាម និងមានការសាយភាយទៅតាមបណ្តាស្រុកក្នុងខេត្តផ្សេងៗមួយចំនួនទៀតនៃប្រទេសកម្ពុជា។

ពូជដំណាំចំណីសត្វប្រភេទហ្គីណេ-ស៊ីមួង (Panicum Maximum-Simuang) នេះជាពូជស្មៅដែលមានដើមខ្ពស់រហូតដល់ទៅកម្ពស់ ១ម៉ែត្រ សមស្របទៅនឹងការដាំសម្រាប់កាត់ផ្តល់ឱ្យសត្វស៊ី។ លក្ខណៈពិសេសរបស់ប្រភេទដំណាំចំណីសត្វ(ស្មៅ)នេះមានៈ

- វាមានទម្រង់ដើម ស្លឹកប្រហាក់ប្រហែលនឹងដើមស្រូវ ឬដើមស្លឹកគ្រៃ តែគល់របស់វា មានព័ណ៌ស្វាយ
- ជាប្រភេទដំណាំចំណីសត្វ(ស្មៅ) ដែលសំបូរស្លឹកច្រើន មានធាងវែង និងមានការដុះលូតលាស់បែកគុម្ពធំក្នុងលក្ខខណ្ឌសមស្រប
- វាអាចដាំបាននៅលើដីដែលមានជីជាតិល្អ និងមធ្យម
- គេអាចធ្វើការដាំដោយគ្រាប់ សាបកូន និងរំលែកឬបំបែកដើមក្នុងគុម្ពដាំ មានការដុះលូតលាស់លឿន និងងាយស្រួលក្នុងការថែទាំជាងការដាំដោយប្រើគ្រាប់។ ករណីព្រួសគ្រាប់ត្រូវប្រើប្រាស់គ្រប់ប្រមាណ៥គ.ក្រ/ហិកតា។

ចំពោះការដាំសម្រាប់ផលិតយកគ្រាប់ ពូជដំណាំចំណីសត្វ(ស្មៅ) ប្រភេទនេះ វាផ្តល់ផលគ្រាប់ បានល្អ ប៉ុន្តែវាពិបាកក្នុងការប្រមូលផល ដោយសារតែគ្រាប់របស់វាមាន សភាពតូច ហើយងាយជ្រុះចេញពីទងរបស់វា។

ពូជដំណាំចំណីសត្វប្រភេទហ្គីណេ-ស៊ីមួង (Panicum Maximum-Simuang)នេះមាន ការដុះលូតលាស់លឿនជាងប្រភេទពូជដំណាំចំណីសត្វផ្សេងៗដទៃទៀតនៅរដូវវស្សា តែកម្រិតនៃការធន់ទៅនឹងរដូវរាំងស្ងួតមធ្យម។ ជាទូទៅវាឆាប់ស្រពោនស្លឹកនៅរដូវប្រាំងក្តៅខ្លាំង។ ចំពោះទិន្នផលពូជដំណាំចំណីសត្វនេះស្ងួតប្រមាណពី១៩-៣០ តោន/ហិកតា/ឆ្នាំ និងស្លឹកវានៅខ្ចីមានកម្រិតប្រូតេអ៊ីន ១៣.៣៣% (ចន្លោះពី ១១.០-១៦.០%) មានកម្រិតជាតិ អាសូត(N) ជុំវិញ២% និងកម្រិតសារធាតុរលាយ។




- **តេរ៉េណូស** ( Panicum atratum - Terenos )

ពូជដំណាំចំណីសត្វប្រភេទ(ស្មៅ)នេះមានច្រើនប្រភេទដូចជា ប៉ាស្ពាលូម ឌីឡាតាទូម (Paspalum dilatatum) ប៉ាស្ពាលូម ណូតាទូម (Paspalum notatum) ប៉ាស្ពាលូម ឌីស្ទិកជូម (Paspalum distichum) និងប៉ាស្ពាលូម អាត្រាទូម (Paspalum atratum) ដែលមានប្រភពមកពីប្រទេសប្រេស៊ីល ហើយបាននាំចូលមកដាំនៅប្រទេសកម្ពុជា ក្នុងកំឡុងឆ្នាំ ២០០៤ ដោយគម្រោង CIAT-LLSP និងកំឡុងឆ្នាំ២០០៧ ដោយគម្រោង ACIAR, AH/2005/086 ដែលបានអនុវត្ត នៅក្នុងខេត្តតាកែវ, កណ្តាល និងខេត្តកំពង់ចាម និងមានការសាយភាយតាមបណ្តាស្រុកក្នុងខេត្តផ្សេងៗមួយចំនួនទៀត នៃប្រទេសកម្ពុជា។

ពពួកដំណាំចំណីសត្វប្រភេទនេះ ជាប្រភេទស្មៅបែកគុម្ពដូចស្រូវ និងស្លឹករ៉ៃគ្រែ មានដើមពណ៌បៃតងខ្ចី ស្លឹករឹង ទៅតាមអាយុកាល កម្ពស់របស់វារហូតដល់ទៅពី ៦០-៨០ស.ម។ គេអាចធ្វើការដាំលើដីមានជីជាតិមធ្យម នៅតំបន់ ត្រជាក់ វាត្រូវការទឹកច្រើន ធន់នឹងកន្លែងសើម ជាំទឹក ប៉ុន្តែវាមិនអាចធន់ទៅនឹងអាកាសធាតុក្តៅស្ងួតទេ។ លក្ខណៈ ពិសេសរបស់ដំណាំចំណីសត្វប្រភេទនេះគឺ:

- ជាប្រភេទស្មៅដែលមានកម្ពស់ដើមមធ្យម និងមានលក្ខណៈសមស្របដាំនៅតំបន់ទំនាបកណ្តាល
- ជាការល្អគេអាចធ្វើការដាំនៅកន្លែងទាបដែលមានដក់ទឹកតិចតួចក្នុងរយៈពេលខ្លី
- ត្រូវការទឹកស្រោចស្រពខ្ពស់(ច្រើន)ជាងប្រភេទដំណាំចំណីសត្វប្រភេទផ្សេងទៀត ក្នុងករណីផ្តល់ទឹកគ្រប់គ្រាន់វា ដុះលូតលាស់លឿន ជាពិសេសនៅរដូវវស្សា តែវាមិនសូវសមស្របទៅនឹងរដូវប្រាំងដែលមានរយៈពេលវែងដូច នៅប្រទេសកម្ពុជា ដែលមានរដូវប្រាំងរហូតដល់ទៅ ៦ខែនោះទេ
- ភាគច្រើនដុះលូតលាស់លើដីខ្សត់ជីជាតិ ជីជាតិមធ្យម និងដីមានជាតិអាស៊ីតផងដែរ
- សម្បូរស្លឹក ហើយស្លឹករបស់វាមានសភាពទន់ល្អនៅអាយុ ៤៥-៦០ថ្ងៃ ស្លឹករបស់វាប្រែរឹងលឿនទៅតាមអាយុ កាលរបស់វា
- ទិន្នផលស្ងួតពី ១២-២៦តោន/ហិកតា/ឆ្នាំ

ជាទូទៅ វាមានកម្រិតប្រូតេអ៊ីនប្រមាណ៧.៨១% កម្រិតអាសូត០.៨%-២% កម្រិតសារធាតុរលាយពី ៣៩%-៦០% ហើយមានការប្រែប្រួលទៅតាមអាយុរបស់វា និងទៅតាមប្រភេទដីនៅកន្លែងដាំ។ (L'tmannetje and R.M. jones (Editors)១៩៩២) វាជាចំណីសម្រាប់គោ-ក្របី ចៀម ពពែ ហើយផ្តល់នូវការលូតលាស់បង្គួរ។






- **រូស៊ី** ( Brachiaria Ruziziensis )

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ មានដើមកំណើតនៅប្រទេសអាហ្វ្រិក ប៊ូរុនឌី រ៉ាវ៉ាន់ដា ហ្សាអៀរ។ល។ វាជាប្រភេទដំណាំចំណីសត្វ(ស្មៅ) មានស្លឹកច្រើន ស្លឹករបស់វាទន់ មានរោម ស្លឹកនីមួយៗមានទទឹង១.៥មម និងបណ្ដោយ ២៥សម ដើមរបស់វាមានលក្ខណៈស្មើរពាក់កណ្ដាលវារ (លូន) ពាក់កណ្ដាលឈរ និងមានកម្ពស់មធ្យម។ លក្ខណៈពិសេសរបស់វាមានដូចខាងក្រោម៖

- ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ អាចដុះលូតលាស់នៅក្នុងតំបន់មានអាកាសធាតុក្ដៅ
- អាចដាំបាននៅលើដីមានជីជាតិមធ្យម និងដីមានជីជាតិល្អ វាក៏អាចដុះលូតលាស់នៅលើដីដែលមានគុណភាពទាបបានដែរ ហើយវាអាចលូតលាស់បានយ៉ាងល្អ ប្រសើរនៅលើដីទីទួល និងផ្ទៃដីមានខ្សែទឹកហូរ
- វាធន់ទៅនឹងភាពរាំងស្ងួតបានប្រសើរនារដូវប្រាំង ហើយវាធន់ទៅនឹងការចូលទន្ទ្រានរបស់សត្វបាន ប៉ុន្តែវាមិនអាចធន់ទៅនឹងអាកាសធាតុរាំងស្ងួតហួតហែង និងទឹកជំនន់បានឡើយ
- អាចផ្ដល់ទិន្នផលគ្រាប់បានច្រើន ហើយអត្រាដុះមានកម្រិតខ្ពស់ ជាហេតុធ្វើឱ្យងាយស្រួលក្នុងការដាំពង្រីកពូជដោយប្រើប្រាស់គ្រាប់។

ជាទូទៅ ដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ជាប្រភេទស្មៅដែលមានគុណភាពខ្ពស់មានកម្រិតប្រូតេអ៊ីនប្រមាណ ១៣-២០% កម្រិតអាសូត (N) ២% កម្រិតសារធាតុរលាយរហូតដល់ពី៥៥%-៧៥% ដែលអាចប្រមូលផលស្រស់បានប្រមាណ១០០-១២៥តោន/ហិកតា/ឆ្នាំ ឬទិន្នផលស្ងួតប្រមាណ ២០-២៥តោន/ហិកតា/ឆ្នាំ។ ប៉ុន្តែ ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះអាចមានវិបត្តិខ្លះដែរ គឺមានរយៈមួយដែលវាត្រូវសម្រាកខ្លួន ឬទ្រឹងមិនធ្វើការលូតលាស់នៅក្នុងរដូវប្រាំង ទោះបីជាមានការផ្ដល់ទឹក និងធ្វើការដាក់ជីគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏វាមិនត្រូវបានផ្ដល់នូវទិន្នផល នៅរដូវរាំងស្ងួតនោះបានដែរ ទាំងនោះជាហេតុធ្វើឱ្យមានការខ្វះខាតចំណីអាហារសត្វមួយរយៈពេលដែលជាហេតុធ្វើឱ្យអ្នកដាំមានការលំបាកក្នុងការសម្រេចចិត្តក្នុងការជ្រើសរើសពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ យកទៅអនុវត្តក្នុងការដាំ។






**ហាមីល** ( Panicum maximum-Hamil )

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ មានប្រភពមកពីប្រទេសអាយវ៉ូរីខស (Ivoricost) ជាប្រភេទស្មៅមានដងដើមខ្ពស់ គល់វាព៌ណ៌ស និងមានស្លឹកច្រើន ស្លឹករបស់វាមានផាងវែង ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទសនេះ អាចដាំនៅលើដីមានជីជាតិមធ្យម និងដីមានជីជាតិល្អ ការ លូតលាស់របស់វាបានល្អ ហើយវាអាចបន្សាំទៅនឹងតំបន់ជាំទឹក និងសមស្របសម្រាប់ធ្វើការដាំនៅតំបន់ដែលមានប្រព័ន្ធធារាសាស្ត្រល្អ ព្រមទាំងសមស្របទៅនឹងការផ្តល់ទឹក និងជីបានល្អ តែវាក៏ធន់ទៅនឹងភាពរាំងស្ងួត និងអាចដុះលូតលាស់បានក្នុងទីម្លប់ផងដែរ។ ការពង្រីកពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ត្រូវបានគេដាំដោយប្រើប្រាស់គ្រាប់ សាបកូនដាំ និងគល់ឬស។ ការប្រមូលផល សមស្របក្នុងការច្រូតកាត់ និងធ្វើការលែងឱ្យសត្វស៊ី។ ចំពោះការកាត់ យើងត្រូវធ្វើការកាត់កម្ពស់ពីដីប្រមាណ៧-១០សម។ ជាទូទៅ ដំណាំចំណីសត្វ(ស្មៅ)ប្រភេទសនេះ ជាប្រភេទស្មៅដែលមានគុណភាពខ្ពស់ មានកម្រិតប្រូតេអ៊ីន ប្រមាណ៨% កម្រិតអាសូត (N) ២% កម្រិតសារធាតុរលាយរហូតដល់ពី៥៥%-៧៥% ដែលអាចប្រមូលផល ឬទិន្នផលស្ងួតប្រមាណពី ១៥.៥-១៩តោន/ហិកតា/ឆ្នាំ។




**ពូជស្មៅដំរី - ស្តេចស្មៅ** (Elephan-King Grass)

ពូជដំណាំចំណីសត្វ (ស្មៅ) ប្រភេទនេះ ជាពូជស្មៅមួយប្រភេទដែលស្ថិតក្នុងក្រុមអំបូរនេពារ (Napier Grass) វាមានប្រភពដើមមកពីទ្វីបអាហ្វ្រិក និងបាននាំមកដាំនៅតំបន់អាស៊ីភាគអាគ្នេយ៍។ ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ បាននាំចូលមកដាំនៅប្រទេសកម្ពុជានៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅនាឆ្នាំ២០០០ ដោយលោក **គង់ សារិន** ជាប្រធានស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល និងត្រូវបានធ្វើការផ្សព្វផ្សាយ និងចែកចាយពូជទូទាំងប្រទេសចាប់ពីពេលនោះមក។ ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះវាជាចំណីសម្រាប់សត្វទំពារអៀង ជាពិសេសសម្រាប់ផ្តល់ឱ្យសត្វគោ-ក្របី និងពេលខ្លះដើមរបស់វានៅខ្ចីៗគេអាចយកទៅចិញ្ច្រាំនឹងផ្តល់ជាចំណីបន្ថែមសម្រាប់ជ្រូក មាន់ និងត្រីបានផងដែរ។ វាជាប្រភេទស្មៅដែលមានដើមធំៗដូចដើមត្រែង និងដើមអំពៅ ជាពិសេសស្លឹករបស់វាទន់ល្អ មានរសជាតិផ្អែមនៅផ្នែកបណ្តូលនៃដើមរបស់វាពេលមានអាយុ៤០ថ្ងៃក្រោយពេលដាំ។ វាអាចមានកម្ពស់ប្រមាណ១ម៉ែត្រ ដុះលូតលាស់លឿន និងអាចមានកម្ពស់រហូតដល់ទៅ ៤ម៉ែត្រ។ គេអាចប្រមូលផលរៀងរាល់៣០-៤០ថ្ងៃម្តង និងអាចរស់បានរហូតដល់ទៅ០៧ឆ្នាំ។ វាជាប្រភេទដំណាំចំណីសត្វដែលលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដាំដុះស្ទើរគ្រប់ប្រភេទដី។ តាមការអនុវត្តជាក់ស្តែងបានសង្កេតឃើញថា វាដុះបានល្អនៅលើប្រភេទដីល្បាប់ខ្សាច់ និងដីល្បាប់តាមមាត់ទន្លេ ឬនៅតាមស្ថានភាពដីមានជាតិអាស៊ីត ប៉ុន្តែវាត្រូវការពន្លឺថ្ងៃ។ កម្ពស់ទឹកភ្លៀងប្រមាណ៨០០មម សមស្របធ្វើការដាំនៅតំបន់ត្រូពិច និងស៊ុបត្រូពិច មានការដុះលូតលាស់បានល្អ និងមិនត្រូវការប្រើប្រាស់ថ្នាំបាញ់កម្ចាត់សត្វល្អិតនោះទេ។

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ការពង្រីកនៃការដាំដុះដោយប្រើប្រាស់ដើមដូចការដាំដំណាំអំពៅ ហើយវាងាយនឹងដុះលូតលាស់បានល្អ ព្រោះដំណាំចំណីសត្វប្រភេទនេះវាជាប្រភេទដំណាំបែកខ្នែងល្អ ជាពិសេសក្រោយពេលធ្វើការកាត់លើកទី១ ខ្នែងរបស់វាអាចមានលទ្ធភាពបែកបានពី២០-៣០ដើមក្នុង១គុម្ព។ ប្រការដែលត្រូវចងចាំដើម្បីឱ្យ

គុណភាពរបស់វាធានាក្នុងការកាត់ផ្តល់ឱ្យសត្វស៊ីបានល្អ យើងគប្បីចាំបាច់ត្រូវបន្ថែមនូវជីដល់ដំណាំចំណីសត្វនេះឱ្យបានរៀងរាល់នៅពេលធ្វើការកាត់ម្តង ដើម្បីបំពេញតម្រូវការលូតលាស់របស់វាឡើងវិញ និងផ្តល់គុណភាពសម្រាប់កាត់ផ្តល់ឱ្យសត្វស៊ី ជាពិសេសគឺ ជីលាមកសត្វ។ ជាងនេះទៅទៀត គឺយើងត្រូវធ្វើការកាត់វាផ្តល់ជាចំណីសត្វមិនត្រូវទុកឱ្យដើមចាស់ ឬដើមខ្ពស់នោះទេ ព្រោះដើមរបស់វាឡើងរឹងចាស់ធ្វើឱ្យសត្វពិបាកខាំបំបែកស៊ី។

ជាទូទៅដំណាំចំណីសត្វ (ស្មៅ) ប្រភេទនេះ ជាប្រភេទស្មៅដែលមានគុណភាពខ្ពស់ មានកម្រិតប្រូតេអ៊ីនប្រមាណ១២-១៥% កម្រិតអាសូត (N) ២-៤% មានជាតិទឹកប្រមាណ៧០% និងកម្រិតសារធាតុរលាយរហូតដល់ពី ៧០%-៧៥% ដែលអាចចាត់ទុកថាជាប្រភេទចំណីដែលមានអាហារូបត្ថម្ភខ្ពស់សម្រាប់ការលូតលាស់ធំធាត់របស់សត្វ ប៉ុន្តែកម្រិតនៃសារធាតុទាំងនេះនឹងមានការថយចុះយ៉ាងលឿនពាក់ព័ន្ធទៅនឹងអាយុរស់ (L.'tmannetje and R.M.jones (Editors)។

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ អាចប្រមូលទិន្នផលរហូតដល់៣៥០តោនស្រស់/ហិកតា/ឆ្នាំ និងប្រមាណ ១០០ហិកតា/ឆ្នាំ ក្នុងករណីដាំលើដីមានជីជាតិ និងការផ្តល់ទឹកគ្រប់គ្រាន់។



**ខ. ពពួកលេហ្គឹម** (Legume)

- **ស្តាយឡូ ១៨៤** (Stylo 184)

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ជាប្រភេទដំណាំចំណីសត្វស្ថិតក្នុងប្រភេទលេហ្គឹម ឬអាចហៅបានថាជាពពួកឃាសជាតិអំបូរសណ្តែក។ ដំណាំចំណីសត្វប្រភេទនេះ មានប្រភពមកពីប្រទេសកូឡុំប៊ី(Columbia)ត្រូវបាននាំមកដាំនៅប្រទេសកម្ពុជា ក្នុងកំឡុងឆ្នាំ១៩៨៦ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ សម្រាប់ប្រើប្រាស់ជាចំណីគោ ហើយមិនត្រូវបានធ្វើការផ្សព្វផ្សាយនោះទេ។ ប្រភេទដំណាំចំណីសត្វនេះ ត្រូវបានដាំសម្រាប់ផ្តល់ឱ្យសត្វទំពារអៀង ជាពិសេស ជាសម្រាប់ជ្រូក មាន់ និងត្រីផងដែរ។ នៅក្នុងកំឡុងឆ្នាំ១៩៩៧-១៩៩៨ បានណែនាំឱ្យប្រើ និងផ្សព្វផ្សាយដល់កសិករនៅតាមបណ្តាខេត្តទូទាំងប្រទេសមុនគេដែលអនុវត្តដោយគម្រោង CAAEP សហការណ៍ជាមួយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ លក្ខណៈពិសេសដំណាំចំណីសត្វប្រភេទនេះរួមមាន:

- អាចដាំនៅស្ទើរគ្រប់ប្រភេទដី ដូចជាដីមានជីជាតិល្អ មធ្យម ដីមិនសូវសម្បូរជីជាតិ និងដីមានជាតិអាស៊ីត ប៉ុន្តែវាមិនត្រូវការនូវប្រភេទដីមានជាតិអាស៊ីតខ្ពស់ពេកនោះទេ
- ធន់ទៅនឹងរដូវប្រាំងយូរ ប៉ុន្តែក្នុងករណីដីមានជីជាតិ និងសើមវាអាចដុះលូតលាស់ល្អ
- ដំណាំចំណីសត្វប្រភេទនេះអាចដាំបានល្អដោយប្រើគ្រាប់ ហើយគ្រាប់ត្រូវការត្រាំទឹកក្តៅប្រមាណ ៨០អង្សាសេ ក្នុងរយៈពេល៣-៥នាទី និងសំដិលវាក្រោមម្លប់ឱ្យស្ងួតជាមុនសិន ទើបយកទៅដាំ
- ដំណាំចំណីសត្វប្រភេទនេះ ត្រូវបានគេដាំដោយពង្រោះលើផ្ទៃដីទាំងអស់ ឬ ដាំជាជួរដោយធ្វើការឆ្លុតជាចង្អូរឆ្លាស់ជាមួយស្មៅ ឬដាំនៅចន្លោះដំណាំផ្សេងៗ

- ដើមវាមានកម្ពស់ប្រមាណពី ៣០-៤០សម ជាប្រភេទដើមវៀរ ឬឈរមានស្លឹកតូចៗ
- គេអាចច្រូតកាត់ផ្តល់ឱ្យសត្វស៊ីស្រស់ៗ ឬអាចហាលស្លឹកវាសម្រាប់ផលិតជាម្សៅកន្ទក់ផ្តល់ឱ្យសត្វ
- ត្រូវកាត់កម្ពស់ពីដីប្រមាណពី១៥-២០សម ព្រោះដំណាំចំណីសត្វប្រភេទនេះ វាបែកមែកតាមថ្នាំងនៃដើមរបស់វា។

ជាទូទៅ ដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ជាប្រភេទស្មៅផ្តល់គុណភាពខ្ពស់ដែលអាចប្រមូលផលស្រស់បានប្រមាណ៦៥-១០០តោន/ហិកតា/ឆ្នាំ ឬទិន្នផលស្ងួតប្រមាណ ១៣-២០តោន/ហិកតា/ឆ្នាំ មានកម្រិតប្រូតេអ៊ីនប្រមាណ ១៥.៥៥% (១១.០-១៩.០%) កម្រិតអាសូត (N) ១.៥-៣% កម្រិតសារធាតុរលាយ(DMdigestibility) រហូតដល់ ៦០%-៧០% ពេលស្លឹកដើមរបស់វានៅខ្ចី ហើយកម្រិតនេះនឹងមានការប្រែប្រួលទៅតាមអាយុ និងទីកន្លែងដាំ។




**សិនត្រូសេម៉ា** ( Centrosema Pascuorum CV. Cavalcade )

ពូជដំណាំចំណីសត្វ(ស្មៅ)ប្រភេទនេះ ជាប្រភេទដំណាំចំណីសត្វស្ថិតក្នុងប្រភេទលេហ្គីមអំបូរសណ្តែក។ ដំណាំចំណីសត្វប្រភេទនេះមានលក្ខណៈជាវល្លិ៍ ស្លឹករបស់វាផែកជាបី មានរាងតូចវែង និងមានស្លឹកច្រើនជាងដើម នៅពេលច្រូតកាត់ហាលស្ងួតស្លឹករបស់វាមិនងាយរង្គោះធ្លាក់ចេញពីដើមរបស់វាឡើយ។ ហេតុដូចនេះទើបដំណាំចំណីសត្វប្រភេទនេះគឺសមស្របទៅនឹងការប្រើប្រាស់ជាដុំស្មៅស្ងួតសម្រាប់រក្សាទុកផ្តល់ឱ្យសត្វស៊ីនៅរដូវខ្សត់ចំណី។ ចំពោះការពង្រីកនៃការដាំដុះ ដំណាំចំណីសត្វប្រភេទនេះ គឺធ្វើការពង្រីកការដាំដុះដោយប្រើប្រាស់គ្រាប់ ចំពោះបរិមាណគ្រាប់ពូជដែលត្រូវប្រើប្រាស់គឺ ២៥គីឡូក្រាម/ហិចតា ដោយធ្វើការរោយគ្រាប់ជាជួរដែលមានចន្លោះជួរពី២៥-៥០ស.ម ប្រសិនបើដីមានគុណភាពអន់ត្រូវដាំឱ្យញឹក តែបើដីមានគុណភាពល្អត្រូវដាំរង្វើលបន្តិចៗ។ រដូវសមស្របក្នុងការដាំដុះគឺធ្វើឡើងនៅដើមរដូវភ្លៀងធ្លាក់ ហើយក៏មិនឱ្យលើសពីខែសីហាឡើយ ព្រោះដំណាំចំណីសត្វប្រភេទនេះមានការលូតលាស់យឺតបន្តិចនៅដំណាក់កាលដំបូង។ មុនពេលដាំ ត្រូវរៀបចំដីដោយធ្វើការភ្ជួររាស់ដីឱ្យបានពី ២-៣ដង រួចដាក់ជីទ្រាប់បាតរណ្តៅដោយប្រើជីគីមី ឬជីលាមកសត្វដើម្បីបង្កើនគុណភាពដីសម្រាប់ការដុះលូតលាស់។ បន្ទាប់ពីដាំដុះរួច ត្រូវធ្វើការកម្ចាត់ពពួកស្មៅរំខាន(ស្មៅចង្រៃ)លើកដំបូងពេលវាមានអាយុប្រមាណ៣-៤សប្តាហ៍ ឬត្រូវធ្វើការសម្អាតជាបន្តបន្ទាប់នៅពេលសង្កេតឃើញថាមានពពួកស្មៅរំខាន(ស្មៅចង្រៃ)មានដុះរំខានដល់ដំណាំចំណីសត្វប្រភេទនេះនៅឡើយ។

ការប្រមូលផលត្រូវបានអនុវត្តនៅពេលវាមានអាយុ ចាប់ពី៦០-៩០ថ្ងៃ បន្ទាប់ពីការដាំរួច និងអាចប្រមូលផលបន្តបន្ទាប់ទៀត គឺរៀងរាល់ ៤៥-៦០ថ្ងៃ។ ដំណាំចំណីសត្វប្រភេទនេះ គេអាចច្រូតឱ្យសត្វស៊ីស្រស់ៗ ឬអាចហាលឱ្យស្ងួតសម្រាប់រក្សាទុកឱ្យសត្វស៊ីនៅរដូវខ្សត់ចំណី។ ត្រូវច្រូតកម្ពស់ពីផ្ទៃដីប្រមាណពី១៥-២០សម ព្រោះដំណាំចំណីសត្វប្រភេទនេះវាបែកមែកតាមថ្នាំង នៃដើមរបស់វា។ យើងអាចប្រមូលផលបានពី២-៣ដង ដោយម្តងៗទទួលទិន្នផលបានប្រមាណពី១.៩-៣តោន/ហិចតានៃទម្ងន់ស្ងួត ហើយអាចប្រើជាចំណីសត្វមានដូចជា: គោ-ក្របី ចៀម ពពែ សេះ ដំរី។ ដំណាំចំណីសត្វប្រភេទនេះ មានគុណភាពល្អ និងមានប្រូតេអ៊ីនប្រមាណពី ១៤-១៨% ហើយសត្វចូលចិត្តស៊ី។ ម្យ៉ាងទៀត ដំណាំចំណីសត្វប្រភេទនេះ សមស្របដាំសម្រាប់ធ្វើពូជ ព្រោះវាអាចចេញផ្កា និងដាក់គ្រាប់នៅខែវិច្ឆិកា ហើយផ្លែ

របស់វាទុំនៅពាក់កណ្ដាលខែធ្នូ។ ចំណែកចំបើង(ដើមស្ងោ) ដែលសល់ពីប្រមូលផលគ្រាប់រួច អាចមានប្រូតេអ៊ីនប្រមាណពី៧-៩% ដែលអាចប្រមូលយកទៅរក្សាទុកឱ្យសត្វស៊ីបាន។



**អារ៉ាឈីស** គឺជារុក្ខជាតិប្រភេទលេហ្គឹមដែលអាចប្រើប្រាស់ជាចំណីសត្វ ហើយដំណាំចំណីសត្វប្រភេទនេះភាគច្រើនកសិករដាំសម្រាប់លម្អសួននៅតាមផ្ទះ ព្រោះវាមានផ្កាពណ៌លឿងខ្ចីស្រស់។ អារ៉ាឈីសមានពីរប្រភេទគឺ Arachis pintoi និង Arachis glabrata ហើយប្រភេទទាំង ២នេះ វាមានគុណសម្បត្តិផ្សេងៗគ្នាមានដូចខាងក្រោមៈ

- ពពួក Arachis pintoi គឺជាអំបូរ Amarillo វាជាប្រភេទដំណាំចំណីសត្វដែលធន់ និងលូតលាស់ល្អ ផ្ដល់ទិន្នផលខ្ពស់ក្នុងតំបន់ក្ដៅ និងពាក់កណ្ដាលក្ដៅ ហើយស្លឹករបស់វាមានរាងស្រដៀងមូលដូចស្លឹកសណ្ដែកដី ចំពោះដើមរបស់ដំណាំចំណីសត្វប្រភេទនេះ មានលក្ខណៈវៀរលើផ្ទៃដីមានផ្កាពណ៌លឿងខ្ចី និងគ្រាប់(មើម)នៅក្នុងដី មានឬសកែវវែងរឹងមាំ និងអាចដុះលូតលាស់គ្រប់សណ្ឋានដី ជាពិសេស គឺវាធន់ទៅនឹងដីមិនសូវសម្បូរជីជាតិ ប៉ុន្តែដីដែលមានជាតិអាស៊ីតវាក៏អាចដុះលូតលាស់បានជាមធ្យម ប៉ុន្តែមិនអាចដាំដុះលើដីមានជាតិប្រៃ ឬជាតិបាសខ្លាំងឡើយ។ តែទោះបីជាយ៉ាងណាក៏ដោយដំណាំចំណីសត្វប្រភេទនេះអាចដុះលូតលាស់ល្អបំផុតនៅលើដីស្រួយស្អិតដែលមានគុណភាពល្អ និងមានភាពស្រស់បំព្រងពេលមានកម្ពស់ទឹកភ្លៀងធ្លាក់ជាមធ្យមច្រើនជាង ១៨០០ម.ម/ឆ្នាំ ប៉ុន្តែមិនអាចធន់ទៅនឹងទឹកជំនន់ និងទឹកដក់យូរបានឡើយ។ ដំណាំចំណីសត្វប្រភេទនេះ ធន់ទ្រាំបានក្នុងការជាន់ទន្រ្ទាំរបស់សត្វ និងព្រមទាំងអាចដុះនៅក្នុងទីម្លប់។ ចំពោះការដាំពង្រីកពូជអាចធ្វើទៅបានដោយប្រើប្រាស់គ្រាប់និងកំណាត់ដើមវល្លិរបស់វា។
- ពពួក Arachis glabrata គឺជាពូជដែលផ្ដល់ទិន្នផលខ្ពស់ មានសណ្ឋានស្លឹកវែង និងចង្អៀត មានផ្កាពណ៌លឿងចាស់ និងពាក់កណ្ដាលឈរ ហើយបែកមែកច្រើន ធន់ទៅនឹងភាពរាំងស្ងួតបានជាមធ្យម។ វាអាចដុះលូតលាស់បានលើផ្ទៃដីដែលមានកម្ពស់ទឹកភ្លៀងធ្លាក់ជាមធ្យម ៩០០ម.ម/ឆ្នាំ។ ប៉ុន្តែដំណាំចំណីសត្វប្រភេទនេះមានគ្រាប់តិច។ ដូច្នេះក្នុងការដាំពង្រីកពូជ គឺតម្រូវឱ្យប្រើប្រាស់ដើមវល្លិចាស់។ ជាទូទៅវាអាចផ្ដល់ទិន្នផលគិតទម្ងន់ស្ងួតប្រមាណពី៦-១២,៥តោន/ហិកតា/ឆ្នាំ មានប្រូតេអ៊ីនពី១៥-២១% ហើយសមស្របសម្រាប់ព្រលែងសត្វឱ្យចូលដើរស៊ីនៅក្នុងចម្ការស្មៅបាន។

ចំពោះការពង្រីកនៃការដាំដុះ ដំណាំចំណីសត្វប្រភេទនេះ គឺធ្វើការពង្រីកការដាំដុះដោយប្រើប្រាស់គ្រាប់ ចំពោះបរិមាណគ្រាប់ពូជដែលត្រូវប្រើប្រាស់គឺ ១២,៥-២៥ គីឡូក្រាម/ហិកតា ដោយធ្វើការរោយគ្រាប់ជាជួរដែលមានចន្លោះជួរពី២៥-៥០ស.ម ។ រដូវសមស្រប ក្នុងការដាំដុះ គឺធ្វើឡើងនៅដើមរដូវភ្លៀងធ្លាក់ ហើយក៏មិនឱ្យលើសពីខែសីហាដែរ ដោយហេតុថាដំណាំចំណីសត្វប្រភេទនេះមានការលូតលាស់យឺតបន្តិចនៅដំណាក់កាលដំបូង។ មុនពេលដាំ ត្រូវរៀបចំដី

ដោយភ្ជួររាស់ដីឱ្យបានពី ២-៣ដង រួចដាក់ជីទ្រាប់បាតរណ្តៅ ប្រើជីគីមី ឬជីលាមកសត្វដើម្បីបង្កើនគុណភាពដីសម្រាប់ការដុះលូតលាស់។ បន្ទាប់ពីដាំដុះរួច ត្រូវកម្ចាត់ពពួកស្មៅរំខាន(ស្មៅចង្រៃ)លើកដំបូងពេលវាមាន អាយុប្រមាណ ៣-៤សប្តាហ៍ ឬត្រូវ ធ្វើការសម្អាតជាបន្តបន្ទាប់នៅពេលសង្កេតឃើញថាមានពពួកស្មៅរំខាន(ស្មៅចង្រៃ)ទាំងនេះ។ ការប្រមូលផលត្រូវបានអនុវត្តនៅពេលវាមានអាយុចាប់ពី៧០-៩០ថ្ងៃ បន្ទាប់ពីការដាំរួច និងអាចប្រមូលផលបន្តបន្ទាប់ទៀត រៀងរាល់ ៣០-៤៥ថ្ងៃ។ គេអាចច្រូតកាត់ផ្តល់ឱ្យសត្វស៊ីស្រស់ៗ ឬអាចហាលឱ្យស្ងួតសម្រាប់រក្សាទុកផ្តល់ឱ្យសត្វស៊ីនៅរដូវខ្សត់ចំណី ឬព្រលែងឱ្យសត្វចូលស៊ីតែម្តងក៏បាន។ ត្រូវធ្វើការច្រូតកាត់កំពស់ពីផ្ទៃដីប្រមាណពី១៥-២០សម ព្រោះដំណាំចំណីសត្វប្រភេទនេះវាបែកមែកតាមថ្នាំងនៃដើមរបស់វា។ អាចប្រើជាចំណីសត្វដូចជា: គោ-ក្របី ចៀម ពពែ សេះ និងជ្រូក។



## ✦ គ្លីរីស៊ីដ្យា

ដំណាំចំណីសត្វប្រភេទនេះជារុក្ខជាតិដំណាំចំណីសត្វដែលមានដើមកំណើតនៅប្រទេសហ្គាតេម៉ាឡា (Guatemala) អាមេរិកឡាទីន (Nitis et al. ១៩៩១) ជាពូជប្រភេទពពួកលេហ្គីមដើមឈើមួយដែលផ្តល់ស្លឹក ច្រើនសម្រាប់ជាចំណីសត្វទូទៅស្លឹករបស់វាសមស្របសម្រាប់ផ្តល់ជាចំណីសត្វពពែ ចៀម និងអាចធ្វើជាចំណីគោ-ក្របី តែវាមិនសូវល្អសម្រាប់ផ្តល់ជាចំណីសត្វដែលមានក្រពះទោលនោះទេ។ ពូជដំណាំចំណីសត្វប្រភេទនេះត្រូវបាននាំមក ដាំនៅតំបន់អាស៊ី និងនៅស្ទើរគ្រប់ខេត្តនៅក្នុងប្រទេសកម្ពុជា។ លក្ខណៈពិសេសរបស់ពូជដំណាំចំណីសត្វប្រភេទនេះគឺ៖

- ជារុក្ខជាតិមានកម្ពស់រហូតដល់ទៅ១០ម បែកមែកសាខា ជារុក្ខជាតិពហុប្រយោជន៍ដាំធ្វើជារបងរស់ យកអុស យកធ្វើជាម្លប់ ការពារដី ស្លឹករបស់វាអាចយកធ្វើជាជីស្រស់(Walpola B.C, Arunakumara KKIU, ២០០៩) និងជាចំណីសត្វ
- ងាយស្រួលពង្រីកនៃការដាំគឺ ដាំដោយប្រើប្រាស់គ្រាប់ និងកាត់មែក
- វាអាចដុះលូតលាស់នៅលើដីច្រើនសណ្ឋាន ធន់នឹងភាពរាំងស្ងួត(Alan Robertson, ១៩៩៨)មិនធន់ជាមួយស្ថានភាពដីដក់ទឹក ឬដីលិចទឹករយៈពេលយូរបានទេ
- អាចដាំបាននៅលើដីមានជីជាតិមធ្យម ឬដីមានជាតិអាស៊ីតខ្សោយ
- ជារុក្ខជាតិបែកខ្នែងច្រើន ដុះលូតលាស់លឿន ដោយផ្តល់ស្លឹក និងត្រួយយ៉ាងច្រើន ប្រសិនបើយើងធ្វើកាត់វាបានត្រឹមត្រូវ ហេតុផលទាំងនេះ ទើបគេកាត់មែក ឬដើម ដាំជា
- របងរស់ ឬដាំវាជារង ជាគុម្ពដើម្បីប្រមូលផលស្លឹក និងមែកខ្ចីៗសម្រាប់ធ្វើជាចំណីសត្វ
- គេអាចប្រមូលផលក្នុងរយៈពេល៦០-៩០ថ្ងៃម្តងនៅរដូវវស្សាអាចផ្តល់ស្លឹកបានច្រើន តែវាតែងជ្រុះស្លឹកនៅរដូវប្រាំង ក៏ប៉ុន្តែករណីឧស្សាហ៍កាត់មែក ស្លឹករបស់វានឹងដុះលូតលាស់បន្តបន្ទាប់គ្រប់រដូវ។

• ស្លឹករបស់វាជាធម្មតាមានក្លិនក្រពុលឈ្ងួលៗដែលជាហេតុធ្វើឱ្យសត្វមិនចង់ស៊ី ពេលកាត់មកភ្លាម ប៉ុន្តែយើងអាចកាត់យកមកហាលថ្ងៃមួយស្របក់ឱ្យវាស្រពាប់ទើបផ្តល់ឱ្យសត្វស៊ីជាការល្អ។

ថ្វីត្បិតតែវាងាយស្រួលក្នុងការពង្រីកការដាំក៏ដោយ ក៏ប៉ុន្តែរុក្ខជាតិនេះវាក៏ងាយទទួលរងនៅសត្វល្អិតបំផ្លាញ និងងាយទទួលរងនូវជំងឺផងដែរ។

ជាទូទៅ ពូជដំណាំចំណីសត្វប្រភេទនេះត្រូវបានផ្តល់ឱ្យសត្វស៊ីដោយលាយជាមួយស្មៅឬចំបើងក្នុងកម្រិត១ភាគ៣ ដើម្បីជាការបង្រៀនសត្វឱ្យចេះស៊ី និងដើម្បីឱ្យសត្វទទួលបាននូវអាហាររូបត្ថម្ភតាមរយៈស្លឹកស្រស់ផងដែរ។ ស្លឹកពូជដំណាំចំណីសត្វប្រភេទនេះ មានកម្រិតប្រូតេអ៊ីនប្រមាណ ២០-២៥% កម្រិតអាសូតប្រមាណ ៣-៥% និងមានសារធាតុស្ងួតដែលរលាយ ស្ថិតក្នុងចន្លោះពី ៤៨-៧៧% ( Werner W.Stur and Peter M.Home)។



**គ. ពពួកលេហ្គឹមដើមឈើ** ( Tree Legume)

**ក្រថុំថេត** ( ឌី ផុន ២០០០) **ឬក្តម្ពតេស** (វចនានុក្រមខ្មែរ ១៩៦៧) (Leucaena)

ដំណាំចំណីសត្វប្រភេទនេះ ជាប្រភេទដើមឈើ មានដើមកំណើតដុះនៅទ្វីបអាមេរិក ហើយត្រូវបានគេនាំមកដាំនៅតំបន់អាស៊ីភាគអាគ្នេយ៍តាំងពីយូរយារណាស់មកហើយ។ ដំណាំចំណីសត្វប្រភេទនេះមានប្រភេទពូជខុសៗគ្នាជាច្រើនតែវាស្ថិតក្នុងគ្រួសារតែមួយ ហើយត្រូវបានគេចាត់ថ្នាក់ជាដំណាំចំណីសត្វស្ថិតក្នុងពពួកលេហ្គឹមដើមឈើដែលមានកម្ពស់ពី២-៨ម ជាប្រភេទរុក្ខជាតិបន្លែ និងត្រូវបានប្រើប្រាស់ជាពហុប្រយោជន៍ ព្រោះកសិករទម្លាប់ ដាំវាធ្វើជារបងនៅជុំវិញដីភូមិ និងដីចម្ការ ដើមរបស់វាយកធ្វើជាអុសដុតធ្វើជាធ្យូង ស្លឹក និងត្រួយខ្ចីៗត្រូវបានគេយកធ្វើជាបន្លែ អន្លក់សម្រាប់មនុស្ស បរិភោគ និងជាចំណីសត្វ ចំពោះផ្លែរបស់វាអាចហូបបាន ហើយមានសារជាតិអាចទម្លាក់ព្រូនមូលបាន។ ចំពោះពូជដែលមានដាំនៅប្រទេសកម្ពុជា មាន២ប្រភេទគឺ ពូជក្នុងស្រុក និងពូជនាំចូលមួយចំនួនដូចជា គ៥៨៤ និង គ៦៣៦ ជាពូជមានលទ្ធភាពក្នុងការផលិតស្លឹកបានច្រើនជាងពូជក្នុងស្រុក ប៉ុន្តែវាផលិតគ្រាប់ពូជបានតិច តែចំពោះពូជក្នុងស្រុកវាផលិតគ្រាប់បានល្អជាងពូជនាំចូល តែវាផលិតស្លឹកបានតិចជាងពូជនាំចូល។

បច្ចុប្បន្នដោយមានការកែប្រែប្រព័ន្ធចំណីសត្វ ដំណាំចំណីសត្វប្រភេទនេះ ត្រូវបានគេចាត់ជាចំណីសត្វដែលមានលក្ខណៈល្អប្រសើរ ជាពិសេសសម្រាប់សត្វ គោ-ក្របី ពពែ ជ្រូក និងមាន់ ក៏ប៉ុន្តែចំពោះសត្វជ្រូកអាចផ្តល់ឱ្យវាស៊ីក្នុងកម្រិតតិចតួច ព្រោះស្លឹករបស់វាមានជាតិពុលម្យ៉ាងឈ្មោះ មីណូស៊ីន (Minosine) វាអាចធ្វើឱ្យពុល ឬបង្កបញ្ហាដល់សត្វដែលមានក្រពះទោល (Werner W.stur and Peter M.Home)។ លក្ខណៈពិសេសរបស់ដំណាំចំណីសត្វប្រភេទនេះដូចខាងក្រោម៖

• ជួយបង្កើនគុណភាពដី ទាំងផ្នែកគីមី និងជីវសាស្ត្រ ដោយធ្វើឱ្យដីសម្បូរនីត្រូសែន ប៉ូតាស្យូម ដែក C,N,P ហើយចំនួនសត្វជន្លេនក៏មានការកើនឡើង (B. Lalljee, S. Facknath and A.M. Osman,១៩៩៨)
• ជាប្រភេទដំណាំចំណីសត្វ ដែលអាចប្រើប្រាស់គ្រាប់ផ្ទាល់ ឬបណ្តុះកូនដាំ
• អាចដុះលូតលាស់ល្អនៅលើដីជាំទឹក ដីមានជាតិអាស៊ីត

• មានអាយុកាលវែងមានដើមខ្ពស់ ទំហំដើមធំ និងមានស្លឹកព័ណ៌បៃតងខ្ចីជានិច្ចគ្រប់រដូវ ប្រសិនបើធ្វើការកាត់មែករបស់វាឱ្យបានត្រឹមត្រូវ។

ជាទូទៅ ដំណាំចំណីសត្វប្រភេទនេះ ស្លឹកវាមានសារធាតុប្រូតេអ៊ីន រហូតដល់២៥-៣១% ( H. M. Shelton, ១៩៨៨) មានសារធាតុរ៉ែរហូតដល់ ៤.៩-៨.៦% នៃសារធាតុស្ងួត (S.A. Dalzell et at, ១៩៨៨) មានសារធាតុអាសូតក្នុងស្លឹកពី ៣-៤% និងមានសារធាតុរលាយពី៦០-៧០%។

ដំណាំចំណីសត្វប្រភេទនេះ បានផ្តល់ទិន្នផលស្លឹកស្រស់ប្រមាណ៥៧ តោន/ឆ្នាំ/ហិកតា នៅឆ្នាំដំបូង ឬផ្តល់ស្លឹកស្ងួតប្រមាណ៨.៥តោន/ឆ្នាំ/ហិកតា (Tu Quang Hien and Nguyen ThiLien, ១៩៩៨) ឬ ២.៥ តោន/ឆ្នាំ/ហិកតា សារធាតុស្ងួតករណីដាំនៅលើមិន សម្បូរជីជាតិ (P. Argenti and F. Espinoza, ១៩៨៨)។





## ទ្រីចាន់ធីរ៉ា ( Trichanthera )

**ទ្រីចាន់ធីរ៉ា** (Trichanthera) ជាប្រភេទរុក្ខជាតិដើមឈើ មានប្រភពដើមនៅប្រទេសកូឡុំប៊ី(Columbia) និងប្រទេសវេណេស៊ុយអេឡា (Venezuela) ត្រូវបានគេដាំធ្វើជារបងនៅជុំវិញដីភូមិ និងដីចំការ។ ដំណាំចំណីសត្វប្រភេទនេះបានដាំសម្រាប់ធ្វើការពិសោធន៍សាកល្បងនាំមកដាំនៅប្រទេសវៀតណាមសម្រាប់ធ្វើជាចំណីសត្វ និងបាននាំចូល មកដាំនិងផ្សព្វផ្សាយនៅប្រទេសកម្ពុជាតាំងពីក្នុងកំឡុងឆ្នាំ១៩៩៤។

**ទ្រីចាន់ធីរ៉ា** (Trichanthera) ត្រូវបានប្រើប្រាស់សម្រាប់ជាចំណីសត្វ សមស្របសម្រាប់ផ្តល់ជាចំណីគោ-ក្របី ពពែ ចៀម ជ្រូក និងមាន់ ទា។ល។ វាអាចដុះលូតលាស់ល្អនៅលើដីដែលមានជីជាតិ និងមានសំណើមខ្ពស់ ងាយស្រួលក្នុងការដាំ ដោយគ្រាន់តែកាត់មែកជាកង់ៗយកមកផ្សាំ ឬកាត់មែកយកទៅដាំតែម្តងក៏បាន។ យើងអាចដាំដុះនៅក្នុងចំការចេក ខ្នុរ បើទោះបីវាស្ថិតនៅក្រោមម្លប់ក៏ដោយគឺវាអាចរស់បាន។ ចំពោះទិន្នផលពូជដំណាំចំណីសត្វនេះ អាចផ្តល់ទិន្នផលប្រមាណពី៦-១២តោន /ហិកតា/ឆ្នាំ(ស្ងួត)។

ជាទូទៅ ប្រភេទដំណាំចំណីសត្វ មែកខ្ចីៗ និងស្លឹករបស់វាមានប្រូតេអ៊ីនប្រមាណ១៨% ដែលអាចត្រូវបានគេយកជំនួសប្រូតេអ៊ីនទទួលបានពីម្សៅត្រី និងម្សៅសណ្តែកសៀងសម្រាប់ផ្សំ ជាចំណីជ្រូក មាន់ និងទា ក្នុងគោលបំណងកាត់បន្ថយតម្លៃចំណី ដោយសារតែម្សៅត្រី សណ្តែក សៀងមានតម្លៃខ្ពស់។





## ២. បច្ចេកទេសដាំដំណាំចំណីសត្វ

ដើម្បីទទួលបានភាពជោគជ័យក្នុងការដាំដំណាំចំណីសត្វ និងជួយជំរុញឱ្យបានទៅដល់គោលដៅមួយយ៉ាងពិតប្រាកដ គឺមានកត្តាសំខាន់ជាច្រើនត្រូវយកចិត្តទុកដាក់នូវវិធីសាស្ត្រមួយចំនួនដូចជាៈ ការជ្រើសរើសទីតាំង ការរៀបចំដី ការជ្រើសរើស និងការរៀបចំពូជ ការរៀបចំសម្ភារៈដាំដុះ យល់ដឹងពីបច្ចេកទេសដាំដុះ ការថែទាំ ការគ្រប់គ្រង និងការប្រមូលផល។

### ក. ការជ្រើសរើសទីតាំង

ជាទូទៅការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅប្រទេសកម្ពុជា មានការជួបប្រទះផលលំបាកខុសៗគ្នា គឺវាអាស្រ័យទៅតាមតំបន់ ដែលក្នុងនោះតំបន់មួយចំនួនអំណោយផលដល់ការចិញ្ចឹមសត្វដោយមានសណ្ឋានដីមានលក្ខណៈធំទូលាយ ហើយសំបូរទៅដោយធនធានចំណីជាលក្ខណៈធម្មជាតិ និងតំបន់មួយចំនួនទៀតមិនអំណោយផលដល់ការចិញ្ចឹមសត្វដោយហេតុថាសណ្ឋានដីមានលក្ខណៈតិចតួច ហើយមិនសូវសម្បូរធនធានចំណីជាលក្ខណៈធម្មជាតិដែលធ្វើឱ្យជះឥទ្ធិពលដល់ការចិញ្ចឹមសត្វ។ ដូចនេះ តំបន់ដែលយើងគួរចាប់ផ្តើមបំផុស ឬធ្វើការផ្សព្វផ្សាយឱ្យមានការដាំដំណាំចំណីសត្វ គឺតំបន់ដែលមានការចិញ្ចឹមសត្វច្រើនប្រឈមនឹងការខ្វះចំណី ជាតំបន់ផ្ទៃដីវាលស្មៅធម្មជាតិតិច ជាតំបន់សម្បូរទៅដោយវាលទំនាបសម្រាប់ធ្វើការដាំដំណាំ ឬវាលស្រែ និងជាតំបន់បាត់បង់នូវតុល្យភាពរវាងចំនួនសត្វ និងបរិមាណចំណីដែលត្រូវផ្តល់ឱ្យសត្វ។ ជាពិសេសក្នុងពេលបច្ចុប្បន្នកំពុងកើតមានការលំបាកយ៉ាងធ្ងន់ធ្ងរនៅតំបន់មួយចំនួននៅតំបន់វាលទំនាប ដោយហេតុថាតំបន់នោះមានការពង្រីកផ្ទៃដីដាំដុះដំណាំកសិកម្មធំធេងធ្វើឱ្យវាលស្មៅត្រូវបានរួមតូចដែលជះឥទ្ធិពលដល់ដំណើរការក្នុងការចិញ្ចឹមសត្វ។

#### ការកំណត់លក្ខណៈដីសម្រាប់ដាំដំណាំចំណីសត្វ

ការកំណត់ប្លង់ដីសម្រាប់ធ្វើការដាំដំណាំចំណីសត្វឱ្យបានសមស្រប គឺជាផ្នែកមួយ រួមចំណែកក្នុងការដាំដំណាំចំណីសត្វដើម្បីទទួលបានជោគជ័យ និងទទួលបានលទ្ធផលល្អក្នុងការអនុវត្តលើការងារដាំដំណាំចំណីសត្វ។ ចំពោះការកំណត់យកដីសម្រាប់ជាកន្លែងដាំដំណាំចំណីសត្វមានច្រើនសណ្ឋានដូចជាៈ ដីភូមិ ដីនៅក្រោយផ្ទះ ដីចំការ ដីចន្លោះរងដំណាំហូបផ្លែ ដែលដើមរបស់វានៅតូចៗ និងអាចជាដីទួលនៅតាមវាលស្រែ។ ម្យ៉ាងទៀតទោះបីជាដីស្ថិតក្នុងស្ថានភាពណាក៏ដោយ យើងគួរតែធ្វើការជ្រើសរើសដីសម្រាប់ដាំដំណាំចំណីសត្វទៅតាមគោលការណ៍បច្ចេកទេសដូចខាងក្រោមៈ

- ដីទួលមិនលិចទឹករយៈពេលយូរ ឬដីមិនដាំទឹកជាប្រចាំ
- ដីចំការដំណាំមិនលិចទឹក និងមានលទ្ធភាពទទួលពន្លឺថ្ងៃគ្រប់គ្រាន់ដើម្បីដុះលូតលាស់
- មិនមែនជាដីវាលស្មៅធម្មជាតិរួមសម្រាប់លែងសត្វឱ្យស៊ីដោយគ្មានការគ្រប់គ្រង
- ដីមិនមានការផ្លាស់ប្តូរមុខដំណាំរយៈពេលខ្លីដែលធ្វើឡើងជារៀងរាល់ឆ្នាំ។

ជាបទពិសោធន៍ជាក់ស្តែង ផ្ទៃដីទំនេរមិនសូវមានការប្រើប្រាស់ ដូចជាដីនៅជុំវិញផ្ទះ ដីចម្ការដំណាំហូបផ្លែ ដីដំណាំរួមផ្សំ ឬដីសម្រាប់ថែរក្សាស្មៅស្រុកទុកផ្តល់ចំណីគោ-ក្របី នោះសុទ្ធតែជាទីកន្លែងល្អសមស្របក្នុងការសម្រេចចិត្តធ្វើការចាប់ផ្តើមដាំដំណាំចំណីសត្វដើម្បីផ្តល់ឱ្យសត្វស៊ី ហើយក៏ជាទីតាំងល្អសម្រាប់ដំណើរការផ្សព្វផ្សាយឱ្យកសិករមានការយល់ដឹង និងឈានទៅដល់ការកែប្រែប្រម្រង់ប្រព័ន្ធចំណីសត្វនៅកម្ពុជា។

#### ការរៀបចំដីសម្រាប់ដាំដំណាំចំណីសត្វ

ការរៀបចំដី គឺជាដំណាក់កាលមួយចាប់ផ្តើមការដាំដំណាំចំណីសត្វដែលចែកចេញជាបីដំណាក់កាលក្នុងនោះរួមមានៈ

- រៀបចំរបងការពារដំណាំចំណីសត្វមុនពេលធ្វើការដាំ
- ភ្ជួរ រាស់ដាស់ដីកម្ចាត់ស្មៅចង្រៃមុនពេលធ្វើការដាំ
- រៀបចំដាក់ជីទ្រាប់បាតដីសម្រេចនៅពេលដំណើរការដាំ ។

ការដាំដំណាំចំណីសត្វ ដើម្បីទទួលបានលទ្ធផលល្អ និងទទួលបានជោគជ័យក្នុងការដាំ គឺត្រូវតែឆ្លងកាត់នូវដំណាក់កាលទាំងបីខាងលើនេះទើបជួយឱ្យដំណើរការដាំដំណាំចំណីសត្វមានភាពងាយស្រួល និងមានសុវត្ថិភាពក្នុងការលូតលាស់បានល្អ ហើយក៏ជាផ្នែកមួយជួយសម្រួលដល់ដំណើរការគ្រប់គ្រងដំណាំចំណីសត្វក្រោយពេលធ្វើការដាំ មានដូចខាងក្រោម:

➢ **ការធ្វើរបង**

ការធ្វើរបង គឺដើម្បីជៀសវាងនូវការខូចខាតដំណាំចំណីសត្វពីការបំផ្លិចបំផ្លាញរបស់ហ្វូងសត្វនៅរដូវប្រាំង ដែលកសិករភាគច្រើនបានលែងសត្វឱ្យដើររកចំណីស៊ីនៅតាមវាលដោយខ្លួនឯងងាយស្រួលក្នុងការគ្រប់គ្រង និងការប្រមូលផលទទួលបានទិន្នផលខ្ពស់ដែលសមស្របទៅនឹងប្រព័ន្ធចិញ្ចឹមសត្វជាលក្ខណៈគ្រួសារពាក់កណ្តាលលែង និងពាក់កណ្តាលបង្ខាំង។

ជាទូទៅរបងត្រូវបានរៀបចំទៅតាមស្ថានភាពជីវភាព និងលទ្ធភាពរបស់កសិករអាចរកបានដោយប្រើប្រាស់ធនធាននៅក្នុងមូលដ្ឋាន ដើម្បីជៀសវាងការចំណាយថវិកា និងបង្កផលវិបាក ឬប៉ះពាល់ដល់ជីវភាពគ្រួសារកសិករ។ សម្ភារៈទាំងនោះរួមមាន:

- បង្គោលរបងអាចប្រើប្រាស់កូនឈើ ឬគល់ឬស្សី
- របាររបងអាចប្រើដើមឬស្សី, កូនឈើ, មែកឈើតូចៗ ដែកលួស និងសំរះបន្លាផ្សេងៗមកវាយ ឬស្រះធ្វើជារបា
- ប្រសិនបើយើងប្រើកូនឈើ ឬដើមឬស្សីធ្វើជារបាគឺត្រូវចងរបាក្នុងចន្លោះ០,៣ម ពីរបាមួយទៅរបាមួយទៀតឱ្យបានកម្ពស់ពី១.៣ទៅ១.៥ម ដើម្បីកុំឱ្យសត្វអាចផ្លោះចូលក្នុងចំការដំណាំចំណីសត្វបាន។




➢ **ការភ្ជួររាស់ដី**

ការភ្ជួររាស់ដី ជាកត្តាសំខាន់ណាស់ក្នុងការដាំដំណាំចំណីសត្វដែលត្រូវយកចិត្តទុកដាក់ ហើយត្រូវបានធ្វើឡើង ២-៣ដងនៅមុនពេលចាប់ផ្តើមដាំដុះ។ ត្រូវភ្ជួរឱ្យបានជ្រៅនិងរាស់ដីឱ្យបានម៉ដ្ឋល្អ ជាពិសេសនៅពេលមានភ្លៀងធ្លាក់ដើមឆ្នាំដីមានសភាពសើមអាចភ្ជួរបាន ។ សារៈសំខាន់នៃការភ្ជួររាស់ដីមានដូចខាងក្រោម:

- ភ្ជួររាស់ដីឱ្យមានលក្ខណៈធូរធ្វើឱ្យទឹកអាចជ្រាបចូលទៅក្នុងស្រទាប់ក្រោមដីបានល្អ និងមានចរន្តខ្យល់ក្នុងដី ដើម្បីសម្លាប់ស្មៅចង្រៃ
- ភ្ជួររាស់ដីបានបង្កប់ស្មៅចង្រៃ និងកម្ទេចកំទី ឬជីលាមកសត្វទៅផ្នែកក្រោមនៃស្រទាប់ដីដាំដុះដើម្បីឱ្យវារលួយពុកផុយជួយបង្កើនគុណភាពដី
- សម្លាប់ពពួកស្មៅចង្រៃពេលវាចាប់ផ្តើមដុះលើកដំបូង ព្រោះស្មៅចង្រៃធន់ទៅនឹងអាកាសធាតុក្នុងតំបន់ ហើយអាចដុះលូតលាស់ប្រជែងជាមួយដំណាំចំណីសត្វ ស្រូបយកជីវជាតិ និងស្រូបយកទឹកដែលបណ្តាលឱ្យដំណាំចំណីសត្វមិនអាចដុះលូតលាស់បានល្អ ឬករណីពពួកស្មៅចង្រៃដុះច្រើនធ្វើឱ្យលទ្ធផលដំណុះរបស់ដំណាំចំណីសត្វថយចុះ ឬធ្វើឱ្យខូចខាតទាំងស្រុងតែម្តង។

ជាទូទៅការភ្ជួរដាស់ដីចាំបាច់ធ្វើឡើងរយៈពេលយ៉ាងតិចពី១០-១៥ថ្ងៃមុនពេលរៀបចំដីសម្រេចក្នុងការដាំដំណាំចំណីសត្វ។





➢ **ការរៀបចំដីសម្រេចនៅពេលដំណើរការដាំដំណាំចំណីសត្វ**

ការរៀបចំដីសម្រេច គឺជាដំណាក់កាលចុងក្រោយនៃការរៀបចំដី ដើម្បីដំណើរការដាំដំណាំចំណីសត្វ។ សកម្មភាពដែលសំខាន់ៗក្នុងការអនុវត្តរួមមាន:

- ភ្ជួរប្រែត្រឡប់ដីដែលបានដាស់រួចពីមុនឱ្យបានសព្វល្អ
- រាស់បំបែកបំណាស់អាចម៍ដីឱ្យបានរាបស្មើល្អ និងរើសសម្អាតពពួកស្មៅចង្រៃដែលនៅសេសសល់ចេញឱ្យបានស្អាត
- ធ្វើចង្អូរសម្រាប់បង្ការទុកបង្ហូរទឹកដើម្បីការពារពេលមានទឹកភ្លៀងធ្លាក់ខ្លាំង ឬមានទឹកដក់ហួសកំណត់បណ្តាលឱ្យជាំទឹករលួយដំណាំចំណីសត្វ
- ត្រូវធ្វើការបែងចែកផ្ទៃដីជាជួរដែលតម្រូវតាមប្រភេទពូជដើម្បីឱ្យច្បាស់ថាតើប្រភេទ ពូជមួយមានប៉ុន្មានជួរក្នុងករណីការដាំដំណាំចំណីសត្វចម្រុះ
- ក្នុងករណីដាំដំណាំចំណីសត្វដោយប្រើប្រាស់គ្រាប់ គឺត្រូវការឆូតចង្អូរជាជួរដោយប្រើប្រាស់ចប ឬកំណាត់ឈើក្នុងជម្រៅប្រមាណពី ០,២-០,៣សម ឱ្យបានត្រង់ល្អទៅតាម ជួរនីមួយៗដើម្បីដាក់គ្រាប់ដាំ។

ក្នុងករណីប្រើប្រាស់ជីលាមកសត្វ ឬជីកំប៉ុសសម្រាប់ទ្រាប់បាត អាចដាក់នៅពេលដែលចាប់ផ្តើមភ្ជួរ ឬរាស់បំបែកអាចម៍បំណាស់ដី ព្រោះជីអាចប្របល់ជាដីបានសព្វល្អ និងកប់ចូលទៅក្នុងដី ហើយរក្សាគុណភាពជីក្នុងដីបានល្អជាងការដាក់ជីនៅផ្នែកលើនៃផ្ទៃដី។ ការរៀបចំដី ជាទូទៅធ្វើឡើងឱ្យស្របទៅនឹងលក្ខណៈសណ្ឋាន ដើម្បីរក្សាបាននូវលក្ខណៈបរិស្ថាន និងទម្ងន់លក្ខណៈដីឱ្យសមស្របទៅតាមលក្ខណៈបច្ចេកទេសក្នុងការប្រើប្រាស់ដី។





## ខ. ការរៀបចំពូជដំណាំចំណីសត្វ

ពូជគឺជាកត្តាសំខាន់ក្នុងការកំណត់នូវភាពជោគជ័យ និងការត្រៀមរៀបចំដាំដុះដំណាំចំណីសត្វ ព្រោះនៅប្រទេសកម្ពុជា ពុំទាន់មានលទ្ធភាពផលិតគ្រាប់ពូជដំណាំចំណីសត្វដើម្បីធ្វើពាណិជ្ជកម្មនៅឡើយ។ គ្រាប់ពូជមួយចំនួនត្រូវបាននាំចូលពីប្រទេសថៃឡង់ដ៍ និងប្រទេសឡាវ (លើកលែងតែពូជស្ពេចស្មៅ)។ល។ ដើម្បីសម្រេចឱ្យបាននូវដំណើរការនេះ ចាំបាច់ត្រូវយល់ដឹងនូវចំណុចសំខាន់មួយចំនួនដូចជា ការជ្រើសរើស និងការប្រើប្រាស់ពូជ របៀបពិនិត្យគុណភាពគ្រាប់ពូជ លក្ខណៈជីវសាស្ត្រប្រភេទពូជ របៀបសាកល្បងគ្រាប់ពូជ និងបរិមាណគ្រាប់ពូជ។ ចំណុចទាំងនេះនាំឱ្យយើងទទួលបានលទ្ធផលល្អ និងទទួលបានជោគជ័យលើការងារដាំដំណាំចំណីសត្វដែលត្រូវអនុវត្តរួមមាន៖

### ➢ ការជ្រើសរើសពូជ

ពូជដំណាំចំណីសត្វមានច្រើនប្រភេទខុសៗគ្នា ហើយមានការប្រែប្រួលទៅតាមស្ថានភាពដាំដុះនៅក្នុងតំបន់ និងចំណង់ចំណូលចិត្តរបស់អ្នកដាំ។ ហេតុដូច្នេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវឱ្យមានលក្ខណៈសមស្របចំណុចខាងលើនេះចាំបាច់ត្រូវយល់ដឹងពីរបៀបជ្រើសរើសពូជមួយចំនួនដូចមានខាងក្រោម៖

- ជ្រើសរើសតាមវិធីសាស្ត្រដាំដុះ និងតម្រូវការប្រើប្រាស់
- ជ្រើសរើសទៅតាមលក្ខណៈអាកាសធាតុ និងស្ថានភាពប្រភេទដីដែលត្រូវដាំ
- ជ្រើសរើសទៅតាមទម្រង់នៃការដុះលូតលាស់របស់ដំណាំចំណីសត្វ
- ជ្រើសរើសទៅនឹងចំណង់ចំណូលចិត្ត និងសារៈប្រយោជន៍របស់ដំណាំចំណីសត្វ ។

**តារាងជ្រើសរើសពូជឱ្យស្រមទៅនឹងការដាំដុះ**

| ជ្រើសរើសតាមវិធីសាស្ត្រដាំដុះ និងតម្រូវការប្រើប្រាស់ | ជ្រើសរើសទៅតាមលក្ខណៈអាកាសធាតុ និងប្រភេទដីដែលត្រូវដាំ | ជ្រើសរើសទៅតាមទម្រង់នៃការដុះលូតលាស់របស់ដំណាំចំណីសត្វ | ជ្រើសរើសទៅនឹងចំណងចំណូលចិត្ត និងសារៈប្រយោជន៍ |
|---|---|---|---|
| ដាំសម្រាប់កាត់ផ្តល់ឱ្យសត្វស៊ី | ដាំនៅតំបន់រដូវប្រាំងវែង | ប្រភេទដើមមានកម្ពស់ខ្ពស់ | ងាយស្រួលច្រូតកាត់ដើម និងស្លឹកទន់ល្អលូតលាស់លឿន |
| ដាំសម្រាប់លែងឱ្យសត្វស៊ី | ដាំនៅតំបន់រដូវប្រាំងខ្លី | ប្រភេទដើមមានកម្ពស់មធ្យម ទាប រឹងមាំ ធន់ទ្រាំនឹងការចូលស៊ីនៃសត្វ | ផ្តល់ទិន្នផលខ្ពស់ |
| ដាំធ្វើជារបងរស់ | ដាំនៅតំបន់អាកាសធាតុត្រូពិចសើម | ប្រភេទលេហ្គឹមដើមឈើធន់ទ្រាំនឹងការច្រូតកាត់ | គុណភាពល្អ |
| ដាំសម្រាប់កែលម្អដី | ដាំនៅលើដីមានការថយចុះជីវជាតិដី | ប្រភេទលេហ្គឹម | សត្វចូលចិត្តស៊ី |
| ដាំទប់ស្កាត់ការហូរច្រោះដី | ដាំនៅលើដីមានជីជាតិល្មម និង ចំណោត | ប្រភេទលេហ្គឹម ដើមឈើ | ងាយស្រួលក្នុងការថែរក្សា |
| ដាំធ្វើជាចំណីបន្ថែមដល់សត្វ | ដាំនៅលើដីមានជាតិអាស៊ីត | ប្រភេទដើមឈរត្រង់មិនដួល | កាត់ហើយលូតលាស់ឡើងវិញ |

### ➢ ការយល់ដឹងពីគ្រាប់ពូជ

គ្រាប់ពូជដំណាំចំណីសត្វ មុនពេលដំណើរការដាំ យើងត្រូវពិនិត្យមើលលើគុណភាពរបស់គ្រាប់ពូជភាគច្រើន គ្រាប់ពូជគឺជាប្រភពដើមនៃការបង្ករបង្កើតពូជដំណាំចំណីសត្វ ដែលមានពពួកស្មៅស្ថិតក្នុងអំបូរក្រាមមីណេ និងពពួកឃាសជាតិ អំបូរសណ្តែក ឬរុក្ខជាតិដែលមានដើមដងដូចជាដើមឈើពេញលេញ ពពួកទាំងនោះភាគច្រើនដុះលូតលាស់តាមរយៈគ្រាប់។ ព្រោះបើយើងប្រើប្រាស់គ្រាប់ពូជពុំមានគុណភាពនោះវានាំឱ្យមានការខាតបង់នូវថវិកា ពេលវេលា កម្លាំងពលកម្មដែលយើងត្រូវអនុវត្តការដាំដុះច្រើនដង ជាពិសេសប្រសិនបើអនុវត្តជាមួយកសិករធ្វើឱ្យបាត់បង់ជំនឿទុកចិត្តលើបច្ចេកវិទ្យាដែលយើងកំពុងធ្វើការផ្សព្វផ្សាយ។ ដើម្បីជៀសវាងនូវប្រការទាំងឡាយខាងលើនេះ អ្នកបច្ចេកទេសត្រូវចេះពីរបៀបពិនិត្យមើលគុណភាពគ្រាប់ពូជមួយចំនួនដូចជាៈ

- ត្រូវពិនិត្យមើលពីរបៀបទុកដាក់គ្រាប់ពូជដំណាំចំណីសត្វ ថាការទុកដាក់នោះបានត្រឹមត្រូវទៅតាមបច្ចេកទេសដែរឬទេ?
- ត្រូវពិនិត្យមើលពីការវេចខ្ចប់ថា ការវេចខ្ចប់មានកម្រិតជិតបានល្អ អាចការពារពីខ្យល់ ពីពន្លឺថ្ងៃ បានល្អដែរឬទេ?
- ត្រូវធ្វើការសាកសួរពីអាយុកាលគ្រាប់ពូជឱ្យបានដឹងច្បាស់ ព្រោះវាមានការពាក់ព័ន្ធ ទៅនឹងការហួសកំណត់ពេលវេលាក្នុងការប្រើប្រាស់ និងមិនទាន់ដល់ពេលវេលាកំណត់ឱ្យប្រើប្រាស់
- ត្រូវពិនិត្យមើលរាល់ស្ថានភាពគ្រាប់ពូជថា ស្ងួតល្អ ទម្រង់គ្រាប់ស្មើល្អ ពណ៌សម្បុរគ្រាប់ពូជ មានសភាពភ្លឺល្អ។

ចំពោះគ្រាប់ពូជដែលមានដំណេកគ្រាប់ ឬសំបកគ្រាប់ពូជក្រាស់ ត្រូវដឹងច្បាស់ថាបានដាស់ដំណេកគ្រាប់មុនពេលយកទៅធ្វើការដាំ។




### ➢ ដំណេកគ្រាប់ពូជដំណាំចំណីសត្វ

ជាធម្មតាគ្រាប់ពូជដំណាំចំណីសត្វ វាមានពេលវេលាកំណត់មួយ ដែលអាចឱ្យចាប់ផ្តើមប្រើប្រាស់ក្នុងការដាំ ព្រោះវាមានពេលវេលាដំណេកគ្រាប់ៈ

- ពពួកស្មៅ បន្ទាប់ពីប្រមូលផលរួចដំណេកគ្រាប់ស្ថិតក្នុងកំឡុងពេលពី ៣-៦ខែ ទើបអាចយកមកប្រើប្រាស់
- ពពួកលេហ្គឹម គ្រាប់មានសំបកក្រាស់ បន្ទាប់ពីប្រមូលផលរួចដំណេកគ្រាប់ស្ថិតក្នុងកំឡុងពេលពី ៦-៨ខែ ទើបអាចយកមកប្រើប្រាស់។

ដើម្បីដាស់ដំណេកគ្រាប់ពូជទាំងនេះគឺមានវិធីច្រើនដូចជាៈ

- កោស ឬខាត់សំបកគ្រាប់ពូជឱ្យស្តើងមុនយកទៅដាំ
- ត្រូវធ្វើការត្រាំគ្រាប់ក្នុងទឹកត្រជាក់រយៈពេល១-២ថ្ងៃហើយស្រង់ផ្អាប់ទុករយៈពេល២៤ម៉ោងមុនយកទៅសាបឬដាំ
- ស្រុះគ្រាប់ពូជនឹងទឹកក្តៅដាំពុះ២-៥នាទីរួចស្រង់យកទៅដាក់ក្នុងទឹកត្រជាក់រហូតដល់អស់កម្តៅទើបយកទៅដាំ

- ស្រុះគ្រាប់ពូជនឹងទឹកក្តៅ ៨០ អង្សាសេ ទុករយៈពេល៥-១០នាទី រួចស្រង់យកទៅដាក់ក្នុងទឹកត្រជាក់រហូតដល់អស់កម្តៅទើបយកទៅដាំ។

គ្រាប់ដែលបានដាស់ដំណេករួចត្រូវប្រើប្រាស់ឱ្យអស់ក្នុងកំឡុងពេលពី១-១០ថ្ងៃ។ ម្យ៉ាងទៀត វិធីដែលល្អ និងងាយស្រួលអនុវត្តក្នុងពេលដាស់ដំណេកគ្រាប់ពូជដំណាំចំណីសត្វ គឺការប្រើប្រាស់ទឹកក្តៅ ព្រោះការប្រើប្រាស់ទឹកក្តៅវាមានរយៈពេលខ្លី និងផ្តល់ប្រសិទ្ធភាពខ្ពស់ ក្នុងការអនុវត្តដាំដំណាំចំណីសត្វ។

➢ **ការសាកល្បងដំណុះគ្រាប់**

ជាទូទៅក្នុងការប្រើប្រាស់គ្រាប់ពូជដំណាំចំណីសត្វ ចាំបាច់ត្រូវធ្វើតេស្តដំណុះគ្រាប់ពូជជាមុនសិន បើទោះបីជាគ្រាប់ពូជទាំងនោះមានប្រភពមកពីណាក៏ដោយមុនយកគ្រាប់ពូជទៅដាំ ឬសាបកូន។ ដោយឡែកដំណើរការធ្វើការសាកល្បងគុណភាពដំណុះគ្រាប់ពូជនេះគឺជាការចាំបាច់ក្នុងគោលបំណងចង់ដឹងពីភាគរយនៃ ដំណុះគ្រាប់មុនពេលយកទៅដាំ។ ចំពោះការសាកល្បង ធ្វើតេស្តមើលគុណភាពគ្រាប់ពូជនេះ ជាទូទៅមិនគិតពីប្រភេទដី ឬបរិយាកាសជាក់លាក់ នៅកន្លែងណាមួយនោះទេ ប៉ុន្តែយើង ត្រូវគិតគូរទៅលើលក្ខខណ្ឌប្រកបដែលដំណាំចំណីសត្វ អាចដុះបាន។ វិធីដែលត្រូវអនុវត្តរួមមាន:

- ត្រូវរៀបចំប្រអប់បណ្តុះគ្រាប់ពូជទំហំពី ១,៥សម X ២៥សម និងដាក់ក្រដាស់ស្តើង ដីខ្សាច់ម៉ត់ ឬដីចម្ការសម្រាប់ ៥សម-៦សម ពីបាតប្រអប់
- ត្រូវបាញ់ទឹក ដោយប្រើប្រដាប់បាញ់ទឹកមានរន្ធតូច ដើម្បីផ្សើមក្នុងកំរិត ៥០-៦០%ត្រូវចាប់យកគ្រាប់ពូជចំនួន ១០០គ្រាប់មកដាក់បណ្តុះដោយដំរៀបគ្រាប់ពូជពីលើក្រដាស់សើម ឬ ធ្វើការឆូតដីក្នុងប្រអប់ជម្រៅប្រមាណ០,៥សម ហើយដាក់គ្រាប់រួចធ្វើការលុបដីទៅវិញ
- មិនត្រូវយកប្រអប់ដែលបានដាក់គ្រាប់ពូជធ្វើតេស្ត រួចដាក់ត្រូវពន្លឺថ្ងៃផ្ទាល់នោះទេ
- ត្រូវផ្តល់ទឹកបន្ថែមដោយប្រុងប្រយ័ត្ន ប្រសិនបើពិនិត្យឃើញសំណើមនៅក្នុងប្រអប់ ពិសោធន៍មានសភាពស្ងួត
- ត្រូវសរសេរស្លាកកត់ត្រាពីឈ្មោះគ្រាប់ពូជ និងថ្ងៃ ខែ ឆ្នាំ ធ្វើតេស្តសាកល្បងដោយបិទពីលើគម្របប្រអប់។

នៅក្នុងគ្រាប់ពូជដំណាំចំណីសត្វ(ស្មៅ) និងរុក្ខជាតិ គឺវាមានកូនរុក្ខជាតិ ឬអំប្រីយ៉ុង និងសំបកគ្រាប់។ ប៉ុន្តែអាហារសម្រាប់ចិញ្ចឹមមិនត្រូវបានស្តុកនៅក្នុងស្លែបគ្រាប់ពូជនៃអំប្រីយ៉ុងនោះទេ។ ផ្ទុយទៅវិញ វាត្រូវបានផ្ទុកនៅក្នុងផ្នែកមួយនៃគ្រាប់ពូជដែលមានឈ្មោះថា អង់ដូស្ពែម។ នៅពេលមានសំណើម អំប្រីយ៉ុងស្ថិតក្នុងគ្រាប់ពូជអាចចាប់ផ្តើមដុះចេញមកក្រៅ ដំណើរការនេះគេហៅថាដំណុះ។ យ៉ាងណាមិញ ប្រសិនបើគ្រាប់ពូជដំណាំចំណីសត្វ ឬរុក្ខជាតិ ដែលត្រូវបានរក្សាទុកឱ្យនៅស្ងួត មានន័យថាកូនរុក្ខជាតិនៅក្នុងគ្រាប់ពូជទាំងនោះនឹងនៅមានជីវិតមួយរយៈពេល ប៉ុន្តែបន្ទាប់ពីមួយរយៈពេលយូរក្រោយមកទៀត អំប្រីយ៉ុងនឹងត្រូវស្លាប់។ ចំពោះគ្រាប់ពូជអាចរស់បានក្នុងរយៈពេលពី៣-៤ឆ្នាំ ប៉ុន្តែបន្ទាប់ពីរយៈពេលនេះ អំប្រីយ៉ុងភាគច្រើនត្រូវបានស្លាប់ ដូច្នេះត្រូវរក្សាគ្រាប់ពូជឱ្យបានស្ងួតទើបជាការប្រសើរ។

ម្យ៉ាងទៀត តាមការស្រាវជ្រាវរបស់អ្នកបច្ចេកទេស បានកំណត់លើលទ្ធផលក្នុងការធ្វើតេស្តដំណុះគ្រាប់ពូជណាដែលអាចយកទៅប្រើប្រាស់ល្អ និងមិនអាចយកទៅប្រើប្រាស់វាអាស្រ័យប្រភេទពូជ និងអត្រាដំណុះគ្រាប់ពូជមានដូចជា:

➢ **ពពួកស្មៅ**(Grass)

- កម្រិតដំណុះគ្រាប់ពូជច្រើនជាង ២០% អាចប្រើប្រាស់បានល្អ
- កម្រិតដំណុះគ្រាប់ពូជតិចជាង ២០% មានន័យថាគុណភាពគ្រាប់ពូជអន់មិនត្រូវប្រើប្រាស់ ឡើយ។ ប៉ុន្តែ បើចង់ប្រើប្រាស់គឺត្រូវបង្កើនបរិមាណ ឬរកពូជថ្មីមកជំនួស។

➢ **ពពួកសណ្តែក**( Legume)

- កម្រិតដំណុះគ្រាប់ពូជច្រើនជាង ៤០% អាចប្រើប្រាស់បានល្អ

- កម្រិតដំណុះគ្រាប់ពូជតិចជាង ៤០% មានន័យថាគុណភាពគ្រាប់ពូជអន់មិនត្រូវប្រើប្រាស់ ឡើយ។ ប៉ុន្តែបើចង់ប្រើប្រាស់គឺត្រូវបង្កើនបរិមាណ ឬរកពូជថ្មីមកជំនួស។






### គ. បច្ចេកទេសដាំដំណាំចំណីសត្វ

ការដាំដំណាំចំណីសត្វ ត្រូវអនុវត្ត៤របៀបផ្សេងៗគ្នា ដែលរបៀបនីមួយៗប្រែប្រួលទៅតាមប្រភេទពូជ និងទៅតាមជីវសាស្ត្ររបស់វា។ ការដាំដំណាំចំណីសត្វ (ហ្គីណេ) ពពួកស្មៅស្ទើរគ្រប់ប្រភេទពូជទាំងអស់អាចដាំបានដោយប្រើប្រាស់គ្រាប់ផ្ទាល់ បំបែកដើមក្នុងគុម្ព និងសាបកូនដកយកទៅដាំ មានដូចជា ម៉ារ៉ានឌូ ( Brachiaria Brizantha-Marandu), ម៉ូឡាតូ ២(Brachiaria hybrid-Mulato 2 ), ស៊ីមួង(Panicum Maximum-Simuang), តេរ៉េណូស (Paspalum atratum-Terenos), រូស៊ី (Brachiaria Ruziziensis) លើកលែងតែពពួកក្រុមនេពារដូចជា យីងក្រាស់ (King Grass) ស្មៅដំរី (Elephant Grass ) ដែលគេដាំដោយប្រើប្រាស់គ្រាប់ និងកាប់ដើមដាំ។ ក្រៅពីពពួកស្មៅ នៅមានពពួកលេហ្គឹម (បន្លែ) មួយចំនួនទៀតមានដូចជា ស្តាយឡូ ១៨៤(Stylo 184) ដេសម៉េនធីស (Desmanthus Virgatus), សិនត្រូសេម៉ា (Centrosema Pascuorum CV. Cavalcade), អារាឆីស ( Arachis sPP) និងពពួកលេហ្គឹមវល្លិ៍ ក៏ត្រូវបានដាំដោយប្រើគ្រាប់ដូចពពួកស្មៅផងដែរ។ ចំពោះរុក្ខជាតិដើមឈើ អាចដាំដោយប្រើគ្រាប់ កាត់មែក ឬផ្សាំមែក និងបណ្តុះកូនដាំ។

#### ១. បច្ចេកទេសដាំដោយប្រើប្រាស់គ្រាប់ផ្ទាល់

- ត្រូវរៀបចំដីឱ្យបានម៉ត់ល្អ ធ្វើការសម្អាតស្មៅចង្រៃចេញឱ្យបានស្អាត និងរាស់ដីឱ្យបានរាបស្មើល្អមុនពេលដាំ
- បាចគ្រាប់ពូជក្នុងបរិមាណ ៤-៥គ.ក្រ/ហិកតា ចំពោះគ្រាប់មានដំណុះពី២០-៣០%។ ការដាំបែបនេះគឺអនុវត្តលើដីដាំស្មៅមានទំហំផ្ទៃធំៗរាប់សិបហិកតា។ ការដាំលក្ខណៈបែបនេះមានការលំបាកក្នុងការគ្រប់គ្រង និងថែទាំជម្រះស្មៅចង្រៃចេញ
- ការដាំជារង ឬជាជួរត្រូវឆ្លូតដីដោយប្រើប្រាស់ចប ដើមកូនឫស្សី ឬកូនដើមឈើធ្វើជាចង្អូរជម្រៅពី២-៣,៥សមឱ្យត្រង់ល្អដើម្បីដាក់គ្រាប់ដាំ
- ត្រូវលប់ដីតាមចង្អូរដែលបានដាក់គ្រាប់រួចប្រមាណពី១,៥-២សម បន្ទាប់មកបង្ហាប់ដីឱ្យគ្រាប់ប៉ះទៅនឹងដី ឬយករនាស់ដៃអូសពីលើចង្អូរដែលបានដាក់គ្រាប់ដាំរួច
- ករណីដាំជាជួរត្រូវទុកចន្លោះពីជួរមួយទៅជួរមួយពី៣៥-៤០សម អនុវត្តបែបនេះបង្កភាពងាយស្រួលក្នុងការគ្រប់គ្រងថែទាំ និងសម្អាតស្មៅចង្រៃចេញ
- ការដាំអាចប្រើរោយគ្រាប់ដោយដៃឬកំប៉ុងចោះឡេរួចដាក់គ្រាប់ពូជចូលហើយគោះទម្លាក់គ្រាប់ពូជតាមចង្អូរដែលបានឆ្លូតរួច
- ក្រោយពេលដាំក្នុងរយៈពេលប្រមាណពី២០-៣០ថ្ងៃ ពូជស្មៅធម្មជាតិ(ស្មៅចង្រៃ) ចាប់ ផ្តើមដុះពេញបន្ទុក ដូច្នេះយើងត្រូវដកស្មៅចេញ ដើម្បីទុកឱ្យកូនពូជដំណាំចំណីសត្វ មានលទ្ធភាពដុះលូតលាស់ ប្រសិនបើមិនធ្វើដូច្នេះទេ

ពេលស្មៅចង្រៃដុះឡើងពេញទំហឹង វាបណ្តាលឱ្យកូនពូជដំណាំចំណីសត្វពុំអាចមានលទ្ធភាពដុះលូតលាស់បាន ឬធ្វើឱ្យកូនដំណាំចំណីសត្វមិនអាចដុះបានឡើយ

- ការដាំដំណាំចំណីសត្វដោយប្រើប្រាស់គ្រាប់ នៅពេលដុះមកគឺវាមានសុខភាពល្អជាងការដាំដោយបំបែកដើម និងការប្រើប្រាស់កូន។

ចំណុចដែលគួរឱ្យយកចិត្តទុកដាក់ និងគួរឱ្យចងចាំលើការដាំដំណាំចំណីសត្វ គឺការប្រើប្រាស់គ្រាប់ ដោយហេតុថា គ្រាប់ពូជងាយនឹងរងនូវការពាំដោយសត្វស្រមោច និងសត្វល្អិតស៊ីបំផ្លាញ ដំណុះគ្រាប់ពូជដុះមិនស្មើគ្នា ក្រោយពេលស្រោចទឹក ឬក្នុងករណីភ្លៀងធ្លាក់ច្រើន គឺបណ្តាលឱ្យគ្រាប់ពូជដំណាំចំណីសត្វបានហូរប្រមូលកកផ្តុំគ្នាធ្វើឱ្យមិនមានលក្ខណៈរាយប៉ាយស្មើគ្នានឹងធ្វើឱ្យដីមានចន្លោះៗ ព្រមទាំងធ្វើឱ្យស្មៅចង្រៃដុះលូតលាស់ល្អ។ ជាទូទៅ ស្មៅចង្រៃដុះលូតលាស់មុនគ្រាប់ពូជដំណាំចំណីសត្វ ជាហេតុធ្វើឱ្យកូនស្មៅពូជដុះយឺតជាង មិនលូតលាស់ និងធ្វើឱ្យយើងមានការពិបាកដកស្មៅចង្រៃចេញ។



ការដាំស្មៅដោយគ្រាប់

## ២. បច្ចេកទេសដាំដោយបំបែកដើម ឬបំបែកខ្នែង

ការបំបែកដើមដំណាំចំណីសត្វ ភាគច្រើនគេអនុវត្តចំពោះពពួកស្មៅដំណាំចំណីសត្វណាដែលមានកម្ពស់ដើមទាប និងដើមមានកម្ពស់មធ្យម។ ដោយឡែកពពួកស្មៅដំណាំចំណីសត្វដែលមានកំពស់ដើមខ្ពស់ ពូកលេហ្គីមវៀរ និងលេហ្គីមដើមឈើប្រភេទខ្លះគេអាចបំបែកដើម ឬបំបៅដើមវាដាំបាន តែពេលខ្លះការដុះលូតលាស់របស់វាមានសភាពយឺតយ៉ាវពិបាកក្នុងការថែទាំឱ្យលូតលាស់បានល្អ ដោយប្រើរយៈពេលយូរជាងការសាបកូន ឬបណ្តុះកូនដាំ។ ការបំបែកដើមដំណាំចំណីសត្វពីក្នុងគុម្ពដើម្បីដាំ គឺត្រូវបានអនុវត្តជាច្រើនរបៀបដូចមានបង្ហាញខាងក្រោម:

- នៅពេលមានភ្លៀងធ្លាក់ជោគជាំល្អ យើងត្រូវចាប់ផ្តើមគាស់គុម្ពដំណាំចំណីសត្វ(ស្មៅ)ដែលបានទុកធ្វើពូជដើម្បីយកមកបំបែកដើម ឬបេះខ្នែងដើម ដោយជ្រើសរើសយកដើម ឬខ្នែងណាដែលមានសុខភាពល្អ ហើយថ្លោសៗរួចកាត់ចុងស្លឹកប្រមាណពី២/៣ចេញដើម្បីឱ្យវាមានសភាពរឹងមាំនៅពេលដាំ និងដុះលូតលាស់បានល្អ
- អាចបំបែកកូនដំណាំចំណីសត្វមួយចំនួនចេញពីគុម្ពនៅពេលវាមានអាយុចាប់ពី៣០- ៦០ថ្ងៃក្រោយពេលដាំរួច
- ចំពោះការដឹកជញ្ជូនទៅដាំនៅតំបន់ឆ្ងាយត្រូវរុំកូនដំណាំចំណីសត្វ(ស្មៅ) ដែលបានរំលែករួចដោយប្រើក្រដាស់ ឬក្រណាត់ជ្រើមទឹក ហើយច្រកចូលក្នុងថង់ផ្លាស្ទិកឱ្យបានជិត។ ការរៀបចំវេចខ្ចប់បែបនេះមិនត្រូវទុកឱ្យលើសពីរយៈពេល ៥ថ្ងៃឡើយ

- ត្រូវយកទៅដាំឱ្យបានឆាប់ដែលអាចធ្វើទៅបាន ក្នុងករណីមិនទាន់បានយកទៅដាំភ្លាមៗ នោះទេ គឺត្រូវយកវាទៅរក្សានៅទីត្រជាក់ និងធ្វើការផ្សើមឬយកវាទៅដាក់ត្រាំក្នុងទឹក រយៈពេល ២-៣ថ្ងៃមុនពេលយកវាទៅដាំ
- គេអាចបំបែកដើម ឬបេះខ្នែងយកទៅដាំនៅរដូវមានភ្លៀងធ្លាក់តិចបាន ប្រសិនបើមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់
- ដាំ (ស្ទូង)មួយគុម្ពប្រមាណពី១-៣ដើម និងស្រោចទឹកក្រោយពេលដាំរួច
- ដាំ(ស្ទូង)ជាជួរដោយទុកចន្លោះពីជួរមួយ ទៅជួរមួយទៀតប្រមាណពី ៣០-៥០សម ហើយចន្លោះពីគុម្ពមួយ ទៅគុម្ពមួយទៀតប្រមាណពី ២០-៣០សម
- ត្រូវរៀបចំដីកន្លែងដាំឱ្យបានម៉ត់ល្អ និងរាស់សម្អាតស្មៅចង្រៃចេញឱ្យបានស្អាត
- ពេលដាំត្រូវកប់គល់ក្នុងជំរៅប្រមាណពី៣-៤សម ទៅក្នុងដី រួចសង្កត់ ឬបិទដីឱ្យបានជិតល្អជៀសវាងការដួលដើម។

**ចំណុចងាយស្រួលៈ** ងាយស្រួលក្នុងការថែទាំ ងាយដកស្មៅចង្រៃចេញក្រោយពេលដាំរួច ដើមដែលបានបំបែករួចដុះលូតលាស់លឿនជាងស្មៅចង្រៃ។ ចំណុចអវិជ្ជមាននៃវិធីដាំដោយបំបែកដើមក្នុងគុម្ព ឬខ្នែងគឺអាយុរស់នៅរបស់វាមានរយៈពេលខ្លីជាងការដាំដោយគ្រាប់ និងការដាំដោយសាបកូន ព្រោះវាងាយឡើងគល់។ កន្លែងស្ទូងមិនត្រូវឲ្យមានទឹកដក់ខ្លាំង និងយូរពេកទេព្រោះវាអាចបណ្តាលឲ្យរលួយស្មៅ ជាពិសេសស្មៅទើបស្ទូងរួច។ បើមានទឹកដក់ត្រូវធ្វើចង្អូរសម្រាប់នាំទឹកចេញ។



ការដាំស្មៅដោយស្ទូងដើម (សំណាប)និងធ្វើចង្អូរសម្រាប់បង្ហូរទឹកចេញ

### ៣. បច្ចេកទេសដាំដោយសាប ឬបណ្តុះកូន

វិធីសាស្ត្រក្នុងការដាំដំណាំចំណីសត្វ គឺជាវិធីសាស្ត្រសាមញ្ញមានការរៀបចំថ្នាលសាប ឬបណ្តុះកូនដូចជាការធ្វើថ្នាលសាបសំណាប(ស្រូវ) ឬថ្នាលបណ្តុះកូនដំណាំហូបផ្លែ និងបន្លែ ។

ប៉ុន្តែវិធីនេះគេច្រើនអនុវត្តលើពពួកលេហ្គីមដើមឈើដែលមានសំបកគ្រាប់របស់វាក្រាស់ពិបាកក្នុងការដុះ ហើយវិធីនេះគេអាចអនុវត្តបាន០២របៀបៈ

– ការបណ្តុះគ្រាប់ដោយប្រើប្រាស់ថង់ផ្លាស្ទិកបណ្តុះ
– ការបណ្តុះគ្រាប់ដោយរៀបចំដីជាថ្នាលបណ្តុះបច្ចេកទេសក្នុងការដាំដំណាំចំណីសត្វ ដោយសាប ឬបណ្តុះកូនរួមមានៈ
    - រៀបចំដីធ្វើថ្នាលសម្រាប់សាប ឬបណ្តុះកូន
    - រៀបចំគ្រាប់ពូជដើម្បីសាប ឬបណ្តុះ
    - សាបកូនឱ្យបានក្រាស់បង្គួរ
    - កូនសាប ឬបណ្តុះចាប់ផ្តើមដកយកទៅដាំនៅពេលវាមានអាយុពី២១-៣០ថ្ងៃ ត្រូវធ្វើការដកកូនដែលមានដើមថ្លោសៗ និងមានសុខភាពល្អ។





### ➢ របៀបដកកូនពូជដំណាំចំណីសត្វ

- ជាការល្អចំពោះការដកកូនដែលបានសាប ឬបណ្ដុះដោយថ្នាលនៅពេលមានភ្លៀងធ្លាក់ភ្លាមៗ ប្រសិនបើគ្មានភ្លៀងគួរស្រោចទឹកឱ្យបានជោគរួចទុករយៈពេល ២៤ម៉ោង ទើបធ្វើការដកជាការល្អ ព្រោះធ្វើឱ្យដីមានលក្ខណៈផុសងាយស្រួលក្នុងការដកកូនដំណាំចំណីសត្វ ជាពិសេសគឺមិនដាច់គល់ឬសកូនពូជ ដំណាំចំណីសត្វ
- កាត់ចុងស្លឹកចេញដោយប្រើកូនកាំបិតមុត ជៀសវាងការក្ដិចចុងស្លឹកដោយដៃ។

ចំណុចងាយស្រួលៈ ការដាំដំណាំចំណីសត្វដោយប្រើកូន គឺមានភាពងាយស្រួលក្នុងការជម្រះស្មៅ ថែទាំពូជដំណាំចំណីសត្វមានការលូតលាស់លឿនជាងពពួកស្មៅធម្មជាតិ (ស្មៅចង្រៃ) ដាំផុះជាជួរងាយស្រួលក្នុងការប្រមូលផល (ច្រូតកាត់)។ ម្យ៉ាងទៀតចំណុចដែលសំខាន់គឺនៅតាមភូមិអាចធ្វើថ្នាល់សាបកូនពូជដំណាំចំណីសត្វរួមដែលធ្វើឱ្យសមាជិកក្នុងភូមិអាចមកដកកូនពូជ ដំណាំចំណីសត្វយកទៅដាំបាន ជៀសវាងករណីផ្ដល់គ្រាប់ពូជទៅដាំជួបនូវបញ្ហា។ ជាទូទៅវិធីសាស្ត្រនេះត្រូវបានអនុវត្តសម្រាប់កសិករដែលមានទំហំដីតូចៗ។





### ➢ របៀបដាំកូនដំណាំចំណីសត្វ

- ត្រូវរៀបចំដីឱ្យបានម៉ត់ល្អ និងជុំរះស្មៅចង្រៃចេញឱ្យបានស្អាត
- ដាក់ជីកំប៉ុស្ដ ឬជីលាមកសត្វទ្រាប់បាតចង្អូរ ឬរណ្ដៅដែលត្រូវដាំ
- រៀបចំរណ្ដៅ ឬចង្អូរឱ្យបានល្អដោយដាក់កូនដំណាំចំណីសត្វចូលទៅក្នុងរណ្ដៅ ឬចង្អូរ លៃយ៉ាងណាកុំឱ្យបត់ចុងឬស បើសិនជាដាំដំណាំចំណីសត្វជាកូនបណ្ដុះដោយថង់ ត្រូវកាត់ថង់បណ្ដុះចេញមុនពេលលប់គល់ដំណាំចំណីសត្វ។ ចំពោះការកប់គល់ត្រូវជាន់បង្ហាប់ដីឱ្យបានណែនល្អ
- ធ្វើការស្រោចទឹកដំណាំចំណីសត្វបន្ទាប់ពីដាំរួចប្រសិនបើគ្មានភ្លៀងធ្លាក់

• ព្យាយាមដកស្មៅចង្រៃជុំវិញគល់ដំណាំចំណីសត្វឱ្យបានស្អាត ពេលដំណាំចំណីសត្វនៅតូចឬការដុះលូតលាស់មិនទាន់បានល្អក្នុងរយៈពេលពី៧-១០ថ្ងៃ បន្ទាប់ពីដាំកូនដំណាំចំណីសត្វនឹងចាប់ផ្តើមលាស់គ្រួយ ឬដុះពន្លកស្លឹកនៅតាមភ្នែកថ្នាំង របស់វា។ យើងអាចប្រមូលផលដំណាំចំណីសត្វក្នុងរយៈពេលពី៤៥-៦០ថ្ងៃ បន្ទាប់ពីធ្វើការដាំដុះ។





## ៤. បច្ចេកទេសដាំដោយដើម ឬមែកបណ្តុះ

ដំណាំចំណីសត្វជាច្រើនប្រភេទមានលទ្ធភាពដុះលូតលាស់ដោយដើមថ្មី មែក ឬដើមតាមរយៈការដាំផ្ទាល់ និងតាមរយៈផ្សាំ(បំបៅ) ឬការបណ្តុះមែក។ ប្រភេទដំណាំចំណីសត្វទាំងនោះរួមមានពពួកដំ ណាំចំណីសត្វក្នុងក្រុមស្មៅនេពារ (Narpier) ដូចជាៈ ស្មៅដំរី យីងក្រាស និងពពួកលេហ្គឹមដើមឈើមួយចំនួនរួមមាន គ្លីរីស៊ីដ្យា មន ទ្រីចាន់ធីរ៉ាក្រទុំថេត ឬក្តម្ពទេស និងប្រភេទដំណាំចំណីសត្វមួយចំនួនផ្សេងទៀត។ វិធីសាស្រ្តដាំដំណាំចំណីសត្វប្រភេទទាំងនេះមានលក្ខណៈបច្ចេកទេសផ្សេងៗគ្នា) ដោយកាត់ដើមជាកំណាត់ៗដែលមានថ្នាំងមានភ្នែកល្អ ៣ថ្នាំង។ កំណាត់ដើមកប់គ្រង់បញ្ឈរឡើងលើ ឬផ្តេក បញ្លិតពាក់កណ្តាលដើម ឬ១ថ្នាំង មានដូចជាៈ

➢ **ពពួកស្មៅនេពារ**( Narpeir )

- រៀបចំដីឱ្យបានស្អាត រួចជីករណ្តៅទំហំប្រមាណ១៥-២០ស.ម ជម្រៅប្រមាណ២០-២៥ស.ម ហើយចន្លោះជួរមួយទៅជួរមួយទៀតប្រមាណ៥០- ៧០ស.ម និង ចន្លោះពីគុម្ពមួយទៅគុម្ពមួយទៀតមានប្រវែងប្រមាណ ៤០ស.ម
- ត្រូវលាយជីលាមកសត្វ ឬជីកំប៉ុសក្នុងកម្រិត ១/៣ នៃដីដោយច្របល់ឱ្យបានសព្វល្អក្នុងរណ្តៅ
- ជ្រើសរើសដើមដំណាំចំណីសត្វណាដែលមានលក្ខណៈរឹងមាំល្អ ហើយត្រូវពិនិត្យទៅលើចំ ណុចដំណុះភ្នែកថ្នាំងរបស់វា គឺមិនមានលក្ខណៈខ្ទាក់ នៅខ្ចីល្មម និងមិនរបកស្រោមសំបក ទើបជាការល្អ
- ពេលដាំត្រូវដាក់ពន្លកថ្នាំង(ភ្នែក)ឱ្យនៅផ្នែកខាងលើ ឬផ្តេកចំហៀងតែត្រូវជៀសវាងដាក់ពន្លកថ្នាំង(ភ្នែក)នៅផ្នែកខាងក្រោម
- ត្រូវកាត់ដើមរបស់វាជាកង់ៗប្រវែងប្រមាណពី៣០-៤០ស.ម ដោយលៃយ៉ាងណាឱ្យជាប់ភ្នែកថ្នាំង ៣ថ្នាំង/១កង់
- ដាក់ដើមដំណាំចំណីសត្វដាំ១-២កង់/១រណ្តៅ ដោយរៀបក្នុងដំណេកមុំ ៤៥ ដឺក្រេ និងលប់ដីបង្ហាប់ឱ្យបានណែនល្អប្រសិនបើមានលទ្ធភាព ត្រូវគ្របរណ្តៅដែលបានដាំ ដំណាំចំណីសត្វរួចដោយប្រើគល់ជញ្ជាំងចំបើង ឬស្មៅរាម រួចត្រូវស្រោចទឹកប្រមាណ ពី៤-៥ថ្ងៃ។ ចំពោះការដាំដំណាំចំណីសត្វបែបនេះក្នុងករណីថែទាំបានល្អវានឹងចាប់ ផ្តើមដុះពន្លកនៅពេលវាមានអាយុប្រមាណពី៧-១០ថ្ងៃ បន្ទាបពីបានដាំរួចហើយ ផ្តល់ផលនៅពេលវាមានអាយុប្រមាណពី៤៥-៦០ថ្ងៃ។





### ➢ ពពួកលេហ្គីមដើមឈើ

ជាទូទៅ ចំពោះការដាំដំណាំចំណីសត្វពពួកដើមឈើដូចជា គ្លីរីស៊ីដ្យា មន ទ្រីចាន់ធីរ៉ា ក្រទុំថេត ឬក្តម្ពទេស និងប្រភេទដំណាំចំណីសត្វមួយចំនួនផ្សេងទៀត ដូចគ្នាទៅនឹងការដាំដំណាំចំណីសត្វពពួក ដំណាំចំណីសត្វប្រភេទនេពាវដែរ តែការលូតលាស់របស់វាមិនសូវបានល្អប៉ុន្មាននោះទេ ហេតុដូចនេះ ដើម្បីឱ្យការលូតលាស់ដំណើការបានល្អ ចាំបាច់ត្រូវការផ្សាំមែក ឬបណ្តុះគ្រាប់របស់វាជាមុនសិនទើបគេយកទៅដាំ។ វិធីសាស្ត្រនៃការដាំដំណាំចំណីសត្វប្រភេទនេះរួមមានៈ

- រៀបចំថ្នាលសម្រាប់សាបកូន ដោយយកគ្រាប់ត្រាំជាមួយទឹកក្តៅកំរិត៨០អង្សាសេ ក្នុងរយៈពេលប្រមាណប្រហែលជា១០នាទី រួចស្រង់គ្រាប់យកទៅសំដិលឱ្យស្ងួតសិនមុនយកមកទៅសាបក្នុងរយៈពេលប្រមាណពី៣០-៤៥ថ្ងៃ ទើបគាស់កូនដំណាំ ចំណីសត្វយកទៅដាំដោយធ្វើយ៉ាងណាកុំឱ្យវាដាច់ឬស រួចលះស្លឹកចេញឱ្យអស់មុនពេលយកទៅដាំ
- កាត់មែកពូជដំណាំចំណីសត្វណាមួយដែលនៅខ្ចីល្មម (សំបករបស់វាមានពណ៌បៃតងចាស់) ជាកង់ៗប្រវែងប្រមាណពី ២០-២៥ ស.ម ដោយធ្វើយ៉ាងណាកុំឱ្យរបកសំបករបស់វានៅពេលកាត់ ឬនៅពេលដឹកជញ្ជូនយកទៅដាំ
- ធ្វើការលាយដីជាមួយដីកំប៉ុស ឬជីលាមកសត្វក្នុងកម្រិត១/៣ ហើយត្រូវធ្វើការច្របល់ចូលគ្នាឱ្យសព្វល្អរួចច្រកចូលទៅក្នុងថង់ ឬស្បោងផ្លាស្ទិកដើម្បីបណ្តុះ បន្ទាប់ពីដាក់ដើមពូជដំណាំចំណីសត្វបណ្តុះក្នុងថង់ ឬស្បោង បន្ទាប់ពីបណ្តុះរួចយើងត្រូវធ្វើការសង្កេតមើលថាតើពូជដំណាំចំណីសត្វដែលបានដាក់បណ្តុះក្នុងថង់ ឬស្បោងនោះមានចេញត្រួយវាដែរឬទេ? ប្រសិនបើយើងសង្កេតឃើញថាវាមានការចេញត្រួយដូច្នេះរយៈពេលប្រមាណពី ១០-១៥ថ្ងៃយើងអាចដកវាយកទៅដាំបាន
- មុនពេលយកកូនដំណាំចំណីសត្វទៅធ្វើការដាំត្រូវកាត់ថង់ ឬស្បោងដែលបានដាក់បណ្តុះចេញ ដើម្បីឱ្យឬសរបស់វាលូតលាស់បានល្អ រួចត្រូវបង្ហាប់ដីឱ្យបានណែនល្អ ហើយធ្វើការគ្របគល់កូនដំណាំចំណីសត្វដែលបានដាំរួចដោយចំបើង ឬកម្ទេចសម្រាម និងធ្វើការស្រោចទឹកឱ្យបានជោគក្នុងរយៈពេញពី៤-៥ថ្ងៃ បន្ទាប់ពីបានធ្វើការដាំរួច។

ក្រោយពីដាំរួចក្នុងរយៈពេលប្រមាណពី ៤៥-៦០ថ្ងៃ ដំណាំចំណីសត្វនឹងដុះស្លឹកដែលអាចកាត់ផ្តល់ឱ្យសត្វស៊ីបានក្នុងកម្រិតប្រមាណពី ៣០-៤០% និងអាចប្រមូលផលជាបន្តបន្ទាប់ទៀតនៅពេលស្លឹករបស់វាលូតលាស់ពេញលេញសារជាថ្មី។ ចំពោះការប្រមូលផលត្រូវមានការ ប្រុងប្រយ័ត្នជៀសវាងការកាច់ដោយដៃ ការកាត់ដោយប្រើប្រាស់កាំបិតមិនសូវមុត ឬការទាញមែកឱ្យរហែកសំបក ដែលជាប្រការនាំឱ្យដំណាំចំណីសត្វមានការដុះលូតលាស់យឺត ឬនាំឱ្យខូចខាតទាំងស្រុងតែម្តងក៏បាន។




## ឃ. ការថែទាំ និងការគ្រប់គ្រងដំណាំចំណីសត្វក្រោយពេលដាំ

ជាទូទៅការថែទាំ និងការគ្រប់គ្រងដំណាំចំណីសត្វ ជាកត្តាសំខាន់ណាស់ដែលអាចធ្វើឱ្យយើងទទួលបានកម្រិតជោគជ័យដោយផ្អែកលើបច្ចេកទេសទើបធ្វើឱ្យដំណាំចំណីសត្វដុះលូតលាស់ ផ្តល់ទិន្នផល និងមានគុណភាពខ្ពស់សម្រាប់អាហាររូបត្ថម្ភរបស់សត្វ និងស្ថិតស្ថេរគង់វង្ស។ ចំណុចសំខាន់ៗក្នុងការថែទាំ និងគ្រប់គ្រងដំណាំចំណីសត្វគួរយកចិត្តទុកដាក់រួមមាន:

### ១. ដី និងជីវជាតិដី

ត្រូវភ្ជួររាស់ដីឱ្យបាន ២-៣ដង មុនពេលធ្វើការដាំដំណាំចំណីសត្វដើម្បីធ្វើយ៉ាងណា ឱ្យដីមានសភាពធូរ បន្ទាប់មកដាក់ជីទ្រាប់បាត។ ក្រោយពេលដាំ ត្រូវឧស្សាហ៍ជ្រោយដីនៅជុំវិញគល់ និងឧស្សាហ៍ដាក់ជីបំប៉នបន្ថែម ព្រោះនៅពេលច្រូតកាត់ដំណាំចំណីសត្វហាក់ដូចជាត្រូវបានស្រូបយកជីវជាតិពីក្នុងដីអស់យ៉ាងច្រើន ដោយសារដំណាំចំណីសត្វត្រូវបានស្រូបយកជីវជាតិពីក្នុងដីដើម្បីចិញ្ចឹមសរីរាង្គ និងការលូតលាស់របស់វា។ ប្រសិនបើយើងមិនឧស្សាហ៍ដាក់ជីបន្ថែមទេនោះ វាធ្វើឱ្យទិន្នផលដំណាំចំណីសត្វថយចុះយ៉ាងឆាប់រហ័ស និងមានសារធាតុចិញ្ចឹមនៅក្នុងដំណាំចំណីសត្វតិចផងដែរ។




### ២. ការគ្រប់គ្រងសម្អាតស្មៅចង្រៃ

ជាធម្មតាស្មៅចង្រៃដុះលូតលាស់លឿនជាងពូជដំណាំចំណីសត្វ បន្ទាប់ពីបានដាំរួច ដូចនេះត្រូវធ្វើការកម្ចាត់ស្មៅចង្រៃចេញក្រោយពេលដាំដោយធ្វើឡើង១-២ដងគឺអាស្រ័យទៅ នឹងកម្រិតរាលដាលរបស់ស្មៅចង្រៃ ជាធម្មតាគេចាប់ផ្តើមដកស្មៅចង្រៃចេញពីដំណាំចំណីសត្វក្នុងកំឡុងពេលពីថ្ងៃទី១៥ បន្ទាប់ពីដាំរួច និងអាចធ្វើឡើងនៅលើកទី២ម្តងទៀតក្នុងកំឡុងពេលពី១០-១៥ថ្ងៃ បន្ទាប់ពីធ្វើនៅលើកទី១ លើសពីនេះដំណាំចំណីសត្វអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដុះលូតលាស់គ្របលើស្មៅចង្រៃ។





### ៣. ការស្រោចស្រព

ជាទូទៅដំណាំចំណីសត្វត្រូវធ្វើការដាំដុះនៅដើមរដូវវស្សា ការធ្វើបែបនេះក្នុងគោលបំណងប្រើប្រាស់ទឹកដើម្បីស្រោចស្រព ដំណាំចំណីសត្វក្រោយពេលដាំ ប្រសិនបើគ្មានទឹកភ្លៀង ធ្លាក់ក្នុងកំឡុងពេល២-៤ថ្ងៃ បន្ទាប់ពីដាំរួច ជាពិសេសនៅរដូវប្រាំង ត្រូវធ្វើការស្រោចស្រព រៀងរាល់២-៣ថ្ងៃម្តង ដើម្បីធ្វើយ៉ាងណាឱ្យដំណាចំណីសត្វអាចដុះលូតលាស់ សម្រាប់កាត់ផ្តល់ឱ្យសត្វស៊ីគ្រប់រដូវបាន។ ដោយឡែកចំពោះដំណាំចំណីសត្វពពូក ទ្រីលេហ្គឹម(ពពួកដើមឈើ) មិនសូវមានបញ្ហាទៅលើការស្រោចស្រពនៅរដូវប្រាំងឡើយ ព្រោះវាអាចដុះលូតលាស់បាននៅរដូវប្រាំងបាន។





### ៤. ការប្រមូលផល

គួរធ្វើការច្រូតកាត់ដំណាំចំណីសត្វលើកទី១ក្នុងកំឡុងពេលពី១០-១២សប្តាហ៍ ឬអាចធ្វើការកាត់ក្នុងរយៈពេលខ្លីជាងនេះអាស្រ័យទៅនឹងតំបន់ និងលក្ខណៈស្ថានភាពដី និងច្រូតកាត់លើកទី ២រៀងរាល់កំឡុងពេលពី២៥-៣០ថ្ងៃ បន្ទាប់ពីច្រូតកាត់លើកទី១។ ការច្រូតដំណាំចំណីសត្វគឺទាមទារនូវបច្ចេកទេសខ្ពស់ និងជាចំណុចសំខាន់បំផុតក្នុងការថែទាំដំណាំចំណីសត្វឱ្យមានការដុះលូតលាស់ដែលអាចច្រូតកាត់ផ្តល់ឱ្យសត្វស៊ីគ្រប់ រដូវ និងអាចប្រើប្រាស់បានយូរ។ ហេតុដូចនេះ ការច្រូតកាត់ដំណាំចំណីសត្វ គឺមានការពាក់ព័ន្ធទៅនឹងលក្ខណៈជីវសាស្ត្រនៃការដុះលូតលាស់ទាំងបរិមាណ និងគុណភាព មានដូចជា:

- ប្រសិនបើច្រូតកាត់ដំណាំចំណីសត្វ នៅពេលមានអាយុតិច ឬនៅពេលដំណាំចំណីសត្វខ្ចីវាផ្តល់គុណភាពចំណី(ប្រូតេអ៊ីន)ខ្ពស់ តែផ្តល់នូវបរិមាណចំណីទាប។ ចំពោះការផ្តល់ឱ្យសត្វស៊ីមានការលូតលាស់លឿន
- ប្រសិនបើច្រូតកាត់ដំណាំចំណីសត្វ នៅពេលមានអាយុច្រើន ឬចាស់ វាមានគុណភាពចំណី(ប្រូតេអ៊ីន)ទាប តែវាផ្តល់នូវបរិមាណច្រើន។ ចំពោះការផ្តល់ឱ្យសត្វស៊ីមានការលូតលាស់យឺត

• ការច្រូតកាត់ដំណាំចំណីសត្វទុកវែង ឬខ្លីពេក គឺបណ្តាលនាំឱ្យការដុះលូតលាស់សារជាថ្មីមានលក្ខណៈយឺត ឬអាចខូចខាតទាំងស្រុងក៏ថាបាន

• ប្រសិនបើទុកឱ្យដំណាំចំណីសត្វដុះលូតលាស់វែងដោយមិនបានធ្វើការច្រូតកាត់នៅរដូវខ្សត់ទឹក ជាពិសេសនៅក្នុងរដូវប្រាំងគឺបណ្តាលឱ្យដំណាំចំណីសត្វងាប់ដោយស្ថានភាពក្នុងការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់។ ដូចនេះ តម្រូវឱ្យធ្វើ ការច្រូតកាត់ដំណាំចំណីសត្វនៅចុងរដូវវស្សាទៅតាមបច្ចេកទេស ដើម្បីរក្សាទឹកនៅក្នុងដីសម្រាប់ចិញ្ចឹមជីវិតរស់ដោយរង់ចាំនៅពេលមានភ្លៀងធ្លាក់។





**ចំណុចសំខាន់ដែលត្រូវយកចិត្តទុកដាក់៖**

កន្លែងដាំដំណាំចំណីសត្វត្រូវធ្វើរបងដើម្បីការពារ កុំឱ្យសត្វដទៃចូលមកបំផ្លាញ ដូចជាសត្វគោ-ក្របី ចូលស៊ីជាន់ដំណាំចំណីសត្វ មាន់ ទា ចូលចឹកស៊ីបណ្តាលដំណាំចំណីសត្វបណ្តាលឱ្យងាប់។ ត្រូវច្រូតកាត់ដំណាំចំណីសត្វទៅតាមបច្ចេកទេស ចំពោះដំណាំចំណីសត្វប្រភេទស្មៅ ត្រូវធ្វើការច្រូតកាត់កម្ពស់ពី៥-១០ស.មពីដី។ ចំពោះដំណាំចំណីសត្វប្រភេទពពួកលេហ្គឹម ត្រូវធ្វើការច្រូតកាត់កំពស់ ពី១០-២០ស.មពីដី ព្រោះដំណាំចំណី សត្វប្រភេទនេះវាបែកខ្នែងតាមថ្នាំងនៃដើមក្នុងការលូតលាស់។ (E.Lating et al. 2000 និង Plant Resources of south Asia 1992 )

## ៥. បច្ចេកទេសកែច្នៃចំណីសត្វ

➢ **វិធីសាស្ត្រនៃធ្វើផ្អកស្មៅ** )Silage )

• អ្វីទៅដែលហៅថាផ្អកស្មៅ?

ផ្អកស្មៅ ធ្វើពីស្មៅស្រស់ ដោយដាក់ផ្អាប់ក្នុងថងប្លាស្ទិក រណ្តៅឬអាងដែលគ្មានខ្យល់ ជាចំណីបម្រុងសម្រាប់ឱ្យសត្វស៊ីនៅរដូវខ្វះចំណី ជាទូទៅគេផ្តល់ឱ្យសត្វស៊ីនៅរដូវប្រាំង។ ផ្អកស្មៅគេច្រើនអនុវត្តបង្កើតឡើងនូវរដូវសំបូរស្មៅជាទូទៅនៅរដូវវស្សា។

• **ផលប្រយោជន៍ផ្អកស្មៅ**?

- មានសារជាតុបំប៉ន និងជួយឲ្យគោក្របីលូតលាស់លឿន
- អាចរក្សាទុកបានយូរ ជាពិសេសទុកប្រើប្រាស់នៅរដូវខ្វះចំណី ។

• **ការផលិតទឹកមេផ្អកស្មៅ**

កសិករអាចផលិតបរិមាណទឹក មេផ្អក ស្មៅ ដោយខ្លួនឯង អាស្រ័យលើតម្រូវការដាក់ស្តែងផលិតផ្អកស្មៅជាចំណីគោ-ក្របី។ ទឹកមេផ្អកស្មៅនេះអាចរក្សាទុកបានត្រឹមតែ ១អាទិត្យប៉ុណ្ណោះ។

• **សមាសធាតុផលិតទឹកមេផ្អកស្ពៃ**

- ស្ពៃស្រស់ ទម្ងន់ ០,៥គីឡូក្រាម
- ស្ករ ទម្ងន់ ២ក្រាម (០,២ខាំ)
- ទឹកសុទ្ធ ចំណុះ ០,៥លីត្រ
- ដបទឹក មានចំណុះ ១លីត្រ
- ប្រដាប់វាស់កំហាប់ ប៉េហាស់ (Ph)

• **របៀបធ្វើទឹកមេផ្អកស្ពៃ**

បុកស្ពៃស្រស់ចំនួន ០,៥គីឡូក្រាមឲ្យម៉ត់រួចពូតយកទឹកស្ពៃ និងច្រោះឲ្យបានស្អាត (ថ្លាល្អ) ជាមួយតម្រងក្រណាត់ស្អាតដែលមិនមានជាប់សារធាតុផ្សេងៗ (ឧទាហរណ៍៖ ជាតិប្រៃ សាប៊ូ.....)។

• **ការធ្វើទឹកមេផ្អកស្ពៃ**

យកទឹកស្ពៃដែលច្រោះបានទៅលាយជាមួយស្ករ ០,២ខាំ និងទឹកចំណុះ០,៥លីត្រ បន្ទាប់មកច្រកចូលទៅក្នុងដបកែវស្អាត រួចបិទដបឲ្យជិតមិនឲ្យមានខ្យល់ចេញចូល។








• **ការរក្សាទុក និងត្រួតពិនិត្យពីគុណភាពទឹកមេផ្អកស្ពៃ**

ទឹកមេផ្អកស្ពៃត្រូវរក្សាទុកកន្លែងត្រជាក់ល្មម (មិនក្តៅមិនត្រជាក់) ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់មកត្រូវយកដបមកពិនិត្យមើលគុណភាព និងវាស់កំហាប់របស់ទឹកមេផ្អកស្ពៃ។ កំហាប់ល្អស្ថិតក្នុងចន្លោះពី ៣ ទៅ ៤,៥។

• **របៀបលាយមេផ្អកស្ពៃសម្រាប់ធ្វើផ្អកស្ពៃ**

យើងមិនអាចយកទឹកមេផ្អកស្ពៃមកប្រើដោយផ្ទាល់ទេ។ ទឹកមេផ្អកស្ពៃ១ដប (បរិមាណលាយខាងលើ) ត្រូវយកទៅលាយទឹកបន្ថែមចំណុះ ១០លីត្រជាមុនសិនទើបអាចលាយធ្វើជាផ្អកស្ពៃបាន។

• **របៀបធ្វើផ្អកស្ពៃ**

ការធ្វើផ្អកស្ពៃមាន ២របៀប គឺអាស្រ័យទៅតាមវត្ថុធាតុដើម និងសម្ភារៈដែលមានដូចជាៈ បរិមាណស្ពៃ, បាវជីស, រណ្តៅ ឬអាង

- **របៀបធ្វើផ្អកស្ពៃច្រកដាក់ក្នុងបាវ**

ត្រូវកាត់ ឬច្រូតស្ពៃយកមកហាលនៅក្រោមកំដៅថ្ងៃ ឬសំដឹលវាតាមរយៈខ្យល់ឱ្យស្រពាប់ឱ្យនូវសល់ជាតិទឹកប្រហែលប្រមាណ៧៥% រួចយកស្ពៃមកចញ្ច្រាំឱ្យបានខ្លីប្រមាណពី ៤-៦សម ចំពោះស្ពៃខ្ចី ឬ១-៣សម ចំពោះស្ពៃដែលមានដើមចាស់។ ស្ពៃនូវវែងដែលយើងមិនបានចញ្ច្រាំឱ្យបានខ្លីគឺវាមិនអាចឡើងមេបាន (មេធ្វើឱ្យស្ពៃទន់ ពណ៌លឿងក្រម៉ៅនិងមានក្លិនក្រអូប) បន្ទាប់ច្រកស្ពៃដែលបានចញ្ច្រាំរួចដាក់ចូលទៅក្នុងបាវទៅតាមស្រទាប់នីមួយៗ ត្រូវសង្កត់ឱ្យណែនកុំឱ្យមានខ្យល់នៅក្នុងបាវ កាលណានៅមានខ្យល់ធ្វើឱ្យស្ពៃរលួយខូច។ នៅក្នុងបាវជីសត្រូវមានថង់ប្លាស្ទិក និងត្រូវពិនិត្យមើលធ្វើយ៉ាងណាកុំឱ្យថង់រហែកដែលបណ្តាលឱ្យខ្យល់ចេញ-ចូលបាន ហើយត្រូវចងមាត់ថង់ និងបាវឱ្យបានជិតល្អ។ ផ្អកស្ពៃដែលបានដាក់ក្នុងបាវ ត្រូវបានរក្សាទុកនៅក្នុងរោង មិនត្រូវទុកនៅកណ្តាលវាលឱ្យត្រូវទឹកភ្លៀងនោះទេ

ព្រោះវាអាចធ្វើឱ្យខូចគុណភាពផ្អកស្មៅ។ សំណើមនៅក្នុងថង់អាចធ្វើឱ្យស្មៅទន់ (ឡើងមេ) បន្ទាប់ពីធ្វើរួចយើងរក្សាទុករយៈពេលប្រមាណ៣០-៤៥ថ្ងៃ រហូតដល់ស្មៅឡើងពណ៌ក្រហមព្រឿងៗ និងមានក្លិនប្រហើរក្រអូបដូចផ្លែខ្វិតទុំទើបអាចយកឱ្យគោស៊ីបាន។ ផ្អកស្មៅអាចរក្សាទុកបានក្នុងរយៈពេលពី៦-១២ខែ។ ការធ្វើផ្អកស្មៅយើងអាចរក្សាគុណភាព និងសារធាតុចិញ្ចឹមដូចស្មៅស្រស់ដែរ។



- **របៀបធ្វើផ្អកស្មៅដាក់ក្នុងរណ្តៅ**

យើងត្រូវធ្វើការជ្រើសរើសទីតាំងរណ្តៅនៅកន្លែងទីទួលខ្ពស់ ស្ងួតមិនលិចទឹក មិនជ្រាបទឹក មិនដក់ទឹក និងមិនត្រូវបានលិចដោយសារទឹកភ្លៀង ត្រូវជីករណ្តៅជម្រៅពី ១,៥- ២,០ម ទំហំអាស្រ័យទៅនឹងបរិមាណស្មៅដែលយើងមាន។ ត្រូវទ្រាប់បាតរណ្តៅដោយប្រើដុំថ្ម ឬដុំឥដ្ឋ រួចក្រាលចំបើងស្ងួតពីលើដុំថ្ម ឬដុំឥដ្ឋដែលបានទ្រាប់បាតរណ្តៅ។ មិនត្រូវទ្រាប់បាតរណ្តៅដោយប្រើក្រណាត់កៅស៊ូ ឬចាក់បេតុងនោះទេ ព្រោះមិនធ្វើឱ្យមានសំណើមនៅក្នុងរណ្តៅ គេអាចទ្រាប់ក្រណាត់កៅស៊ូ និងរៀបឥដ្ឋតាមជញ្ជាំងរណ្តៅបាន។

ចំពោះវិធីធ្វើផ្អកស្មៅអនុវត្តដូចគ្នានឹងវិធីធ្វើផ្អកស្មៅដាក់ក្នុងបាវដែរ ដោយកាត់ស្មៅយកមកសំដិលឱ្យស្រពាប់ឱ្យនូវសល់ជាតិទឹកប្រហែលប្រមាណពី៦៥-៧៥%% រួចយកស្មៅមកចញ្ច្រាំឱ្យបានខ្លីប្រមាណពី ៤-៦សម ចំពោះស្មៅខ្ចី ឬ១-៣សម ចំពោះស្មៅដែលមានដើមចាស់។ នៅពេលដាក់ស្មៅក្នុងរណ្តៅត្រូវសង្កតបង្ហាប់ឱ្យណែនម្តងមួយស្រទាប់ៗប្រមាណពី៣០-៤០សម ធ្វើរបៀបនេះរហូតដល់
ស្មៅពេញរណ្តៅ ព្រោះធ្វើរបៀបនេះ ដើម្បីកុំឱ្យមានខ្យល់នៅក្នុងរណ្តៅ។

ត្រូវគ្របមាត់រណ្តៅឱ្យបានជិតល្អ ដោយប្រើប្លាស្ទិក បន្ទាប់មកកប់ដីពីលើក្នុងកម្រាស់សមស្រប ប្រមាណពី ០,៥-១០សម។ ម្យ៉ាងទៀត យើងអាចរៀបចំអាងដើម្បីធ្វើផ្អកស្មៅបានដែរ។ របៀបធ្វើគឺអនុវត្តដូចគ្នានឹងការធ្វើផ្អកស្មៅដាក់ក្នុងរណ្តៅផងដែរ។



អាងពីដែលមានទំហំដូចគ្នាត្រូវបានសាង សង់រួច

• **ការផ្តល់ឲ្យគោ ឬក្របីស៊ី**

កសិករអាចផ្តល់ចំណីផ្កស្មៅឲ្យគោ-ក្របីស៊ីជារៀងរាល់ថ្ងៃទៅតាមបរិមាណដែលមាន។ គោក្របី ១ក្បាលអាចស៊ីផ្កស្មៅចំនួន ១គីឡូក្រាម ក្នុង១ថ្ងៃ ដោយលាយជាមួយចំណីផ្សេងៗទៀត ដូចជា ចំបើង ស្មៅ ជាដើម។ គួរផ្តល់ផ្កស្មៅដល់សត្វមេកំពុងបំបៅកូន ក្លូររាស់ និងបំប៉នសាច់លក់ជាដើម។

### ៦. ការដាំដំឡូងមីយកស្លឹកសម្រាប់ជាចំណីគោ

**គោលបំណង៖** ការផ្តល់ស្លឹកដំឡូងមីស្ងួតជាចំណីគោជួយកាត់បន្ថយការចំណាយដើមទុន និងពេលវេលាក្នុងការចិញ្ចឹមគោ-ក្របី ជាពិសេសកសិករអាចប្រើប្រាស់មើមដំឡូងមីជាចំណីអាហារផ្ទាល់ខ្លួន និងជាចំណីសត្វដ៏ល្អ។ ការប្រើប្រាស់ស្លឹកដំឡូងមីស្ងួតជាចំណីគោ ជួយធ្វើឲ្យចំណីមានគុណភាពល្អ និងមានប្រូតេអ៊ីនខ្ពស់។

• **ផលប្រយោជន៍ស្លឹកដំឡូងមី**

- ផ្តល់ប្រូតេអ៊ីន សារធាតុរ៉ែ និងថាមពល
- កាត់បន្ថយពពួកប៉ារ៉ាសិតខាងក្នុង
- ជាចំណីបន្ថែមជំនួយដល់ការរំលាយអាហាររបស់សត្វទំពារអៀងការប្រមូលផលស្លឹកដំឡូងមី ។

• **ពេលវេលាប្រមូលផលស្លឹកដំឡូងមី**

ការប្រមូលផលស្លឹកដំឡូងមីសម្រាប់ធ្វើជាស្លឹកដំឡូងមីស្ងួតក្រោយពេលដាំបាន ៤ខែ និងបន្ទាប់មកទៀតអាចប្រមូលផលបាន ២ខែម្តង រហូតដល់ប្រមូលផលមើម។

• **របៀបប្រមូលផលស្លឹកដំឡូងមី**

ពេលប្រមូលផលលើកទី១ ត្រូវកាត់ដើមកម្ពស់ពីដីប្រមាណ ៣ ទៅ ៦តឹក ហើយជាបន្តបន្ទាប់ត្រូវកាត់ដើមដំឡូងមីរំកិលឡើងលើពីកន្លែងកាត់មុន ៣សង់ទីម៉ែត្រ រាល់ពេលកាត់មួយលើកៗ។



## ៧. របៀបកាប់ដើមដំឡូងមីធ្វើជាចំណីសត្វ

- **របៀបចិញ្ច្រាំស្លឹកដំឡូងមី និងរបៀបហាលថ្ងៃ**

មែកខាងចុង និងស្លឹកដំឡូងមីដែលកាច់បានត្រូវចិញ្ច្រាំឲ្យល្អិតៗ ឬកំណាត់ខ្លីៗ។

**ចំណាំ៖** កសិករមិនត្រូវទុកស្លឹកដំឡូងមីឡើងពណ៌លឿងដែលនាំឲ្យខូចគុណភាពនោះទេ។

ក្រោយពីចិញ្ច្រាំរួច ត្រូវយកមកហាលលើកម្រាលដោយពង្រាយស្តើងៗ ឲ្យបានស្ងួតល្អ។ គួរហាលលើកៅស៊ូតង់ ឬសង្កសី ឬកំរាលផ្សេងដែលឆាប់ស្ងួត។




## ៨. ចិញ្ច្រាំស្លឹកដំឡូងមីល្អិតៗ រួចហាលឲ្យស្ងួត

- **ការរក្សាទុកស្លឹកដំឡូងមីស្ងួត**

ស្លឹកដំឡូងមីស្ងួតត្រូវច្រកបាវ ឬការ៉ុងរក្សាទុកឲ្យបានល្អ។ បើស្លឹកដំឡូងមីស្ងួតមិនត្រូវទឹក ឬសំណើមទេ វាអាចទុកបានរហូតដល់ ៦ខែ ដោយមិនខូចគុណភាព។




ស្លឹកដំឡូងមីស្ងួតច្រកបាវរក្សាទុកជាចំណីគោ

- **ការផ្តល់ឲ្យគោក្របីស៊ី**

កសិករអាចយកស្លឹកដំឡូងមីស្ងួតចំនួន ២០ ទៅ ៣០គីឡូក្រាម លាយជាមួយចំបើងផ្ទាប់ចំនួន ១០០គីឡូក្រាម ឲ្យគោស៊ី។ គោក្របី ១ក្បាលអាចស៊ីស្លឹកដំឡូងមីស្ងួតចំនួន ២០០ ក្រាម ក្នុង ១ថ្ងៃ។





## ៩. ការធ្វើចំណីផ្សំតាមផ្ទះកសិករសម្រាប់ចំណីបំប៉ន (Home Made Concentrate (HMC)

### ៩.១. គោលបំណង

ចំណីផ្សំនេះមានសារជាតិខ្ពស់គ្រប់គ្រាន់ ដូចជា៖ ប្រូតេអ៊ីន វីតាមីន ថាមពល និងសារធាតុរ៉ែ ដែលធ្វើឲ្យគោក្របីលូតលាស់ធំធាត់លឿន ឆាប់រកឈ្មោល មានកម្លាំងមាំមួន។





កសិករអាចទិញគោស្គមៗ មកចិញ្ចឹមបំប៉នសម្រាប់លក់បន្ត

### ៩.២. ការប្រើប្រាស់

ចំណីនេះជាចំណីបំប៉នបន្ថែមក្រោយពីគោក្របីបានស៊ីស្មៅ និងចំបើងរួចហើយ។ កសិករមិនត្រូវផ្តល់ឲ្យសត្វស៊ីពេញមួយថ្ងៃលើសចំនួនកំណត់នោះឡើយ។ ចំណីនេះអាចទុកបានរយៈពេលវែងប្រសិនបើកុំឲ្យប៉ះទឹក ឬសើម។

### ៩.៣. ការធ្វើស្លឹកដំឡូងមី និងចំណិតមើមដំឡូងមីស្ងួត

ដូចគ្នានឹងការផលិតស្លឹកដំឡូងមីស្ងួតដែរ គឺស្លឹក និងចុងដំឡូងមីត្រូវចិញ្ច្រាំឲ្យល្អិតរួចហាលឲ្យស្ងួត។ ចំណែកមើមដំឡូងត្រូវចិតស្តើងៗរួចហាលឲ្យស្ងួតល្អ។ ស្លឹក និងមើមដំឡូងមីស្ងួតច្រកទុកក្នុងបាវ ឬការ៉ុងដើម្បីទុកលាយជាមួយចំណីផ្សំផ្សេងៗទៀត សម្រាប់បំប៉នគោក្របី។



ការហាលស្លឹកដំឡូងមី



ការហាលចំណិតមើមដំឡូងមី

## ៩.៤. រូបមន្តលាយចំណី

- ចំណិតមើមដំឡូងមីស្ងួត ៧ គីឡូក្រាម
- ស្លឹកដំឡូងមីស្ងួត ៣ គីឡូក្រាម
- កន្ទក់ ១២ គីឡូក្រាម
- ជីអ៊ុយរ៉េ ៣០០ ក្រាម (៣ខាំ)
- អំបិល ២៥០ ក្រាម (២,៥ ខាំ)
- ស្ករ ២៥០ ក្រាម (២,៥ ខាំ)
- ទឹក ២៥០ ក្រាម (២,៥ ខាំ)

***ចំណាំ៖*** ចំពោះស្ករ និងទឹក ត្រូវកូរលាយគ្នាឲ្យសព្វជាមុន រួចប្រោះ ឬលាស់លើចំណីផ្សំ ហើយកូរច្របល់ឲ្យសព្វ។



ការច្របល់ចំណីផ្សំចូលគ្នា

## ៩.៥. របៀបផ្តល់ចំណី

- មេធើម និងមេកំពុងបៅដោះកូន៖ ឲ្យស៊ី ៣០០ក្រាម (៣ខាំ) ក្នុង១ក្បាល ក្នុង១ថ្ងៃ
- គោរួសទាញ (ទឹម) និងគោបំប៉នយកសាច់៖ ៥០០ក្រាម (៥ខាំ) ទៅ ១គីឡូក្រាម ក្នុង១ក្បាល ក្នុង១ថ្ងៃ។



## ១០. ការធ្វើចំបើងផ្ចាប់

ស្មៅសម្រាប់គោ-ក្របីស្ទើរគ្រប់កន្លែងមានការខ្វះខាតពិសេសនៅរដូវប្រាំង ដូច្នេះកសិករត្រូវកែច្នៃចំណីដែលមានឲ្យមានរសជាតិ និងមានសារជាតិចិញ្ចឹមគ្រប់គ្រាន់។ ការផ្តល់ចំបើងធម្មតាតែមួយមុខមិនអាចជួយឲ្យគោក្របីទទួលបានសារជាតិគ្រប់គ្រាន់សម្រាប់លូតលាស់ឡើយ ព្រោះវាគ្រាន់តែជួយឲ្យបានត្រឹមបំពេញក្រពះ និងបំបាត់ឃ្លានតែប៉ុណ្ណោះ។ តាមការពិសោធន៍ និងអនុវត្តលើការកែច្នៃចំបើងផ្ចាប់របស់លោកសាស្ត្រាចារ្យ **មេតា វ៉ាណាផាត់** (Prof. Metha Wanaphat) បានទទួលជោគជ័យលើការចិញ្ចឹមគោក្របីឲ្យបានលូតលាស់ល្អ។



### ១០.១. គុណប្រយោជន៍ចំបើងផ្ចាប់

តាមរយៈការពិសោធន៍បង្ហាញថា៖

ក. ចំបើងស្ងួតធម្មតាមានប្រូតេអ៊ីន ២% ទៅ ៤% ចំណែកចំបើងផ្ចាប់មាន ៨% ទៅ ១០% និងបន្ថែមអាម៉ូញ៉ាក់នីត្រូសែន ក្នុងក្រពះគោទៅតាមតម្រូវការ

ខ. បន្ថែមការរំលាយអាហារ (ចំបើងស្ងួត) បានរហូតដល់ ១០% ទៅ ១៥%

គ. គោស៊ីចំបើងច្រើនជាងមុន ៣០% ទៅ ៤០%

ឃ. គោមានកំលាំងខ្លាំងសម្រាប់អូសទាញបានល្អ

ង. ផ្តល់ចំបើងផ្ចាប់ជាមួយចំណីគ្រាប់ ធ្វើឲ្យគោមានការធំធាត់លឿន។

- តើបច្ចេកទេសនៃការកែច្នៃចំបើងផ្ចាប់ជាចំណីបំប៉នគោក្របីយ៉ាងដូចម្តេច?

**ឧបករណ៍ និងសម្ភារៈសម្រាប់កែច្នៃ ក្នុងចំបើង ១០០គីឡូក្រាម**

| | |
|---|---|
| • ចំបើង ១០០ គ.ក្រ | • ក្រណាត់គង់ ឬក្រណាត់កៅស៊ូ ឬអាង |
| • ទឹក ១០០ លីត្រ | • ជីអ៊ុយរ៉េ ២ គ.ក្រ |
| • ធុងទឹកមានចំពួយផ្កាឈូក | • កំបោរស (កំបោរថ្ម) ២ គ.ក្រ |
| • ជញ្ជីង | • ខ្សែសម្រាប់ចងចំបើង |

- **វិធីធ្វើចំបើងផ្អាប់**

១. លាយជីអ៊ុយរ៉េ ២គ.ក្រ និងកំបោរថ្ម ២គ.ក្រ ជាមួយទឹក ១០០លីត្រ រួចកូរឲ្យសព្វ ។

២. រៀបចំបើងជាស្រទាប់ក្នុងអាង ឬថង់ បន្ទាប់មកស្រោចទឹកជីអ៊ុយរ៉េពីលើ។ ត្រូវធ្វើដូចគ្នារហូតដល់អស់ចំបើង ១០០គ.ក្រ។

៣. ចងមាត់ថង់ ឬគ្របមាត់អាងឲ្យជិត ដោយមិនឲ្យទឹកភ្លៀងហូរចូល ។

៤. ផ្អាប់ទុករយៈពេល ១០ថ្ងៃទើបយកមកឲ្យគោក្របីស៊ី។ ត្រូវយកឲ្យស៊ីតាមស្រទាប់ចំបើង ហើយពេលយកចេញរួចត្រូវគ្របវិញឲ្យបានត្រឹមត្រូវ។





*សំគាល់៖* ប្រសិនបើកចំហរ ធ្វើឲ្យចំបើងហើរក្លិន ព្រមទាំងរក្សាមិនបានយូរ។



គម្រៀប និងជាន់បង្អាប់ចំបើង




ស្រោចទឹកជីអ៊ុយរ៉េលើចំបើង



គ្របកៅស៊ូលើអាងចំបើងដើម្បីផ្ទាប់ចំបើង



ផ្ទាប់ចំបើងដោយស្រោបថងប្លាស្ទិក

**ចំបើងផ្ទាប់ដែលល្អមានលក្ខណៈដូចជា៖**

ក. មានពណ៌ក្រហមចាស់ បើប្រៀបធៀបជាមួយចំបើងធម្មតា

ខ. មានក្លិនក្រអូបឈ្ងួល

គ. មានសំណើមប្រមាណ ៤០% ទៅ ៥០%

ឃ. មានលក្ខណៈទន់គួរឲ្យចង់ស៊ី

ង. មិនមានដុះផ្សិត (ប្រសិនបើមានដុះផ្សិត ត្រូវយកទៅហាលថ្ងៃ) ។

- **ការផ្តល់ឲ្យគោក្របីស៊ី**

កសិករអាចធ្វើចំបើងផ្ទាប់បន្តបន្ទាប់គ្នា ដើម្បីឲ្យស៊ីបានយូរ។ បើមានផ្សិតច្រើន ត្រូវយកចំបើងហាលថ្ងៃឲ្យស្ងួតមុនឲ្យស៊ី។ ចំបើងផ្ទាប់នៅសល់ពីស៊ី ត្រូវយកទៅលាយជាមួយចំបើងថ្មី ព្រោះវាចំណេញពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

- ត្រូវដាក់ចំបើងផ្ទាប់ឲ្យគោស៊ីបន្តិចម្តងៗ ហើយវានឹងស៊ីច្រើនឡើងៗ ក្នុងរយៈពេល ៣ ទៅ ៤ថ្ងៃ យើងអាចឲ្យគោស៊ីឲ្យឆ្អែតជារៀងរាល់ថ្ងៃដោយលាយជាមួយចំបើងធម្មតា
- ផ្តល់ចំបើងផ្ទាប់ឲ្យគោស៊ីពេលយប់ច្រើនជាងពេលថ្ងៃ
- ត្រូវដាក់ទឹកឲ្យគោផឹករហូត ក្នុងពេលដាក់ចំបើងផ្ទាប់ឲ្យគោស៊ី ។



ដាក់ចំបើងផ្ទាប់ឲ្យគោស៊ី

# ជំពូកទី៤
# សុខភាព ជំងឺគោ ជំងឺឈាមខ្មៅ

ជំងឺឈាមខ្មៅ ជាជំងឺកាចសាហាវបំផុតដែលកើតឡើងនៅពាសពេញពិភពលោក ជាពិសេសកើតមានឡើងចំពោះសត្វមានឈាមក្តៅ ស្ទើរតែទាំងអស់ដូចជា គោ ក្របី ចៀម ពពែ ជ្រូក សេះ ព្រមទាំងមនុស្សផងដែរ។ ជំងឺនេះមានលក្ខណៈជាពីសវាលដាលពេញក្នុងខ្លួន ហើយគេសង្កេតឃើញសត្វងាប់យ៉ាងឆាប់រហ័ស ដោយមានឈាមខាប់ពណ៌ខ្មៅហូរចេញតាមរន្ធធម្មជាតិទាំងឡាយដូចជា រន្ធច្រមុះ រន្ធគូថ និងតាមមាត់។ល។ សត្វងាប់ក្នុងពេលប្រហែល២៤ម៉ោងដោយគ្មានរោគសញ្ញាជាក់លាក់។ ម្យ៉ាងទៀតសត្វអាចងាប់ក្នុងពេលពីរទៅបីម៉ោង ដោយមានរោគសញ្ញាអាចកំណត់បាន។ ដោយឡែកការព្យាបាលមិនអាចធ្វើបាន ប៉ុន្តែការធ្វើរោគវិនិច្ឆ័យឲ្យបានល្អវាមានសារៈសំខាន់ណាស់ដើម្បីការពារគោ-ក្របីផ្សេងទៀតកុំឱ្យប៉ះពាល់ជាមួយសត្វដែលងាប់។




## ១. មេរោគបង្កជំងឺ និងការចម្លង

បង្កដោយបាក់តេរីឈ្មោះថាបាក់ស៊ីលុស អង់ត្រាក់ស៊ីសគោ-ក្របី ឆ្លងមេរោគតាមរយៈដី ជំងឺនេះអាចចម្លងមកមនុស្សតាមរយៈការប៉ះពាល់ផ្ទាល់ ដកដង្ហើម ឬតាមមាត់ គឺនៅពេលស៊ីសាច់ ចំណី ផឹកទឹក ឬរបស់អ្វីមួយដែលលាយឡំដោយស្ព័រ ឬបាក់តេរីរស់នៅ។ សាកសពរបស់សត្វស្លាប់ដោយសារជំងឺឈាមខ្មៅ គឺជាប្រភពនៃការចម្លងជំងឺ ព្រោះសត្វដទៃទៀតអាចទៅស៊ីសាច់សត្វដែលងាប់ដោយជំងឺ ឬជួនកាលមនុស្សយើងក៏វះយកសាច់សត្វដែលកើតជំងឺនេះមកបរិភោគ។ ម្យ៉ាងទៀត កន្លែងដែលចម្លងជំងឺដ៏ខ្លាំងនោះគឺនៅកន្លែងដែលធ្វើការវះកាត់សាកសពសត្វ ព្រោះចំណែកសាកសពសត្វដែលបានធ្វើការវះកាត់ដូចជា សាច់ ឆ្អឹង ស្បែក ឈាម និងកម្ទេចកំទីផ្សេងៗនៃសត្វដែលនៅរាយប៉ាយអាចធ្វើឱ្យមេរោគរស់នៅ និងប្រមូលផ្តុំ ឬរីករាលដាលឆ្លងពីតំបន់មួយទៅតំបន់មួយនៅក្នុងប្រទេសតាមរយៈសត្វឆ្កែ ក្អែកត្មាត និងខ្យល់។ល។ ដែលនាំសំដែលជាភ្នាក់ងារចម្លងមេរោគដ៏មានប្រសិទ្ធភាព។

## ២. រោគសញ្ញា

សត្វកើត ឬឆ្លងជំងឺនេះ ការបង្ករោគមានរយៈពេលពី១-២សប្តាហ៍។ ចំពោះសត្វពាហនៈ រោគសញ្ញានៃជំងឺឈាមខ្មៅអាចចែកចេញជា ២សណ្ឋាន គឺសណ្ឋាន ស្រួចស្រាវបំផុត និងសណ្ឋានស្រួចស្រាវ។

### ក. សណ្ឋានស្រួចស្រាវបំផុត

សត្វកើតជំងឺដែលមានសណ្ឋានស្រួចស្រាវបំផុតគេង្កេតឃើញសត្វស្លាប់ មានសភាពធម្មតាដោយគ្មានបង្ហាញនូវរោគសញ្ញាអ្វីសោះ ឬមុនសត្វស្លាប់រវាង១-២ម៉ោង គេសង្កេតឃើញសត្វអាចបង្ហាញនូវរោគសញ្ញាខ្លះដូចជា៖

- សត្វមានសភាពគ្រុនក្តៅញាក់ញ័រ
- ភ្នាសស្តើងទាំងឡាយនៃសត្វមានស្នាម ឈាមពណ៌ក្រហមជាំ
- ក្រោយពេលសត្វស្លាប់មានហូរឈាមពណ៌ខ្មៅ-ពីមាត់និងទ្វារធំបន្ទាប់ពីងាប់ភ្លាមខ្លួនគោ មានសភាពទន់យូរជាងគោក្នុងករណីមិនស្វូវស្រួច ស្រាវ
- ចុះខ្សោយយ៉ាងខ្លាំង និងគ្រុនក្តៅរហូតដល់៤១,៥អង្សាសេ
- ពិបាកដង្ហើម
- មានឈាមក្នុងទឹកនោម ទឹកដោះ លាមកមានចលនាមិននឹង និងប្រកាច់ ។






### ខ. សណ្ឋានស្រួចស្រាវ

សត្វដែលកើត ឬឆ្លងជំងឺឈាមខ្មៅអាចរស់បានក្នុងរយៈពេលប្រហែល ២ថ្ងៃ ប៉ុន្តែវាស្ថិតក្នុងសភាពល្វិតល្វៃ ហើយសីតុណ្ហភាពក្នុងខ្លួនសត្វឡើងខ្ពស់ ភ្នាសស្តើងទាំងឡាយរបស់សត្វឡើងពណ៌ក្រហម និងមានហូរឈាម។ ចំពោះសត្វមេបំបៅកូន ទឹកដោះរបស់វាមានលាយឈាម មានដុំពកពាសពេញខ្លួន រលូតកូន រោគ ឬមូលមានលាយឈាម។ល។ សត្វកើតជំងឺឈាមខ្មៅនេះ នៅពេលស្លាប់ខ្លួនរបស់វាមិនរឹងក្រញ៉ង់ដូចសត្វដែលស្លាប់ដោយសារផ្សេងៗទៀតនោះទេ។ សត្វដែលស្លាប់ដោយសារជំងឺនេះ ឈាមរបស់វាមានសភាពខាប់ពណ៌ខ្មៅ ដែលបានជ្រាបចេញតាមរន្ធធម្មជាតិទាំងឡាយ និងតាមរន្ធស្បែក។ ចំពោះការស្លាប់នេះគឺបណ្តាលមកពីជាតិពុលដែលបង្កឡើងដោយពពួកបាក់តេរី។ សត្វកើតជំងឺនេះ គេពិនិត្យសត្វឃើញមានដុំពកនៅក្រោមស្បែក ត្រង់បំពង់ក កញ្ចឹងក និងពោះសត្វមានកម្តៅខ្លាំង(៤០អង្សាសេ) ពិបាកដកដង្ហើម ហើយអាចស្លាប់ក្នុងរយៈពេលពី ៣-៤ថ្ងៃ។

## ៣. ស្លាកស្នាម

មិនត្រូវវះកាត់សាកសពគោ ដែលស្លាប់ដោយជំងឺ ឈាមខ្មៅនោះទេ ព្រោះឈាមរបស់សត្វដែលស្លាប់ នឹងសាយភាយមេរោគយ៉ាងច្រើនក្នុងដី។ មេរោគ នឹងបំប្លែងជាស្ព័រហើយរស់ក្នុងដីបានច្រើនឆ្នាំ។ ការផ្ទុះជំងឺភាគច្រើនកើតក្នុងកន្លែងដែលសត្វធ្លាប់ស្លាប់ដោយជំងឺឈាមខ្មៅពីពេលមុន។

## ៤. ការព្យាបាល

សត្វកើតជំងឺឈាមខ្មៅនេះ យើងអាចព្យាបាលដោយប្រើពពួកអង់ទីប៊ីយ៉ូទិចបាន និងយ៉ាងមានប្រសិទ្ធភាពបន្ទាប់ពីកំណត់សម្គាល់ឃើញមានរោគសញ្ញានៃជំងឺនេះបានភ្លាមៗ និងប្រសិនបើគេបានប្រើប្រាស់ទាន់ពេលវេលា ហើយត្រូវធ្វើការព្យាបាលឲ្យលឿនជាមួយនឹងពពួកប៉េនីស៊ីលីន ប៉ុន្តែជាទូទៅពេលដែលរោគសញ្ញាត្រូវបានកំណត់វាច្រើនយឺតពេលរួចទៅហើយ។ ការព្យាបាលត្រូវកំណត់ធ្វើឡើងក្នុងរយៈពេល ៦ថ្ងៃជាប់ៗគ្នា។

# ៥. ការការពារ និងការហាមឃាត់

## ក. ការការពារ

ក្នុងការទប់ស្កាត់កុំឱ្យសត្វកើត ឬឆ្លងជំងឺឈាមខ្មៅនេះ យកល្អត្រូវធ្វើការចាក់វ៉ាក់សាំងការពារសត្វគឺមានប្រសិទ្ធភាពណាស់ ប៉ុន្តែដើម្បីឲ្យមានភាពស៊ាំពេញលេញត្រូវការពេលពី១០ទៅ១៤ថ្ងៃ ទើបវ៉ាក់សាំងបង្កើតភាពស៊ាំនៅក្នុងខ្លួនសត្វ ដើម្បីប្រឆាំងទប់ទល់ជាមួយមេរោគពីមជ្ឈដ្ឋានខាងក្រៅបាន ហើយភាពស៊ាំនោះវានឹងស្ថិតនៅបន្តរហូតរយៈពេល១ឆ្នាំ។ នៅតំបន់ដែលធ្លាប់មានកើតជំងឺឈាមខ្មៅ ត្រូវធ្វើការចាក់វ៉ាក់សាំងការពារជំងឺនេះជារៀងរាល់ឆ្នាំជាការចាំបាច់បំផុត។ ការចាក់វ៉ាក់សាំងការពារជំងឺនេះក្នុងរយៈពេល៣-៤ឆ្នាំជាប់ៗគ្នាអាចកម្ចាត់ជំងឺឆ្លងមួយចំនួនធំពីតំបន់ធ្លាប់កើតជំងឺឈាមខ្មៅនេះ។ គោដែលប្រឈមគ្រោះថ្នាក់(ដូចជាគោដែលស៊ីស្មៅនៅតាមវាលស្មៅរួមដែលមានសត្វឈឺបានស្លាប់ដោយជំងឺឈាមខ្មៅនៅទីនោះ) ត្រូវធ្វើការព្យាបាលជាបន្ទាន់ជាមួយនឹងអង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពវែងដើម្បីបញ្ឈប់ការជ្រៀតចូលរបស់មេរោគ។

ត្រូវធ្វើការចាក់ការពារពី៧ទៅ១០ថ្ងៃ បន្ទាប់ពីការព្យាបាលដោយបានប្រើប្រាស់អង់ទីប៊ីយ៉ូទិករួច (ថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រូវប្រើក្នុងពេលជំណាលគ្នានឹងធ្វើវ៉ាក់សាំងនោះទេ)។

## ខ. ការហាមឃាត់

- ត្រូវផ្អាកសត្វកុំឱ្យដើរស៊ីស្មៅ ផឹកទឹកនៅតាមវាលស្មៅសាធារណៈ ឬតំបន់ដែលផ្ទុះជំងឺឈាមខ្មៅនេះ
- ត្រូវបង្ខាំងសត្វឈឺឱ្យនៅដោយឡែកពីសត្វជា (មិនឈឺ) ដើម្បីធ្វើការព្យាបាល ដោយផ្តល់ចំណី និងទឹកស្អាតដល់សត្វ
- ជៀសវាងកុំប៉ះពាលដោយផ្ទាល់នូវអ្វីដែលហូរចេញពីខ្លួនសត្វ ដែលកើត ជំងឺឈាមខ្មៅ។ សាក សព និងសម្ភារៈចម្លងមេរោគដូចជាចំណី កម្រាលសត្វដេក ខ្សែកន្ទះ។ល។ ត្រូវកប់ចោលក្នុងរណ្តៅយ៉ាងជ្រៅ ឬដុតបំផ្លាញចោលទាំងអស់។ ជាពិសេសមនុស្សដែលមានមុតស្នាម របួស របកស្បែក។ល។ ត្រូវមានការប្រុងប្រយ័ត្នជាទីបំផុត គឺមិនត្រូវទៅប៉ះពាល់ផ្ទាល់ជាមួយសត្វកើតជំងឺឈាមខ្មៅនេះឡើយ
- ពេលពិនិត្យសាកសពសត្វកើតជំងឺនេះ មិនត្រូវធ្វើការវះកាត់សាកសពសត្វឡើយ ព្រោះមេរោគអាចសាយភាយតាមរយៈនៃការវះកាត់ ឬតាមរយៈសត្វឆ្កែ កណ្តុរ និងសត្វផ្សេងៗមកប៉ះបំណែកសាកសពទៅស៊ី
- សត្វស្លាប់ដោយជំងឺនេះត្រូវដុត ឬកប់ក្នុងរណ្តៅជំរៅយ៉ាងតិចឱ្យ បាន ២ម៉ែត្រដោយបាចកំបោរសពីលើ
- ហាមដាច់ខាតក្នុងការវះកាត់សត្វឈឺ ឬស្លាប់ដោយជំងឺឈាមខ្មៅ
- ហាមដាច់ខាតក្នុងការវះកាត់សាកសពសត្វយកទៅលក់ និងបរិភោគ។





# ៦. ជំងឺដែលកើតទៅលើសត្វគោ

## ១. ជំងឺបូសខ្យល់

### ១. ជំងឺបូសខ្យល់ជាអ្វី ?

ជំងឺបូសខ្យល់ គឺជាជំងឺឆ្លងមានលក្ខណៈធ្ងន់ធ្ងរ ជំងឺនេះត្រូវបានបង្កឡើង ដោយពពួកបាក់តេរី Clostridium Chauvoei ដែលបង្កើតជាស្ព័រនៅក្នុង និងក្រៅសារពាង្គកាយបណ្ដាលឱ្យសត្វឈឺយ៉ាងរហ័ស ហើយលក្ខណៈពិសេសនៃជំងឺគឺគ្រុនក្ដៅ និងហើមក្នុងសាច់ដុំ។ ចំពោះសត្វដែលប្រឈមនឹងជំងឺនេះរួមមានៈ គោ-ក្របី ចៀម ពពែ និងជ្រូក ជំងឺនេះច្រើនកើតមានទៅដោយតំបន់ ជាពិសេសកើតនៅរដូវភ្លៀងធ្លាក់។ សត្វទទួលរងនូវជំងឺនេះគឺបណ្ដាលឱ្យសត្វស្លាប់យ៉ាងឆាប់រហ័សក្នុងរយៈពេលពី២-៣ម៉ោង ដោយមិនបញ្ចេញនូវរោគសញ្ញាអ្វីឡើយ។ ជំងឺនេះច្រើនកើតនៅលើគោ-ក្របីដែលមានអាយុពី៦ខែ-៣ឆ្នាំ ហើយសត្វដែលផ្ទុកមេរោគបង្កជំងឺនេះ ហាក់ដូចជាមានសុខភាពល្អធម្មតា។




### ២. មូលហេតុបង្កជំងឺ

ជំងឺបូសខ្យល់ គឺជាជំងឺបង្កដោយពពួកបាក់តេរីឈ្មោះថា ក្លូស្ត្រីឌីយ៉ូមសូវេអ៊ី (Clostridium Chauvei) បង្កើតជាស្ព័រ ហើយស្ព័ររបស់វាធន់ទៅនឹងកម្ដៅ និងវាអាចរស់បានយូរនៅក្នុងដី។ នៅក្នុងលក្ខខ័ណ្ឌសមស្របវាអាចរស់នៅជាមធ្យមបានពី៤-៥ឆ្នាំ ឬអាចរស់បានរហូតដល់ទៅ១១ឆ្នាំ។ នៅក្នុងសាច់ធ្វើងៀតវាអាចរស់នៅបានយ៉ាងតិច៨ឆ្នាំ។ ក្នុងសាច់ប្រលាក់អំបិលវាអាចរស់នៅបានរយៈពេល២ឆ្នាំ និងក្នុងសម្ភារៈ ឬសម្រាមស្អុយរលួយវាអាចរស់នៅបានរយៈពេល ៦ខែ។

### ៣. ការចម្លងជំងឺ និងការរាលដាលនៃជំងឺ:

ការចម្លងជំងឺកើតឡើងនៅពេលសត្វបានដើរស៊ីស្មៅខ្ចីនៅពេលមានភ្លៀងធ្លាក់ ដំបូងប្រលាក់ដីដែលមានមេរោគ និងចម្លងតាមមុខរបួស ហើយមេរោគបង្កជំងឺនៅពេលឆ្លងចូលក្នុងខ្លួនសត្វ វាបានធ្វើដំណើរតាមប្រព័ន្ធសរសៃឈាម ហើយចូលទៅរស់នៅគ្រប់សរីរាង្គ ជាពិសេសសាច់ដុំចលនានៃដងខ្លួនសត្វ ហើយ មេរោគបង្កជំងឺបានបញ្ចេញជាតិពុល (អុកស៊ីតុកស៊ីន) ធ្វើឱ្យសរីរាង្គសត្វមួយចំនួនដូចជាៈ ថ្លើម សួត បេះដូង និងតម្រងនោមក្លាយជាជាំដំបៅរលួយ។

### ៤. រោគសញ្ញា:

ជំងឺបូសខ្យល់ ភាគច្រើនកើតនៅលើសត្វដែលមានអាយុចាប់ពី ៦ខែ ទៅ ៣ឆ្នាំ ប៉ុន្តែសត្វដែលមានអាយុតិច ឬច្រើនជាងអាយុដែលបានកំណត់ខាងលើក៏អាចកើតជំងឺនេះផងដែរ ប្រសិនបើវារស់នៅក្នុងហ្វូងជាមួយគ្នា។ សត្វកើតជំងឺជារឿយៗភាគច្រើនងាប់ដោយពុំបានបង្ហាញនូវរោគសញ្ញាអ្វីឡើយ សត្វងាប់យ៉ាងលឿនក្នុងរយៈពេលពី១២ទៅ៤៨ម៉ោង។ ក្នុងករណីជាច្រើន សត្វត្រូវបានគេឃើញងាប់ដោយគ្មានសង្កេតឃើញមានឈឺពីមុន ហើយរោគសញ្ញាគួរឱ្យគត់សម្គាល់នោះគឺសត្វមានអាការៈឡើងកម្ដៅប្រមាណពី៤០-៤១អង្សាសេ កម្លាំងចុះខ្សោយ ពិបាកដកដង្ហើម ដីពចរដើរញាប់

និងពិបាកធ្វើចលនា សត្វមានការហើមនៅតាមសាច់ដុំស្មា ត្រគាក ក ទ្រូង និងខ្នង។ ជាដំបូងយើងត្រូវពិនិត្យឃើញនៅកន្លែងហើមនេះ មានសភាពដុំពកតូចៗមានកម្តៅ និងមានការឈឺចាប់ខ្លាំង។ បន្ទាប់មួយរយៈក្រោយមកដុំហើមតូចៗនោះរីកឡើងធំ នៅពេលយើងធ្វើការប៉ះនៅត្រង់កន្លែងដុំហើមនោះវាមានសភាពត្រជាក់ ហើយសត្វដូចជាគ្មានការឈឺចាប់ឡើយ(សាច់ដុំត្រូវបានបាត់បង់ភាពរស់) និងមានសំឡេងលាន់ដូចមានខ្យល់នៅខាងក្នុង។ នៅលើមុខកន្លែងដុំហើមនោះមានឡើងជាំពណ៌ខ្មៅស្ងួតហើយមានក្លិនជូរ។ ក្រពេញកូនកណ្តុរនៅក្បែរៗនោះក៏រីកឡើងធំផងដែរ។

- **ករណីមិនសូវស្រួចស្រាវ**
  - ខ្វិកជើងធ្ងន់ធ្ងរ
  - ការហើមដែលមានឮសម្លេងប្រែសៗវិវត្តក្នុងសាច់ដុំត្រគៀក ក និងស្មារ
  - ដំបូងការហើមមានទំហំតូច ក្តៅ និងមានការឈឺចាប់
  - ស្បែកចាប់ផ្តើមត្រជាក់ និងស្ងួត
  - សាច់ដុំដែលទទួលផលប៉ះពាល់ផ្លាស់ប្តូរពណ៌ពីក្រហមចាស់ទៅជាខ្មៅ និងឡើងដូចអេប៉ុងដែលផ្តល់នូវអារម្មណ៍ដែលមានសំឡេងប្រែសៗពេលដែលសង្កត់លើសាច់ដុំ។



ស្លាកស្នាមហើមជើង និងការវាស់កម្តៅឡើងខ្ពស់



**ស្នាមជាំឈាមពណ៌ខ្មៅនៅលើស្រទាប់ភ្នាសក្រោមស្បែក**



ស្នាមជាំឈាមនៅលើសាច់ដុំ



ស្នាមជាំឈាមនៅស្រទាប់ភ្នាសសាច់ដុំនៃបេះដូង

## ៥. វិធានការការពារ

- ត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីជំនាញបសុពេទ្យ ឬអាជ្ញាធរដែលនៅជិតលោកអ្នក
- ត្រូវធ្វើអនាម័យនៅកន្លែងចិញ្ចឹមជាប្រចាំ
- ជៀសវាងយកសត្វ ឬផ្តល់ចំណីពីប្រភពកន្លែងផ្ទុះជំងឺ
- ហាមចលនាសត្វចេញ ចូល ឆ្លងកាត់នៅតំបន់ផ្ទុះជំងឺ
- ហាមទិញ លក់សត្វ និងផលិតផលពីសត្វឈឺ ឬងាប់ដោយសារជំងឺ
- ត្រូវដុត ឬកប់សាកសពសត្វឈឺ ឬងាប់ដោយសារជំងឺឱ្យបានជ្រៅ។

## ៦. ការព្យាបាល

នៅពេលដឹងថាសត្វឈឺភ្លាមៗ ត្រូវធ្វើឱ្យបានលឿនក្នុងដំណាក់កាលខ្ទក ជើងដែលមានការហើមក្តៅ និងឈឺចាប់ដោយចាក់ថ្នាំអំពីនីស៊ីលីន(Penicillin) ឬអាម៉ុកស៊ីស៊ីលីន(Amoxi-cillin)កម្រិតខ្ពស់ ត្រូវចាក់ក្នុងកម្រិតទ្វេដង ចាក់សាច់ដុំ និងនៅជុំវិញកន្លែងហើម។ ត្រូវធ្វើការព្យាបាលសត្វដែលមានសុខភាពល្អនៅក្នុងហ្វូងភ្លាមៗ ដើម្បីសម្លាប់មេរោគក្នុងដំណាក់កាលវាសម្ងំនៅក្នុងខ្លួនសត្វដោយប្រើអាម៉ុកស៊ីលីន(Amoxicillin)។




ថ្នាំសម្រាប់ព្យាបាល(អង់ទីប៊ីយ៉ូទិច)

## ៧. ការចាក់វ៉ាក់សាំងការពារ

ការចាក់វ៉ាក់សាំងការពារមានប្រសិទ្ធភាពដែលជាទូទៅកសិករប្រើវ៉ាក់សាំង"៧មុខ" ប្រឆាំងជំងឺបង្ករដោយក្លូស្ទ្រីឌីយ៉ូមដូចជាជំងឺបួសខ្យល់ តេតាណូស បូទុយលីស...។ល។

- គោដែលប្រឈមមុខនឹងគ្រោះថ្នាក់ (គោដែលស៊ីស្មៅនៅកន្លែងដែលធ្លាប់មានសត្វងាប់ដោយជំងឺបួសខ្យល់ពីមុន)។ ត្រូវធ្វើការព្យាបាលឱ្យបានលឿនជាមួយនឹងថ្នាំអាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពវែង (Long acting amoxicillin) ដើម្បីបញ្ឈប់ការចម្លងសម្ងំជំងឺដែលមានសក្តានុពល
- ការចាក់ថ្នាំការពារអាចធ្វើទៅបានត្រឹមតែ៧ទៅ១០ថ្ងៃបន្ទាប់ពីការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក (ថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រូវប្រើពេលដំណាលគ្នានឹងការធ្វើវ៉ាក់សាំងទេ)
- ត្រូវចាក់វ៉ាក់សាំងការពារសត្វពីការឆ្លងជំងឺលើកទី១ នៅអាយុពី២ - ៦ ខែ
- ត្រូវចាក់វ៉ាក់សាំងការពារសត្វពីការឆ្លងជំងឺវិព្ធកឡើងវិញ នៅក្រោយពេលចាក់លើកទី១ ពី២-៤អាទិត្យ។ បន្ទាប់មកត្រូវធ្វើការចាក់ឡើងវិញរៀងរាល់មួយឆ្នាំម្តង។




ថ្នាំសម្រាប់ចាក់ការពារ(វ៉ាក់សាំង)

## ២. ជំងឺសារទឹក

Hemorrhagic septicemia: (HS)

### ១- ជំងឺសារទឹកជាអ្វី?

ជំងឺសារទឹក គឺជាជំងឺឆ្លងដ៏សាហាវ បើប្រៀបធៀបទៅនឹងជំងឺឆ្លងដទៃទៀត។ ជំងឺនេះវាបង្កឡើងដោយពពួកបាក់តេរី មានឈ្មោះថា ប៉ាស្ទ័រវ៉ែឡាម៉ុលតូស៊ីដាប្រភេទបេ (Pasteurella multocida Type B)។ ពពួកបាក់តេរីនេះមានរាងជាកូនដំបងខ្លី គ្មានចលនា និងគ្មានស្ព័រ។ ជំងឺនេះច្រើនមានកើតលើសត្វពាហនៈគ្រប់ប្រភេទដូចជា គោ-ក្របី ចៀម ពពែ ជ្រូក និងសេះ។ល។ មេរោគបង្ក ជំងឺនេះ បណ្តាលឱ្យមានការរលាក និងជាំឈាមនៅតាមសរីរាង្គខាងក្នុងរបស់សត្វជាពិសេសនៅតាមប្រដាប់ដកដង្ហើម និងប្រដាប់រំលាយអាហារ។ ជំងឺនេះកើតឡើងរៀងរាល់ឆ្នាំ ជាញឹកញាប់ច្រើនកើតនៅ

រដូវភ្លៀងធ្លាក់ និងមានការរាតត្បាតខ្លាំងនៅពេលអាកាសធាតុប្រែប្រួល។ ជំងឺនេះវាមានផលប៉ះពាល់ខ្លាំងទៅលើសត្វជាកម្លាំងអូសទាញប្រើប្រាស់ហួសកម្លាំងនិងចំណីមិនគ្រប់គ្រាន់។ ចំពោះសត្វដែលបានកើតជំងឺនេះបណ្តាលឱ្យសត្វងាប់យ៉ាងឆាប់រហ័ស។

## ២. ការចម្លង និងការរាលដាល:

ជំងឺសារទឹក ឆ្លងពីសត្វមួយទៅសត្វមួយទៀតតាមរយៈប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ឬតាមរយៈភ្នាក់ងារផ្ទុកជំងឺការស៊ីស្មៅ ឬរុក្ខជាតិនៅកន្លែងធ្លាប់ផ្ទុះជំងឺ និងឆ្លងតាមរយៈខ្យល់ និងពពួកបរ៉ាសិត ដោយសារការធ្វើចរាចរសត្វមានជំងឺពីតំបន់មួយទៅតំបន់មួយទៀត។ ចំពោះសត្វក្មេងអាចទទួលជំងឺនេះយ៉ាងឆាប់រហ័ស។ ជាទូទៅជំងឺនេះគេតែងពិនិត្យឃើញសត្វឆ្លងតាមរយៈ:

- ✓ ការស៊ីចំណី ឬផឹកទឹកជាមួយសត្វឈឺ
- ✓ សាកសពសត្វដែលងាប់ដោយសារជំងឺសារទឹក គឺជាប្រភពនៃការចម្លងជំងឺ
- ✓ ដីនៅជុំវិញកន្លែងវះកាត់សាកសពសត្វនឹងក្លាយជាកន្លែងចម្លងមេរោគ។

## ៣. រោគសញ្ញា

សត្វកើតជំងឺនេះ អាចងាប់គ្មានបញ្ចេញនូវរោគសញ្ញាអ្វីទាំងអស់ ព្រោះរយៈពេលមេរោគសំងំខ្លី ហើយសត្វអាចឈឺក្រោយពេលមេរោគបានជ្រៀតចូលទៅក្នុងខ្លួនសត្វពី ២-៥ម៉ោង ក្នុងករណីខ្លះអាច២-៣ថ្ងៃ។ បន្ទាប់មកសត្វមានអាការៈគ្រុនក្តៅសីតុណ្ហភាពឡើងខ្ពស់ពី៤១-៤២អង្សា កំលាំងចុះខ្សោយ សត្វចុះស្គមយ៉ាងឆាប់រហ័ស និងមានជាំឈាមនៅតាមស្រទាប់ភ្នាសស្តើងនៃសរីរាង្គខាងក្នុងរបស់សត្វ។ ជាទូទៅគេពិនិត្យឃើញសត្វគោ-ក្របី មានហើមនៅជុំវិញក ហើយរាលដាលដល់ស្មាមុខ នៅកន្លែងហើមឡើងក្តៅមានសភាពទន់ជ្រាយ អណ្តាតហើមតឹង រួចលៀនចេញមកក្រៅហៀរទឹកមាត់ ទឹកសំបោរ ហើមពោះ ហើមនៅដើមទ្រូង និងត្រចៀក ដឹពចរ និងដង្ហើមដើរញាប់ រាគឈាមលាយជាមួយរំអិល ភ្នែកហើម និងរលាកនៅតាមស្រទាប់ភ្នាសស្តើងគ្របកភ្នែកខាងក្នុង។ ប្រសិនបើយើងពុំបានធ្វើការព្យាបាលបានទាន់ពេលវេលានោះទេ សត្វអាចងាប់ក្នុងរយៈពេលយ៉ាងខ្លីពី៦-២៤ម៉ោងតែប៉ុណ្ណោះ។



ការហើមមុខ ក្បាល និងកដោយសារការរលាកស្រទាប់ភ្នាសសរីរាង្គខាងក្នុង



ស្នាមជាំឈាមនៅស្រទាប់ភ្នាសសាច់ខាងក្នុងមាត់



ស្នាមជាំឈាមស្រទាប់ភ្នាសសាច់ខាងក្នុងនៃក



ស្នាមក្រហមអុចៗនៅបេះដូង និងសួត

## ៤. វិធានការការពារ

- ត្រូវប្រញាប់រាយការណ៍មកមន្ត្រីបសុពេទ្យ ឬអាជ្ញាធរដែលនៅជិតអ្នក
- ត្រូវបំបែកសត្វឈឺចេញពីហ្វូង
- ត្រូវធ្វើអនាម័យនៅកន្លែងចិញ្ចឹមជាប្រចាំ

- ជៀសវាងការផ្តល់ចំណីដែលមានប្រភពពីកន្លែងផ្ទុះ ឬឆ្លងជំងឺ
- ហាមចលនាសត្វចេញ ចូល ឬឆ្លងកាត់នៅតំបន់ផ្ទុះជំងឺ
- ហាមប៉ះពាល់សត្វឈឺ ឬងាប់ និងពិឃាដសត្វឈឺ ឬសត្វសង្ស័យមានជំងឺយកសាច់ទៅលក់ ឬបរិភោគ។

**៥. ការព្យាបាល**

ជំងឺនេះមានការវិវត្តលឿន ដែលជាហេតុធ្វើឱ្យគេពិបាកក្នុងការព្យាបាលឱ្យបានទាន់ពេលវេលា ព្រោះជំងឺនេះមានលក្ខណៈស្រួចស្រាវដោយសត្វងាប់លឿន។ ដោយឡែក ចំពោះការព្យាបាលគឺ យើងត្រូវប្រើថ្នាំមួយចំនួនដូចជា៖

- ត្រូវចាក់ថ្នាំស៊ុលហ្វូណាមីត(Sulfonamide)
- តេត្រាស៊ីគ្លីន (Tetracyclin (Liquamycine IV)) ដោយចាក់តាមសរសៃវ៉ែន
- ថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ត្រូវបានណែនាំឲ្យព្យាបាលជំងឺ។

ចំពោះការចាក់លើកដំបូងគឺយើងត្រូវចាក់ក្នុងកម្រិតទ្វេដង (២០ម.ក្រ/គ.ក្រ) ដើម្បីបញ្ឈប់សកម្មភាពដំណាក់កាលសំងំរបស់មេរោគ យកល្អត្រូវចាក់សត្វផ្សេងៗទៀតនៅក្នុងហ្វូង ឬសត្វរស់នៅក្នុងទ្រុងជាមួយគ្នា។

**៦. ការចាក់វ៉ាក់សាំងការពារ:**

- ចាក់ថ្នាំការពារដំបូង(លើកទី១) ចំពោះសត្វមានអាយុ៦ខែ ព្រោះសរពាង្គកាយសត្វ ពុំទាន់មានលទ្ធភាពក្នុងការបង្កើតភាពស៊ាំបានឡើយ
- បន្ទាប់មកត្រូវចាក់វ៉ាក់សាំងការពារជំងឺសត្វរៀងរាល់៦ខែម្តង ជាពិសេស ត្រូវចាក់នៅមុនពេលរដូវភ្លៀងធ្លាក់មកដល់
- យើងអាចចាក់វ៉ាក់សាំងការពារដល់មេសត្វដើម(មានផ្ទៃពោះ)នៅដំណាក់កាលចុងក្រោយ ដើម្បីបង្កើតឱ្យមានភាពស៊ាំ(អង់ទីគ័រ)ដល់កូននៅក្នុងផ្ទៃរបស់មេ។




វ៉ាក់សាំងការពារសត្វប្រឆាំងទៅនឹងជំងឺសារទឹកគោ ក្របី

## ៣. ការពុលជីអ៊ុយរ៉េ

**១. និយមន័យ**

គោត្រូវបានទាក់ទាញដោយក្លិនរបស់ជីអ៊ុយរ៉េ និងវាធ្លាប់ស៊ីបាវដែលមានសល់ថ្នាំគីមីនៅក្នុងថង់ ឬបាវ។ ម្យ៉ាងទៀតការពុលជីអ៊ុយរ៉េនេះ ក៏អាចកើតមានពេលដែលសត្វលិឍជីអ៊ុយរ៉េដែលនៅសល់ក្នុងបាវ។ បុព្វហេតុទូទៅទីពីរគឺពេល

ដែលកសិករប្រើប្រាស់បច្ចេកទេសស្រោចជីអ៊ុយរ៉េដោយផ្ទាល់លើចំបើងដើម្បីបង្កើនគុណភាពចំណី បច្ចេកទេសនេះត្រូវការឲ្យមានកម្រិតសមរម្យ។





ពេលដែលចំបើងលាយជាមួយអ៊ុយរ៉េដាក់ក្នុងរោងដើម្បីដំណើរការផ្ទាប់រយៈពេល២អាទិត្យ វាគ្មានគ្រោះថ្នាក់ទេព្រោះអ៊ុយរ៉េត្រូវបំបែកជាអាម៉ូនីញ៉ាក់

## ២. រោគសញ្ញា

រយៈពេលពីពេលដែលស៊ីជីអ៊ុយរ៉េចូលទៅដល់ពេលចេញសញ្ញាគ្លីនិក មើលឃើញខាងក្រៅគឺ២០ទៅ៦០នាទី ការស្លាប់នឹងកើតមានក្នុងកំឡុងពេល២ម៉ោង។

## ៣. សញ្ញាដំបូង

- កន្ត្រាក់ត្រចៀកនិងសាច់ដុំមុខ សង្កៀរធ្មេញ មានហៀរទឹកមាត់បែកពពុះ
- មិនអាចរក្សាលំនឹង និងកន្ត្រាក់សាច់ដុំ
- មានអាកប្បកិរិយាឆេវឆាវ
- ហើមពោះ
- ដកដង្ហើមលឿននឹងខ្លាំង។

សញ្ញាដំបូងគឺកន្ត្រាក់សាច់ដុំមុខ និងសង្កៀរធ្មេញ និងដួលប្រកាច់





## ៤. ការព្យាបាលបន្ទាន់

នៅពេលសង្កេតឃើញសត្វស៊ីថង់ប្លាស្ទិក ឬបាវជីសមានអាការៈកន្ត្រាក់សាច់ដុំមុខ និងសង្កៀរធ្មេញ ត្រូវឲ្យគោផឹកទឹកខ្មេះពី២ទៅ៥លីត្រ (ឬអាស៊ីតអាសេទិចកម្រិត ៥%)។

## ៤. ជំងឺអុតក្ដាម

Foot and Mouth Disease (FMD)

### ១. ជំងឺអុតក្ដាមជាអ្វី ?

ជំងឺអុតក្ដាម ជាជំងឺឆ្លងដែលកើតមានចំពោះសត្វដែលមានចង្កែកជើងដូចជាៈ គោ-ក្របី ជ្រូក ចៀម ពពែ....។ ជំងឺនេះបង្កឡើងដោយពពួកវីរុស(Virus) ដែលថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពក្នុងការព្យាបាលទេ។

វីរុសបង្កជំងឺនេះ មាន ៧ប្រភេទគឺ O, A, Asia1, SAT1, SAT2, SAT3 ហើយប្រភេទវីរុសបង្កជំងឺនីមួយៗ មានអនុក្រុមជាច្រើនទៀត។ នៅប្រទេសកម្ពុជាគេបានរកឃើញវីរុសបង្កជំងឺអុតក្ដាមចំនួន ៣ប្រភេទគឺ O, A និង Asia1។ ហើយប្រភេទវីរុស O, A និង Asia1 ត្រូវបានរកឃើញលើសត្វគោក្នុងប្រទេសកម្ពុជា។ ជំងឺនេះមានផលប៉ះពាល់ខ្លាំងចំពោះកូនគោ-ក្របី ដែលបណ្ដាលឱ្យងាប់ដោយដំបៅក្នុងមាត់ ក្រពះ ពោះវៀន និងចំពោះសត្វមេផើមអាចបណ្ដាលឱ្យរលូតកូន។

ម្យ៉ាងទៀត ថ្វីបើជំងឺនេះកម្រធ្វើឱ្យមានផលប៉ះពាល់ដល់សត្វធំស្លាប់ក៏ពិតមែន ប៉ុន្តែវាបានបង្កឱ្យមានផលប៉ះពាល់ដល់កម្លាំងអូសទាញ បាត់បង់ឱកាសប្រកួតប្រជែងក្នុងការធ្វើពាណិជ្ជកម្មក្នុងការនាំសត្វចេញទៅប្រទេសដែលតម្រូវការសាច់សត្វនៅលើទីផ្សារ ជាពិសេស គឺប្រទេសជិតខាងដែលជាចំណូលគ្រួសារ និងសេដ្ឋកិច្ចជាតិ។

### ២. ការចម្លង និងការរាលដាល

❖ **ការរាលដាល**

ជំងឺអុតក្ដាម ជាជំងឺដែលឆ្លងរាលដាលយ៉ាងឆាប់រហ័ស ហើយមានអត្រាសត្វឈឺខ្ពស់។ វីរុសបង្កជំងឺនេះមាននៅក្នុងវត្ថុដែលចេញពីសត្វឈឺ ឬសត្វផ្ទុកវីរុស បង្កជំងឺដូចជា ទឹកមាត់ ទឹកសំបោរ ទឹកនោម ឈាម លាមក ផលិតផលសត្វ ឬសម្ភារៈដឹកជញ្ជូន ចំណី ទឹក ខ្យល់នៅជុំវិញមជ្ឈដ្ឋានសត្វឈឺ ឬសត្វដែលមាន ផ្ទុកវីរុសរស់នៅ។ វីរុសបង្កជំងឺអាចហើរតាមខ្យល់ ហូរតាមតឹក និងតាមរយៈការ ធ្វើចលនាសត្វឈឺ ឬផ្ទុកវីរុស។ល។

❖ **ការចម្លង**

ជំងឺនេះ អាចចម្លងតាមរយៈការប្រើប្រាស់ខោអាវ ស្បែកជើង ឬសម្ភារៈ ប្រើប្រាស់ដែលប្រឡាក់ប្រឡូសជាមួយសត្វឈឺ ឬផ្ទុកវីរុសបង្កជំងឺ តាមរយៈការផ្ដល់ចំណី និងទឹកដែលប្រឡាក់ប្រឡូសជាមួយសត្វឈឺ ឬផ្ទុកវីរុសជាពិសេសនៅតាមវាលស្មៅ ឬប្រភពទឹករួម តាមរយៈមធ្យោបាយដឹកជញ្ជូនសត្វឈឺ ឬផ្ទុកវីរុស ការនាំសត្វដែលផ្ទុកវីរុសបង្កជំងឺចូលក្នុងហ្វូង និងការដាក់សត្វឱ្យនៅកន្លែង ដែលមានផ្ទុះជំងឺ។ ចំពោះវីរុសបង្កជំងឺនេះក៏អាចសាយភាយពីសត្វជ្រូកឈឺ ឬផ្ទុកវីរុស ទៅគោ ព្រោះជ្រូកបញ្ចេញបរិមាណវីរុសយ៉ាងច្រើនហើយគោងាយទទួលជំងឺនេះតាមរយៈការចម្លងតាមខ្យល់។

### ៣. រោគសញ្ញាសំខាន់ៗ

រយៈពេលសំងំនៃវីរុសបង្កជំងឺនេះមារយៈពេលពី១៨ម៉ោងទៅ ៣សប្ដាហ៍ ហើយរោគសញ្ញាដែលសង្កេតឃើញនៅពេលផ្ទុះជំងឺរួមមានៈ

- សត្វមានអាការៈគ្រុនក្ដៅ និងមិនឃ្លានចំណីដោយសារមានពងដោរបែកនៅក្នុងមាត់ដែលធ្វើឲ្យវាមានការឈឺចាប់ ហើយធ្វើឲ្យសត្វមិនអាចស៊ីចំណីបាន។ ចំពោះសត្វធំទង់ៗសីតុណ្ហភាពថយចុះមកវិញនៅក្នុង រយៈពេល៤៨ម៉ោងក្រោយ
- ពងដោរ និងដំបៅលេចចេញនៅលើមាត់ អណ្ដាត អញ្ចាញធ្មេញ ជើងធ្មេញ បបូរមាត់ (កម្រឃើញលើជ្រូក) បណ្ដាលឲ្យមានការហូរទឹកមាត់យ៉ាងច្រើនធ្វើឱ្យសត្វពិបាកស៊ីចំណី
- ពងដោរ និងដំបៅលេចចេញនៅលើក្បាលដោះ និងកន្សោមដោះ ចន្លោះសង្កែកជើង និងគល់ក្រចក ដែលធ្វើឱ្យសត្វពិបាកបំបៅដោះកូន ពិបាកឈរ និងធ្វើចលនា

- ពងបែកនេះ  បានបន្សល់ទុកនូវស្លាកស្នាមរបួសនៅកន្លែងពងបែកនោះ
- ការស្លាប់ ជាទូទៅច្រើនកើតលើកូនគោព្រោះការខូចសាច់ដុំបេះដូង
- ការរលូតកូនកើតមានជាញឹកញាប់ចំពោះសត្វមេផើម។

ចំពោះជ្រូក រោគសញ្ញាអាចខុសពីគោក្របីបន្តិច ព្រោះជ្រូកអាចមានដំបៅនៅចុងច្រមុះ ហើយអាចរបូតក្រចកជើង និងធ្វើឱ្យជ្រូកស្លាប់ភ្លាមៗចំពោះកូនជ្រូក។



ដំបៅរលួយច្រមុះ មាត់ អណ្តាត អញ្ចាញធ្មេញ ធ្វើឱ្យហៀរតឹកសំបោ និងទឹកមាត់



ដំបៅរលួយគល់ដោះនិងចុងដោះធ្វើឱ្យមេពិបាក់បំបៅកូន



ដំបៅរលួយនៅចង្អែកក្រចកជើង និងគល់ក្រចកជើងធ្វើឱ្យសត្វពិបាកធ្វើចលនា



កើតលើសត្វមេផើមបណ្តាលឱ្យរលូតកូន



កើតនៅលើសត្វមេបំបៅកូន ធ្វើឱ្យមានការពិបាកក្នុងការបំបៅកូន



កើតនៅលើសត្វជ្រូកពងបែកនៅចុងច្រមុះ និងចង្អែកក្រចកជើង ធ្វើឱ្យរបូតក្រចក



ការវិលមករកសភាពដើមបន្ទាប់ពីបានជាសះស្បើយ

## ៤. ការព្យាបាល

ជំងឺបង្កដោយវីរុស ដូចនេះគ្មានការព្យាបាលទេ ហើយមិនត្រូវធ្វើការចាក់វ៉ាក់សាំងលើសត្វឈឺទេ។ គោលបំណងនៃការព្យាបាលគឺបង្ការការជ្រៀតចូលរបស់បាក់តេរីឱកាសនិយមនៃជំងឺផ្សេងៗ
ទៀតដោយត្រូវចាក់៖

- ទ្រីមេតូព្រីមជាមួយស៊ុលហ្វា TMP+Sulfa ឬអុកស៊ីតេត្រាស៊ីគ្លីន OTC ពី៥ទៅ៧ថ្ងៃ
- លាងដំបៅជើង មាត់ជាមួយសាប៊ូ ឬសាច់ជូរ ម្ជូរ ជើងបាញ់ថ្នាំសំលាប់មេរោគ ដែលមានជាតិវីយូលេហ្សង់ត្យាន (ប្លឺមេទីឡែន) សម្រាប់ព្យាបាលកន្លែងមានដំបៅពីរដងក្នុងមួយថ្ងៃ និងប្រើអង់ទីប៊ីយ៉ូទិចដូចជា អុកស៊ីតេត្រាស៊ីគ្លីន បន្ទាប់ពីសម្អាតរួច។
- ព្យាបាលដោយលាងដំបៅជើង មាត់ជាមួយសាប៊ូ ឬសាច់ជូរ ម្ជូរ ជើងបាញ់ថ្នាំសំលាប់មេរោគ ដែលមានជាតិវីយូលេហ្សង់ត្យាន(ប្លឺមេទីឡែន និងប្រើអង់ទីប៊ីយ៉ូទិច សម្រាប់ផ្សះដំបៅ

## ៥. វិធានការជីវសុវត្ថិភាព

- ជៀសវាងការប៉ះពាល់ផ្ទាល់ ឬមិនផ្ទាល់ជាមួយនឹងសត្វឈឺ និងសត្វសង្ស័យមានផ្ទុកវីរុស
- ត្រូវបំបែកសត្វឈឺចេញពីហ្វូង
- ត្រូវធ្វើអនាម័យនៅក្នុងទ្រុង ឬចិញ្ចឹមជាប្រចាំ
- ហាមចលនាសត្វចេញ-ចូល ឆ្លងកាត់តំបន់ផ្ទុះជំងឺ
- សត្វមិនអាចដើរ ស៊ីចំណី និងផឹកទឹកបានដូច្នេះត្រូវ៖
- ផ្តល់ចំណី(ស្មៅ) និងកន្ទក់ និងទឹក
- ត្រូវដាក់សត្វឱ្យនៅក្នុងម្លប់ដើម្បីកាត់បន្ថយការខ្សោះជាតិទឹក។



ការប្រើប្រាស់វ៉ាក់សាំងមានប្រសិទ្ធភាព ហើយវាមានប្រយោជន៍ក្នុងការធ្វើវ៉ាក់សាំងគោពីរដងក្នុងមួយឆ្នាំ។ ចាំបាច់ត្រូវប្រើវ៉ាក់សាំងដែលមានវីរុសបីប្រភេទគឺអូ អា អាស៊ី១។ គោអាចវិវត្តភាពស៊ាំបានយ៉ាងលឿនបន្ទាប់ពីការចាក់វ៉ាក់សាំង។ វាមានប្រសិទ្ធភាពក្នុងការចាក់វ៉ាក់សាំងពេលដែលកសិករដឹងថាមានករណីសង្ស័យកើតជំងឺនេះនៅភូមិជិតគ្នា ឬក្នុងភូមិរបស់ខ្លួន។ ជាអកុសល វាមិនមានភាពងាយស្រួលក្នុងការទិញវ៉ាក់សាំងក្នុងសភាពបន្ទាន់ ហើយជារឿយៗអ្នកផ្គត់ផ្គង់អស់វ៉ាក់សាំងពីស្តុកយ៉ាងឆាប់រហ័សពេលដែលការផ្ទុះជំងឺអូសបន្លាយ។ ត្រូវធ្វើការចាក់វ៉ាក់សាំងជំងឺអុតក្តាមលើកទី ១ នៅពេលសត្វមានអាយុ ៤ខែឡើយទើបជាការល្អ ហើយសត្វអាចបង្កើតភាពស៊ាំនៅក្នុងខ្លួនបាន។ ត្រូវធ្វើការចាក់វ៉ាក់សាំងជំងឺអុតក្តាមលើកទី ២ ក្រោយចាក់លើកទី ១ បានរយៈពេល ១ខែ និងចាក់រំលឹកឡើងវិញរៀងរាល់ ៦ខែម្តង។






## ៥. ជំងឺផ្លូវដង្ហើម ជំងឺរលាកសួត (Pneumonia)

### ១. ជំងឺរលាកសួតជាអ្វី ?

សត្វពាហនៈទាំងអស់ងាយទទួលរងជំងឺផ្លូវដង្ហើម ប៉ុន្តែជាទូទៅវាចាប់ផ្តើមពេលដែលសត្វមានបញ្ហាស្រ្តេស។

### ២. មូលហេតុ

សភាពស្រ្តេសជាទូទៅរួមមានការផ្លាស់ប្តូរសីតុណ្ហភាព ធ្វើការអស់កម្លាំង ផ្តល់ចំណីនិងទឹកមិនគ្រប់គ្រាន់។ លក្ខខ័ណ្ឌស្ងួតនិងមានធូលីក៏អាចបង្កើនបញ្ហានេះផងដែរ។ មេរោគដែលជាប់ទាក់ទងនឹងជំងឺរលាកសួតគឺប៉ាស្ទឺរ៉េឡា។ មេរោគនេះជាធម្មតារស់នៅក្នុងផ្លូវដង្ហើមផ្នែកខាងលើ (រន្ធច្រមុះ បំពង់អាហារ និងដើមក) ប៉ុន្តែមិននៅក្នុងបំពង់ខ្យល់និងសួតទេ។ ចំពោះគោដែលមានសុខភាពល្អពួកប៉ាស្ទឺរ៉េឡាបំបែកខ្លួនយឺតៗហើយកោសិការមាក្រូហ្វា (Macrophage) និងអង់ទីគ័របំផ្លាញពួកវា។ ប៉ុន្តែក្នុងករណីសត្វមានបញ្ហាស្រ្តេសភាពស៊ាំនឹងចុះខ្សោយនិងមិនអាចគ្រប់គ្រងការរាតត្បាតរបស់ប៉ាស្ទឺរ៉េឡាលើសួតបានទេ។ លើសពីនេះប្រសិនបើផ្លូវដង្ហើមត្រូវក្រហល់ក្រហាយដោយធូលីនេះមេរោគអាចវិវត្តបានយ៉ាងស្រួល។






លទ្ធផលគឺកើតជំងឺរលាកសួត

### ៣. រោគសញ្ញា

ពេលដែលពួកប៉ាស្ទឺរ៉ែឡាត្រូវបានគេហៅវាថាប្រភេទបេ (Type B) វាបង្កជាជំងឺសារទឹកដែលធ្វើសត្វងាប់លឿន (មើលក្នុងផ្នែកជំងឺសារទឹក)។ ប្រភេទផ្សេង ទៀតរបស់ប៉ាស្ទឺរ៉ែឡាបង្កជារលាកសួតមិនស្រួចស្រាវ ប៉ុន្តែជំងឺរលាកសួតគឺគ្រប់ពេលបង្ករជាការឈឺធ្ងន់ធ្ងរដែលត្រូវធ្វើការព្យាបាលភ្លាមៗ។ ជំងឺរលាកសួតអាចទន្ទ្រានកូនគោ និងគោធំ នៅពេលសត្វកើតជំងឺនេះ សត្វបានបង្ហាញពីចង្វាក់ដកដង្ហើមកើនឡើង សត្វសភាពគ្រុនក្តៅ សីតុណ្ហភាពលើសពី៤០អង្សាសេ និងបាត់បង់ការស៊ីចំណី និងក្អកហៀរសំបោរ។



### ៤. ស្លាកស្នាម

ការកើតដំបៅរលួយធ្ងន់ធ្ងរ (សួតលែងមានសភាពយឺតតទៅទៀត) សសៃស្នារ Fibrinous (សារធាតុខាប់ស្អិត) នៃការរលាកសួតចាប់ផ្តើមវិវត្ត។




### ៥. ការព្យាបាល

ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជា តេត្រាស៊ីគ្លីន ឬ ផ្លរហ្វេនីកុល (Tetracycline, Florfenicol) ជាមួយថ្នាំប្រឆាំងនឹងការរលាកដូចជាប៉ារ៉ាសេតាម៉ុល តុលហ្វេឌីន គេតូផេន (Paracetamol, Tolfedine, Ketophen)។

# ៦. ព្រូនក្នុងសួត

## ១. និយមន័យ

ព្រូនក្នុងសួត គឺជាពពួកសត្វល្អិតដែលរស់នៅក្នុងសួត ត្រូវបានគេហៅថា ឌីកទីយោកូលុស (Dictyocaulus) ព្រូននៅក្នុងសួត បានបង្កជាជំងឺសួតលើគោដែលមានរោគសញ្ញាដូចគ្នានឹងជំងឺបង្កដោយមីក្រុប។ ជំងឺនេះបានបណ្តាលឱ្យសត្វស្លាប់បានប្រសិនបើមិនត្រូវបានធ្វើការព្យាបាលសត្វទទួលរងនៅជំងឺនេះឱ្យបានទាន់ពេលវេលានោះទេ។ ព្រូនបង្កជំងឺសួតធំពេញវ័យរស់ក្នុងទងសួតហើយផលិតស៊ុតជាច្រើន។



## ២. រោគសញ្ញា

- ក្អក
- សីតុណ្ហភាពអាចឡើងដល់៤០អង្សាសេក្នុងករណីការរំខានធ្ងន់ធ្ងរ
- ហៀរសំបោរ
- សត្វស្រេកថ្លួរ
- ជាទូទៅវាធ្វើឲ្យដងខ្លួនស្គមស្គាំង និងរោមបះ។



### ៣. ការការពារព្យាបាល

យើងត្រូវធ្វើព្យាបាលសត្វដែលបានឆ្លងព្រូនបង្កជំងឺក្នុងសួតនេះ១ដង ដោយប្រើថ្នាំទម្លាក់ព្រូន (ពពួកបរ៉ាសិតខាងក្នុង) ដូចជា:

- ថ្នាំអាល់បង់ដាសុល (Albendazole) ១០មីលីលីត្រក្នុង១០០គីឡូក្រាម
- ថ្នាំអ៊ីវែម៉ិចទីន (Ivermectine) ១មីលីលីត្រក្នុង៥០គីឡូក្រាម

ក្នុងករណីធ្ងន់ធ្ងរ(សីតុណ្ហភាពខ្ពស់ និងអស់កម្លាំង) ត្រូវប្រើថ្នាំប្រឆាំងនឹងបរ៉ាសិតរួមជាមួយថ្នាំអង់ទីប៊ីយ៉ូទិកដូចការព្យាបាលជំងឺរលាកសួតដែរ។

## ៧. ជំងឺរលាកពោះវៀន ដង្កូវថ្លើម ( fasciola )

### ១. និយមន័យ

ជំងឺបង្កដោយព្រូនហ្វាស្យូឡា គឺបណ្ដាលមកពីព្រូនសំប៉ែតពពួកត្រេម៉ាតូត (Trematode) ជំងឺនេះបង្កឡើងដោយបរាសិតមួយប្រភេទគឺហ្វាស្យូឡាហ្គីហ្គង់ទីកា (Fasciola gigantica) កើតលើសត្វស្រុក និងសត្វព្រៃច្រើនប្រភេទ ជាពិសេស គឺកើតលើសត្វគោ-ក្របី ចៀម និងពពែ។ កូនដង្កូវថ្លើមត្រូវបានសត្វលេបចូលពេលសត្វស៊ីស្មៅដែលមានវត្តមានកូនព្រូនដង្កូវថ្លើម។ ជំងឺនេះបានធ្វើឱ្យសត្វស្គមចុះទំងន់ មួយចំនួនតូចអាចស្លាប់ ផលិតភាពបន្តពូជទាប ថ្លើមខូច ផលិតផលថយចុះ ហើយសត្វមិនសូវមានកម្លាំងមាំមួន។

### ២. ទម្រង់ និងរូបរាង

ដង្កូវថ្លើមមានទម្រង់ និងរូបរាងសំប៉ែត ពណ៌ប្រផេះត្នោត មានប្រវែងពី ៣.៥-៧.៥ស.ម ហើយខ្លួនរបស់វាមានរាងស្របគ្នាផ្នែកក្បាល(ស្មាមុខ) និងកន្ទុយ។ ស្មាមុខ និងកន្ទុយរបស់ព្រូនដង្កូវថ្លើមមានប្រវែងពី០.៦៥-១.២ស.ម។

### ៣. វដ្តជីវិត

ព្រូនដង្កូវថ្លើម វារស់នៅក្នុងថ្លើម ហើយវាបញ្ចេញស៊ុតមកក្រៅតាមរយៈលាមក ហើយស៊ុតនឹងញាស់ក្នុងរយៈពេលពី១០-១២ថ្ងៃ ជាកូនព្រូនហៅថា មីរ៉ាស៊ីដ្យូម (Miracidium)។ មីរ៉ាស៊ីដ្យូមបានរស់នៅក្នុងទឹក ហើយវាធ្វើដំណើរទៅរកខ្យងមួយប្រភេទដែលមានឈ្មោះថាលីមណេអា (Lym-naea) ដែលជាម្ចាស់កណ្ដាលរបស់ព្រូនហ្វាស្យូឡា ដើម្បីជ្រៀតចូលរស់នៅក្នុងនោះរហូតវិវត្តខ្លួនក្លាយជាស្ព័រ៉ូស៊ីស (Sporocyst) ហើយក្លាយជារ៉េដ្យា (Rediae) និងជាសែកាវីយ៉ា (Cercariae) ក្នុងរយៈពេលនៃការលូតលាស់ពីមីរ៉ាស៊ីដ្យូមទៅដល់សែការីយ៉ា មានរយៈពេលពី ៤-៧ សប្ដាហ៍។ សែការីយ៉ា បានចាកចេញពីខ្យងលីមណេអាទៅតោងជាប់នឹងស្មៅ ឬរុក្ខជាតិដុះនៅក្នុងទឹក ស្រូវ។ល។ ហើយសែការីយា ក៏បានក្លាយទៅជាគីសដែលហៅថា មេតាសែការីយ៉ា (Metacercariae)។ មេតាសែការីយ៉ាឆ្លងមកសត្វដោយសារត្រូវបានស៊ីស្មៅ រុក្ខជាតិដុះក្នុងទឹក (គល់ជញ្ជ្រាំង ចំបើង) ផឹកទឹកដែលមានវត្តមានមេតាសែការីយ៉ា។ ករណីខ្លះជំងឺបង្កដោយព្រូនហ្វាស្យូឡានេះអាចឆ្លងពីមេមកកូនតាមរយៈសុក។ កូនព្រូនហ្វាស្យូឡា ត្រូវបាននាំទៅថ្លើម ហើយវារស់នៅទីនោះរហូតដល់ពេញវ័យ។

### ៤. រោគសញ្ញា

- ជំងឺដង្កូវថ្លើមអាចមានសភាពស្រួចស្រាវ មិនសូវស្រួចស្រាវ ឬរ៉ាំរ៉ៃ ដែលសញ្ញាលើមេគោគឺការខូចខាតថ្លើមដែលមានរោគសញ្ញាប្រែប្រួលអាស្រ័យនឹងចំនួនដង្កូវមានក្នុងថ្លើម។
- ជំងឺនេះធ្វើឲ្យចេញឈាមហើយជាលិកាខូចខាតដោយសារការបម្លាស់ទីរបស់កូនដង្កូវមិនទាន់ពេញវ័យទៅក្នុងថ្លើម និងការខូចខាតបំពង់ទឹកប្រមាត់(ស្ទះ) និងបាត់បង់ឈាមដោយសារដង្កូវពេញវ័យ។
- ជំងឺនេះ ធ្វើឱ្យសត្វចុះស្គម ស្រកទម្ងន់ ស្លេកស្លាំង សត្វរាកអាចម៍ ជាពិសេសលាមកជាប់គូទមានពណ៌ក្រម៉ៅហើមត្របកភ្នែក ភ្នាសត្របកភ្នែកស្លេក និងឡើងលឿង រោមស្ងួត បាស់ និងស្រអាប់ ហើមម្ដុំថ្គាម និងទ្រូង។



រោមស្កួត បាស់ និងស្រអាប់ និងលាមករាកជាប់គូទមានពណ៌ក្រម៉ៅ



ហើមត្របកភ្នែក ភ្នាសត្របកភ្នែកស្លេក និងឡើងលឿង



ហើមមុំថ្គាម និងទ្រូង

## ៥. ការព្យាបាល

ត្រូវប្រើប្រាស់ថ្នាំមួយចំនួនដូចខាងក្រោម ៖

- Triclabendazole (Fasinex) ត្រូវធ្វើការបញ្រ្ចូកតាមមាត់ក្នុងកម្រិត ១២ម.ក្រ/គ.ក្រ នៃទម្ងន់សត្វរស់ ដោយធ្វើការបញ្រ្ចូកពីរដងក្នុងមួយឆ្នាំ
- Nitroxinile (Dovenix-២៥%) ត្រូវចាក់ក្រោមស្បែកក្នុងកម្រិត ១ម.ល/២៥គ.ក្រ នៃទម្ងន់សត្វរស់ ដោយធ្វើការចាក់ពីរដងក្នុងមួយឆ្នាំ
- Albendazole ត្រូវធ្វើការបញ្រ្ចូកតាមមាត់ក្នុងកម្រិត ១៥ម.ក្រ/គ.ក្រ នៃទម្ងន់សត្វរស់ ដោយធ្វើការទាញចុះពីរដងក្នុងមួយឆ្នាំ
- Nizan ត្រូវធ្វើការបញ្រ្ចូកតាមមាត់ក្នុងកម្រិត ១៥ម.ក្រ/គ.ក្រ នៃទម្ងន់សត្វរស់ ដោយធ្វើការបញ្រ្ចូកពីរដងក្នុងមួយឆ្នាំ
- Oxyclozanide ត្រូវធ្វើការបញ្រ្ចូកតាមមាត់ក្នុងកម្រិត ១៥ម.ក្រ/គ.ក្រ នៃទម្ងន់សត្វរស់ ដោយធ្វើការបញ្រ្ចូកពីរដងក្នុងមួយឆ្នាំ។

## ៦. ការការពារ

- ត្រូវធ្វើការប្រមូលលាមកសត្វរក្សាទុកក្នុងរណ្តៅរយៈពេលយ៉ាងតិច ២ខែ មុននឹងយកទៅប្រើប្រាស់ជាជីធ្វើយ៉ាងនេះអាចកម្ចាត់ស៊ុតព្រូនហ្វាស្យូឡាបាន។
- បញ្ចៀសសត្វផឹកទឹក ស៊ីស្មៅ ឬរុក្ខជាតិដុះក្នុងទឹក គល់ជញ្រ្ជាំង ជាទីកន្លែងឆ្លងជំងឺ ជាពិសេសទីកន្លែងប្រភពទឹកមានជាប្រចាំ ហើយមានវត្តមានខ្យងមួយប្រភេទដែលមានឈ្មោះថាលីមណេអា(Lymnaea) ដែលជាម្ចាស់កណ្តាលរបស់ព្រូនហ្វាស្យូឡារស់នៅ។
- ត្រូវបំបាត់ខ្យងលីមណេអា (Lymnaea) ដែលជាម្ចាស់កណ្តាលរបស់ព្រូនហ្វាស្យូឡាដោយធ្វើការចិញ្ចឹមសត្វទា និងត្រី។

# ៨. ព្រូនខាងក្នុង ព្រូនក្នុងពោះវៀន

## ១. និយមន័យ

ជំងឺនេះបង្កឡើងដោយព្រូន (larva) ហើយសត្វអាចឆ្លងព្រូនក្នុងពោះវៀនដោយសារការលេបកូនដង្កូវព្រូន (larva) នៅពេលសត្វស៊ីស្មៅ។ ព្រូនពេញវ័យក្នុងពោះវៀនសត្វ រួចវាបានពងចេញមកក្រៅតាមរយៈលាមក។ ស៊ុតញាស់ក្នុងស្មៅដែលវិវត្តជាកូនដង្កូវដោយធ្វើការបម្លាស់ទីក្នុងវាលស្មៅ ហើយអាចឆ្លងមកសត្វតាមរយៈនៃការស៊ីស្មៅដែលមានវត្តមានកូនព្រូនតោងជាប់ស្មៅនោះ។

## ២. រោគសញ្ញា

- ស្រកទម្ងន់
- ការស៊ីចំណីថយចុះ ប៉ុន្តែគ្មានគ្រុនក្តៅ
- ភ្នាគមានពណ៌បៃតង
- រោមបះ



រាគពណ៌ខៀវនិងមានយ៉ាងច្រើន



៣. ការព្យាបាល

- ប្រើថ្នាំឡេវ៉ាមីសុល (Levamisole) និងអាល់បង់ដាសុល Alben-dazole...
- អ៊ីវែម៉ិចទីន (Ivomix tin)១% គឺ១ម.ល/៥០គ.ក្រ ដោយចាក់ក្រោមស្បែក។

## ៩. ជំងឺកុកស៊ីដ្យូស៊ីស Coccidiosis

១. និយមន័យ

ជំងឺនេះវាបង្កឡើងដោយបរាសិតដែលតូចមានកោសិកាតែមួយ។ កុកស៊ីដ្យូស៊ីសកើតមានជារឿយៗលើកូនគោដែលមានអាយុពី១ទៅ៦ខែ។

២. រោគសញ្ញា

- បាត់បង់ការស៊ីចំណីនិងស្រកទម្ងន់ដែលជាទូទៅធ្វើឲ្យសត្វស្គម
- រាគខ្លាំងដែលអាចមានឈាមនិងសំបោរ
- ឈឺចាប់ពេលជុះលាមក (ឈឺពោះ)
- ក្នុងស្ថានភាពជំងឺមិនសូវស្រួចស្រាវ (កើតជាទូទៅ)
- រោម និងលក្ខខ័ណ្ឌទូទៅមិនល្អ
- រាគប្រែជាពណ៌ខ្មៅនិងមានដូចសំបោរហើយអាចបង្កើតជាការប្រឡាក់ជុំវិញកន្ទុយ។





### ៣. ការព្យាបាល

ត្រូវចាក់ថ្នាំស៊ុលហ្វា៣៣ (Sulfa33) រយៈពេល៥ថ្ងៃ។

## ១០. ជំងឺអ៊ីកូលី E.Coli

### ១. និយមន័យ

ជំងឺនេះច្រើនកើតលើគោទើបកើត ហើយវាឆ្លងទៅកូនគោដោយបានលេបចូលបាក់តេរីពេលដែលបៅដោះ ឬចូលតាមរយៈទងផ្ចិត។ រាកបង្កដោយអ៊ីកូលីកើតមានក្នុងកំឡុងថ្ងៃដំបូងបន្ទាប់ពីកើត។

### ២. រោគសញ្ញា

- រាកមានពណ៌លឿង ស
- កូនគោចុះខ្សោយយ៉ាងខ្លាំង ឈប់បៅ
- ការចម្លងលើផ្ចិត សន្លាក់ និងការចម្លងមេរោគក្នុងឈាមទូទៅអាចកើតមានផងដែរ។



### ៣. ការព្យាបាល

កូនគោដែលទើបកើតមកមានរាកត្រូវផ្តាច់ទឹកដោះជាបន្ទាន់ ពេលដែលកូនគោបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (ភ្នែកឡើងរូង) វាចាំបាច់ត្រូវព្យួរសេរ៉ូមតាមសរសៃវ៉ែន ឬត្រូវបញ្ចូកតាមមាត់នូវទឹកដែលលាយជាមួយអេឡិចត្រូលីត (electrolytes) (ទឹកតែមួយមុខមិនមានប្រសិទ្ធភាពទេ)។ នៅជនបទគ្មានអេឡិចត្រូលីត ដូចនេះអាចលាយស្ករបីស្លាបព្រាធំនិងអំបិលកន្លះស្លាបព្រាធំក្នុងទឹកពីរលីត្រ។ កូនគោត្រូវផឹកទឹក១លីត្ររៀងរាល់៦ម៉ោងម្តង។ កូនគោដែលខ្សោះជាតិទឹកភាគច្រើនទទួលរងដោយសីតុណ្ហភាពជងខ្លួនចុះទាប និងត្រូវដាក់វានៅកន្លែងកក់ក្តៅជាពិសេសពេលយប់។ គួរចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជា កូលីស្ទីន ទ្រីមេតូព្រីមជាមួយស៊ុលហ្វា។

### ៤. ការការពារ

កូនគោកើតមកដោយគ្មានអង់ទីគ័រប្រឆាំងនឹងជំងឺអ៊ីកូលី។ ពួកវានឹងទទួលអង់ទីគ័រនេះពីទឹកដោះមេវា។ ប៉ុន្តែមានតែទឹកដោះដំបូង (Colostrum) ដែលមានអង្គការពារច្រើននិងវាផលិតតែប៉ុន្មានម៉ោងបន្ទាប់ពីកើតតែប៉ុណ្ណោះ។ ដូចនេះវាចាំបាច់បំផុតត្រូវឲ្យកូនគោបៅទឹកដោះដំបូងនៅកំឡុងពេល១២ម៉ោងបន្ទាប់ពីកើត ប៉ុន្តែយើងគួរធ្វើយ៉ាងណាឱ្យកូនគោបានបៅទឹកដោះដំបូង(Colostrum)១លីត្រ ១ម៉ោងបន្ទាប់ពីកើត ១លីត្រ ៦ម៉ោងបន្ទាប់ពីកើត។





## ១១. ជំងឺសាល់ម៉ូណែឡា Salmonellosis

### ១. និយមន័យ

ក្នុងបរិស្ថានពួកសាល់ម៉ូណែឡារស់បានពី៤ទៅ៥ឆ្នាំក្នុងទឹក ដី ធូលី កន្លែងសើមដែលមិនប៉ះជាមួយពន្លឺព្រះអាទិត្យផ្ទាល់។ ការធ្វើអនាម័យជុំវិញផ្ទះនិងក្នុងភូមិជាមធ្យោបាយសំខាន់ក្នុងការគ្រប់គ្រងពួកសាល់ម៉ូណែឡា។



កន្លែងយ៉ាងល្អបំផុតសម្រាប់ការលូតលាស់របស់ពពួកសាល់ម៉ូណែឡា



### ២. រោគសញ្ញា

ការចម្លងអាចមានចាប់ពីការមើលទៅសត្វដែលផ្ទុក "មានសុខភាពល្អ" រហូតបង្ហាញរោគសញ្ញាចម្លងស្រួចស្រាវដូចជា ៖

- គ្រុនក្តៅខ្លាំង
- ចំពោះគោធំយើងអាចឃើញរាកធ្ងន់ធ្ងរនិងមានក្លិនស្អុយខ្លាំងព្រមទាំងបរិមាណឈាម និងសំបោរប្រែប្រួលក្នុងលាមក និងបំណែកទ្រនាប់ខាងក្នុងពោះវៀន។ ការលូតអាចកើតមានចំពោះគោដែលឆ្លងជំងឺ។ ក្នុងករណីរ៉ាំរ៉ៃដែលកើតមានតាមពីក្រោយដំណាក់កាលស្រួចស្រាវធ្វើឲគ្រុនក្តៅកើតឈប់ៗ រាករាវដូចទឹកដែលធ្វើឱ្យខ្សោះទឹកនិងស្រកទម្ងន់។
- ចំពោះកូនគោអាយុ២ទៅ១២អាទិត្យ ជំងឺនេះច្រើនរាតត្បាលលើកូនគោដែលមិនបានបៅទឹកដោះដំបូង។ វាបង្កឲកើតជាគ្រុនក្តៅខ្លាំង រាកពណ៌លឿងច្រើនជាមួយ ឬគ្មានឈាម និងសំបោរ ហើយធ្វើឲ្យខ្សោះជាតិទឹកលឿន និងការងាប់អាចកើតមាន ក្នុងកំឡុងពេល២៤ទៅ៤៨ម៉ោង។



**៣. ការព្យាបាល**

- ដូចការព្យាបាលជំងឺអ៊ីកូលី ការធ្វើឲ្យមានជាតិទឹកឡើងវិញត្រូវអនុវត្តជាបន្ទាន់
- ការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកមិនសូវប្រាកដប្រជាព្រោះពួកសាល់ម៉ូណែឡាវិវត្តច្រើនធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិក
- ការព្យាបាលត្រូវធ្វើយ៉ាងតិចចំនួន ៦ថ្ងៃ
- ថ្នាំព្យាបាលត្រូវប្រើប្រាស់ដូចជាទ្រីមេតូព្រីម ជាមួយស៊ុលហ្វា កូលីស្ទីន ជាមួយអំពីស៊ីលីន អង់រ៉ូផ្លកសាក់ស៊ីន អាចប្រើបានប៉ុន្តែការធន់នឹងថ្នាំងទាំងនេះកើតមានយ៉ាងលឿន។ ជាទូទៅពួកសាល់ម៉ូណែឡាធន់នឹងថ្នាំតេត្រាស៊ីគ្លីន។

## ១២. ជំងឺរាគដោយឱកាស

**១. និយមន័យ**

ជាទូទៅជំងឺនេះ វាបង្កដោយកំហុសក្នុងការផ្តល់ចំណីដូចជា៖

- ការផ្លាស់ប្តូរចំណីសត្វលឿន
- នៅដើមរដូវភ្លៀងគោស៊ីស្មៅខ្ចីច្រើនបណ្តាលឲ្យរាក
- ចំណីចាស់(សល់ផ្តួមជូរ) រលួយ ឡើងមេ (ពោត កន្ទក់)

ពេលខ្លះរាក គឺជារោគសញ្ញាតែប៉ុណ្ណោះ គោមិនបានបង្ហាញរោគសញ្ញាទូទៅប៉ុន្តែយើងអាចសង្កេតឃើញលាមករាវដូចទឹក។



## ២. ការព្យាបាល

- ស្មៅឬចំណីថ្មីត្រូវផ្តល់ឲ្យវាបន្តិចម្តងៗ
- ដាក់គោក្រោមផ្ទះនិងផ្តល់ចំបើងដែលមានគុណភាពល្អ
- យកចំណីដែលខូចចេញ។

# ១៣. ជំងឺហើមពោះ

## ១. និយមន័យ

ជារឿយៗ ជំងឺនេះត្រូវបានបង្កដោយការស្ទះក្នុងបំពង់អាហារដូចជា ស្នូលពោត ឬផ្លែឈើផ្សេងៗ។ ដូច្នេះ បសុពេទ្យ ឬម្ចាស់សត្វ ត្រូវស្ទាបបំពង់អាហារដោយដៃ ឬហែកមាត់សត្វមើលក្នុងបំពង់កបស់សត្វ ដើម្បីកំណត់កន្លែងស្ទះ និងកំណត់ថាតើការហើមពោះនេះបណ្តាលមកពីពពួកបាត់តេរី ពពួកផ្សិត ឬមួយបណ្តាលមកពីការលេបចូលនៅចំណីដែលជារបស់រឹងអ្វីមួយឱ្យច្បាស់លាស់ មុននឹងធ្វើការព្យាបាលសត្វ។ វាអាចកើតមានយ៉ាងលឿន ជាពិសេសពេលដែលសត្វស៊ីស្មៅលើវាលស្មៅដែលមានសំណើមខ្ពស់នៅពេលព្រឹក។ គោស៊ីស្មៅខ្ចីច្រើនពេកពេលដែលរដូវភ្លៀងចាប់ផ្តើម។ វាអាចបណ្តាលឲ្យ សត្វស្លាប់ភ្លាមៗ។





ការស្ទាបដើមកនិងបំពង់អាហារ

## ២. រោគសញ្ញា

- ជំងឺហើមពោះគឺប៉ោងផ្នែកខាងឆ្វេងរបស់មេគោ
- ពោះគោបង្ហាញថាមានឧស្ម័ន ឬពពុះពេញ
- គោមិនអាចភើរឧស្ម័នក្នុងពោះបានទេ
- ការទំពារអៀងឈប់
- ពោះឡើងធំដូចស្គរដែលសង្កត់លើសន្ទះទ្រូងធ្វើឲ្យការដកដង្ហើមមានការលំបាកខ្លាំង
- សីតុណ្ហភាពធម្មតា។





ហើមប៉ោងផ្នែកខាងស្តាំងដោយសារការដើម

### ៣. ការការពារ

មិនត្រូវឲ្យគោដែលឃ្លានខ្លាំងស៊ីចំណីដែលមានគ្រោះថ្នាក់នោះទេ។ ត្រូវផ្តល់ចំណីណាទន់ដល់សត្វដែលងាយស្រួលលេប។

### ៤. ការព្យាបាល

បសុពេទ្យត្រូវយកចំណីដែលស្ទះចេញដោយដៃ។ ច្រកប្រេង៣០០ទៅ៥០០មីលីលីត្រតាមមាត់។ ចំពោះគោដោយប្រើត្រូការ (Trocar) ពេលដែលការហើមពោះធ្ងន់ធ្ងរដើម្បីបញ្ចេញខ្យល់។ គ្រប់ពេលត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីបង្ការជំងឺអាប់សែស្រោមពោះ។

## ១៤. បញ្ហាស្បែក ប៉ារ៉ាសិតខាងក្រៅ ពពួកសត្វរុយ

### ១. និយមន័យ

សត្វរុយ គឺជាសត្វល្អិតមួយប្រភេទដែលតែងតែរំខានដល់ការរស់នៅរបស់សត្វ និងមនុស្សផងដែរ។ មានរុយច្រើនប្រភេទអាចរំខានដល់សត្វ ហើយប្រភេទខ្លះ គឺបឺតឈាមដែលបង្កឱ្យសត្វអស់ឈាម ជាពិសេសលើសត្វក្មេងមានស្លាកស្នាមលើស្បែក និងការរំខានជាអចិន្ត្រៃយ៍ចំពោះការខាំមានការឈឺចាប់។ ប្រភេទខ្លះមិនមែនបឺតឈាម តែបង្កជាការរំខានពេលដែលពួកវាមានចំនួនច្រើន (មានរុយច្រើនជាង១០០/សត្វមួយក្បាល) ពួកវាអាចសាយភាយបាក់តេរី ឬវីរុសនិងពួកវាជាប្រភពធ្វើឲ្យមានភាពក្រហល់ក្រហាយពេលដែលពួកវាស៊ីចំណីលើភ្នាសសើមនៃភ្នែករបស់សត្វ រំខានដល់ការដេករបស់សត្វ និងធ្វើឱ្យសត្វស្រកទម្ងន់។





### ២. ការគ្រប់គ្រង

មានផលិតផលពីរដែលមានសម្រាប់គ្រប់គ្រងរុយលើគោគឺ៖

- ពែរមេទ្រីន Permethrin (ប៊ុយតុកButox)
- គូម៉ាផូស Coumaphos (អាស៊ុនតុល Asuntol)

## ១៥. ពពួកសត្វមូស

### ១. និយមន័យ

មូស គឺជាសត្វល្អិត វាបឺតឈាមពីគោ។ ពួកវាសម្រក់ឈាមក្នុងទឹកហើយជាទូទៅវាមានចំនួនច្រើននៅកន្លែងងងឹត ដែលគោតែងដេកជាធម្មតា។ ពួកវាបឺតឈាមពេលថ្ងៃរសៀល និងយប់បង្ករជាការរំខានដែលសត្វមិនអាចដេក និងពេលថ្ងៃពួកវាអស់កម្លាំង ដើម្បីស៊ីស្មៅពួកវាបាត់បង់លក្ខខ័ណ្ឌដងខ្លួនល្អ ចុះទម្ងន់។

## ២. ការគ្រប់គ្រង ឬព្យាបាល

ដុតស្លឹកឈើ និងមែកឈើតូចៗ ដើម្បីបង្កើតជាផ្សែងធ្វើឲ្យមូសចេញឆ្ងាយពីសត្វ ឬប្រើប្រាស់ថ្នាំសម្លាប់សត្វមូស។ ជាក់មុងដើម្បីការពារឲ្យកន្លែងសត្វដេកឱ្យមានសុវត្ថិភាពនៅពេលយប់។



# ១៦. ពពួកសត្វដង្កែ

## ១. និយមន័យ

ពេលដែលគោត្រូវរំខានខ្លាំងក្លា ដង្កែត្រូវបានរកឃើញគ្រប់កន្លែងលើដងខ្លួន។ ចំពោះសត្វដែលមានការរំខានតិចតួចពីដង្កែគឺយើងអាចមើលឃើញវាភាគច្រើននៅកន្ទុយ ពោះ ស្មានិងត្រចៀក។ ដង្កែបឺតឈាមពីសត្វ និងចំនួនដង្កែច្រើនអាចធ្វើឱ្យសត្វបាត់បង់ឈាម និងចុះខ្សោយ ជាពិសេសចំពោះកូនគោ។ ដង្កែមានមាត់វែងហើយអាចបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ស្បែក។ ដង្កែអាចចម្លងភ្នាក់ងារជំងឺដូចជា ជំងឺបាបេស្យា និងអាណាប្លាស្មា។





## ២. ការគ្រប់គ្រង ឬព្យាបាល

ជាការល្អម្ចាស់គោ ត្រូវលាងទឹកឱ្យគោគឺជាការល្អ និងជាមធ្យោបាយមានសុវត្ថិភាព ដើម្បីត្រួតពិនិត្យមើលដង្កែ និងត្រូវបេះដង្កែចេញ ឬត្រូវព្យាបាលដោយប្រើថ្នាំដូចខាងក្រោម៖

- ពែរមេទ្រីន Permethrin (ប៊ុយតុកButox)មានសកម្មភាពភ្លាមៗ
- គូម៉ាផូស Coumaphos (អាស៊ុនតុល Asuntol) មានសកម្មភាពភ្លាមៗ
- អ៊ីវែម៉ិចទីន Ivermectin (អ៊ីវែម៉ិច) ទទួលបានប្រសិទ្ធភាពខ្ពស់បំផុត នៅពេលពី៤ទៅ៥ថ្ងៃបន្ទាប់ពីការចាក់។

## ១៧. ជំងឺបន្តដោយពពួកសត្វចៃ

### ១. និយមន័យ

អង្កែបង្កជាការត្រដុសយ៉ាងខ្លាំង អេះខ្វាចស្បែកដែលកើតមានតាមក្រោយការបាត់បង់រោមនិងស្បែកក្រម៉ក្រាស់។ ស្លាកស្នាមអាចគ្របដណ្តប់ដងខ្លួនទាំងមូល។



### ២. ការគ្រប់គ្រង

វាមានការលំបាកព្រោះចៃចូលរូងលាក់ខ្លួន។ ការចាក់ថ្នាំអ៊ីវ៉េម៉ិចទីនគឺជាបច្ចេកទេសគ្រប់គ្រងចៃបានល្អបំផុតក្នុងការសម្លាប់សត្វចៃពីដង់ខ្លួនសត្វ។ ថ្នាំអាស៊ុនតុល អាចប្រើបាន។ ការចាក់លើកទី២ចាំបាច់ត្រូវធ្វើនៅ២ ឬ៣អាទិត្យក្រោយមកអាស្រ័យវដ្តរបស់បរាសិត។

## ១៨. ជំងឺចាញ់ពន្លឺថ្ងៃ

### ១. មូលហេតុ

- ប្រតិកម្មថ្នាំដូចជាពពួកស៊ុលហ្វា
- ផ្សិតក្នុងស្មៅប្រាស្យារីយ៉ា(Brachiaria)
- ថ្លើមខូច(ដោយហ្វាស្យូឡា...)ដែលមិនអាចបំបាត់ជាតិពុលបាន
- ការព្យាបាល
- ដាក់សត្វនៅក្នុងម្លប់
- ដំណាក់ដំបូងត្រូវចាក់ថ្នាំដិចសាមេតាសូន
- ប្រសិនបើមានក្រម៉ច្រើនត្រូវចាក់ថ្នាំដូចជាអាម៉ុកស៊ីលីនដែលមានសកម្មភាពវែង។

### ២. សញ្ញា

- ស្បែកអាចឡើងក្រហម និងហើម
- វិវត្តជាពងស្បែកហើយបែក
- បំណែករបស់ស្បែកអាចជ្រុះចេញ



## ១៩. ការប្រែពណ៌

### ១. មូលហេតុ

រោម និងស្បែកប្រែពណ៌ជារឿយៗជាប់ទាក់ទងនឹងសភាពរាងកាយមិនល្អ និងរោមបះ។ មូលហេតុទូទៅគឺកង្វះវីតាមីនអា ស័ង្កសី និងទង់ដែង។ មូលហេតុមួយទៀតគឺស្លាកស្នាមដែលបង្កដោយសត្វល្អិតទិច (ខាំ) ឬការជាសះស្បែកណាមួយ។ រោមនឹងដុះឡើងវិញដែលមានពណ៌ផ្សេង។



### ២. ការព្យាបាល

ចាក់មួយ ឬពីរម្ជុលថ្នាំវីតាមីនកម្រទទួលបានជោគជ័យ ព្រោះរាល់ពពួករ៉ែ និងវីតាមីនធ្វើការរួមគ្នា ការកែខៃការខ្វះខាតនេះមានភាពស្មុគស្មាញ គឺវាត្រូវការស្រូបយកពពួករ៉ែ និងវីតាមីនដែលមានគុណភាពល្អ ជាការល្អបំផុតត្រូវឱ្យចំណីផ្សំរយៈពេល៣ទៅ៤អាទិត្យ។

## ២០. ជំងឺដំបៅ

### ១. និយមន័យ

ដំបៅគឺជាជំងឺមួយបង្កដោយវីរុស បាក់តេរី និងការដាច់ស្បែកដោយមុតវត្ថុរឹងដូចជាកាំបិត ដែក គល់ ឬចំរាសឈើមានមុខស្រួច។ល។ ដំបៅជ្រៅអាចពាក់ព័ន្ធនឹងសាច់ដុំ សន្លាក់។ រាល់ដំបៅទាំងអស់ចេញឈាម មានការឈឺចាប់ និងអាចក្លាយជាការចម្លងដោយមីក្រុប ឬដង្កូវ។ ដំបៅគឺជាការដាច់ស្បែក ដំបៅជ្រៅអាចពាក់ព័ន្ធនឹងសាច់ដុំ សន្លាក់។ ប្រសិនបើដង្កូវទន្ទ្រានលើដំបៅ មានតែបាញ់ថ្នាំសម្លាប់សត្វល្អិតទៅក្នុងដំបៅ (ថ្នាំរេដ៏ Raid) ក្នុងរយៈពេល២-៣នាទីក្រោយមកត្រូវយកដង្កូវចេញ (វាចេញឈាម)ដោយប្រើដង្កៀបហើយព្យាបាលដូចដំបៅធម្មតា។





### ២. ការព្យាបាល

សម្អាតដំបៅជាមួយទឹកឱ្យបានច្រើន និងដុសច្រាសថ្នមៗដែលនេះវាគឺជាការព្យាបាលដំបៅ៩០%។ កាត់រោមនៅជុំវិញដំបៅចេញ រួចធ្វើការលាបអ៊ីយ៉ូឌីន (ប្រសិនបើដំបៅស្អាត) ឬបាញ់ថ្នាំដែលមានថ្នាំតេត្រាស៊ីគ្លីន និងថ្នាំស្វាយ (Genti-ane violet)។ ប្រសិនបើដំបៅជ្រៅត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាអាម៉ុកស៊ីលីន ដែលមានសកម្មភាពវែង ឬអុកស៊ីតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។





## ២១. ជំងឺឫស

### ១. មូលហេតុ

ឫសគឺជាជំងឺបង្កឡើងដោយពពួកវីរុសដែលហៅថាប៉ាពីឡូម៉ាវីរុស(papillomavirus)។ វីរុសនេះអាចសាយភាយទៅគោផ្សេងទៀតពេលដែលស៊ីស្មៅនៅតាមគុម្ពោតព្រៃ (វីរុសស្ថិតលើផ្នែកច្រើន និងលេចចេញស្លាកស្នាមលើស្បែកនៃដងខ្លួន)។

ជាធម្មតា ជំងឺឫសនេះវាមិនបណ្តាលឱ្យគោឈឺទេ ហើយគ្មានការព្យាបាលជំងឺនេះទេ។ ឫសកើតលើគោតែងរួញ និងជ្រុះបន្ទាប់ពីបានកើតប្រមាណពី៣ទៅ៦ខែ។



## ២២. ជំងឺខ្វក់ជើង

### ១. បុព្វហេតុ

នៅប្រទេសកម្ពុជាគោត្រូវបានប្រើភាគច្រើនជាកម្លាំងអូសទាញដូចនេះជើងរឹងមាំគឺមានសារៈសំខាន់ដើម្បីធ្វើការក្នុងវាលស្រែ។

### ២. ជំងឺស្បែកក្រចកជើង

ជំងឺស្បែកក្រចកជើងគឺជាជំងឺស្បែករបស់គោដែលមានឥទ្ធិពលលើស្បែកផ្នែកខ្ពស់របស់កែងជើង។ ជំងឺស្បែកក្រចកជើងអាចឃើញមាននៅចន្លោះក្រចកជើងផងដែរ។



### ៣. រោគសញ្ញា

គោដែលមានជំងឺស្បែកក្រចកជើងអាចបង្ហាញសញ្ញាខ្វក់ជើងពេលដែលក្រោកឈ ឬពេលដែលបម្លាស់ទី។ ការបង្ហាញជាទូទៅភាគច្រើនគឺការឈររបស់សត្វមានភ្លាត់ជើងច្រើនដងដោយគ្មានមូលហេតុ។ គោមិនសូវមានកម្លាំងពេលធ្វើការក្នុងវាលស្រែដោយពួកវាឈឺជើង។ ជំងឺនេះភាគច្រើនត្រូវបានឃើញពេលដែលគោធ្វើការក្នុងដីភក់ វាកើតមានជាទូទៅចំពោះគោដែលភ្ជួរស្រែ។

### ៤. ការព្យាបាល

ប្រសិនបើជំងឺស្បែកក្រចកជើងត្រូវបានព្យាបាលវាអាចស្ថិតនៅជាច្រើនខែ ដោយការត្រាំជើង កសិករត្រូវរកផើងដើម្បីត្រាំ និងកាន់សត្វឲ្យត្រឹមត្រូវដើម្បីត្រាំជើងឲ្យបាន២-៣នាទីក្នុងទឹកដែលមាន៖

- ហ្វម៉ាលីន(formalin) ៣%ពីរដងក្នុងមួយថ្ងៃរយៈពេល៣ថ្ងៃឬ
- ទង់ដែងស៊ុលហ្វាត (Copper sulfate 5%)។

ក្នុងករណីធ្ងន់ធ្ងរត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬអុកស៊ីតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។

**ការការពារ ៖** ត្រូវប្រាកដថាកម្រាលមានសភាពទន់ និងស្ងួតនៅកន្លែងជម្រកដែលដាក់គោ។

## ២៣. ជំងឺរលួយស្អុយជើង

### ១. មូលហេតុ

ការរលួយស្អុយជើង គឺជាការចម្លងដំបៅរលួយ (ជាលិកាត្រូវបានចម្លងហើយបន្ទាប់មកត្រូវបានបំផ្លាញដោយមានក្លិនស្អុយ)នៃស្បែក(ចន្លោះក្រចកជើង)។ ម្យ៉ាងទៀត ការរលួយស្អុយជើង បណ្តាលមកពីកន្លែងរស់នៅរបស់សត្វមានសភាពសើម លាមកសើម និងភក់ជ្រាំជាប្រចាំដែលអាចធ្វើឲ្យស្បែកចន្លោះក្រចកជើងទន់ដែលធ្វើឲ្យវាងាយមុត។ ភ្នាក់ងារចម្លងចូលតាមរយៈស្បែកដែលមានរបួសបង្ករដោយការមុតថ្ម ដែក ឈើ...។ល។ ការធ្វើការរបស់គោក្នុងភក់គឺបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុរបស់ដំបៅរលួយជើង។




### ២. រោគសញ្ញា

- ខ្វក់ជើងលេចឡើងយ៉ាងលឿន ដែលជាទូទៅមានជើងម្ខាងដែលទទួលរងគ្រោះ
- គ្រុនក្តៅ
- ហើមជើង
- ដាច់ដោចក្នុងស្បែកចន្លោះក្រចក អាចមានខ្ទុះតិចៗ។

### ៣. ការព្យាបាល

- ចាក់ថ្នាំស៊ុលហ្វា៣៣តាមសរសៃវ៉ែនមានប្រសិទ្ធភាព
- ចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វារយៈពេល៣ថ្ងៃ
- ចាក់ថ្នាំតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។

# ២៤. ជំងឺស្លាក់

## ១. មូលហេតុ

ជំងឺស្លាក់ គឺជាការរលាកនៅសន្លាក់ដែលជាទូទៅរួមនឹងការចម្លងជំងឺ។ ជំងឺបណ្តាលមកពីការដំបៅសន្លាក់ដែលជាទូទៅមានសន្លាក់តែម្ខាងទទួលរងគ្រោះ។ ការចម្លងទូទៅដទៃទៀតដែលវិវត្តក្នុងសន្លាក់ជាពិសេសលើកូនគោការចម្លងមកពីផ្ចិត សួត ឬបំពង់រំលាយអាហារមានដូចជាពួកមីកូប្លាស្មា អ៊ីកូលី ឬសាល់ម៉ូណែឡា។ មេគោបំបៅកូនដែលកង្វះជាតិកាល់ស្យូម ផូស្វ័រ សមាសជាតុមីក្រូដទៃទៀត។ ចំពោះកូនគោវាបង្កឲ្យក្រិន ជើងមុខខូចទ្រុងទ្រាយនិងសន្លាក់កជើងធំ។



## ២. រោគសញ្ញា

- ខូកជើងស្តែងចេញនៅពេលសត្វធ្វើចលនា
- ឈឺចាប់ពេលស្ទាបកន្លែងសន្លាក់ដែលហើម
- ចំណង់ស៊ីចំណីតិចតួច
- គ្រុនក្តៅ

## ៣. ការព្យាបាល

- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទីឡូស៊ីនTylosin ឡាំងកូមីស៊ីនLincomycin តេត្រាស៊ីគ្លីនTetracyclin រយៈពេល៥ទៅ៧ថ្ងៃ
- ថ្នាំដែលកាត់បន្ថយការឈឺចាប់ និងការរលាកដូចជាប៉ារ៉ាសេតាម៉ុលParacetamol ឌីពីរ៉ូនDypirone (អាណាល់សាំងAnalgine កាល់ម៉ាស៊ីនCalmalgine)។

# ២៥. ជំងឺខ្វិនជើង

## ១. មូលហេតុ

ជាទូទៅគេពិនិត្យឃើញសត្វដេកខ្ជិលច្រអូសរយៈពេលយូរ។ ខ្វិន(ជើងមុខ)ពេលដែលគោស្គម និងខ្សោយគោមិនក្រោកឈរច្រើនថ្ងៃ ហើយវាសំងំនៅស្ងៀមមួយកន្លែង សរសៃមិនត្រូវបានការពារដោយសាច់ដុំ និងត្រូវបានខូចខាតពេលដែលគោដេកទៅម្ខាងលើផ្ទៃដែលរឹង។




**២. ការព្យាបាល**

- ជួយគោដែលខ្សោយឲ្យក្រោកពីរដងក្នុងមួយថ្ងៃ
- ត្រូវចាក់ថ្នាំលើកកម្លាំងដូចជាការ៉ាស៊ីល (Carasil) អេម៉ាតូប៉ែន ប៉េ១២ (Hematopen B12)
- ត្រដុសស្នា និងភ្លៅជាមួយចំបើង

## ២៦. លក្ខខណ្ឌដងខ្លួនដែលទទួលមហន្តរាយ

DISASTROUS BODY CONDITION

ជាទូទៅ គេតែងតែសង្កេតឃើញមាននៅក្នុងប្រទេសកម្ពុជានូវគោស្គមៗ រោមប៉ះ និងរោមស្រអាប់ហើយមានសភាពអស់កម្លាំង។



វាមិនងាយស្រួលក្នុងការធ្វើឲ្យសត្វត្រឡប់មកមានសភាពដងខ្លួនដូចដើមវិញនោះទេ។ មូលហេតុចម្បងគួរតែ៖

**១. កង្វះការផ្តល់ចំណី (ការចុះអន់ថយ)**

កង្វះការផ្តល់ចំណី(គុណភាព និងបរិមាណ) គឺជាមូលហេតុចម្បងធ្វើឱ្យសត្វមានសភាពស្បែកបែបនេះ។ ការចាក់ថ្នាំវីតាមីនច្រើនប្រភេទ ឬថ្នាំលើកកម្លាំងមិនគ្រប់គ្រាន់ទេ។ ដាច់ខាតត្រូវផ្តល់ស្មៅដែលមានគុណភាពល្អ (ផ្តល់ប្រូតេអ៊ីន) និងចំណីផ្សំនៅផ្ទះ (មើលក្នុងផ្នែកការផ្តល់ចំណីគោ) វាត្រូវការពេលវេលាប្រហែល៦អាទិត្យដើម្បីធ្វើឲ្យដងខ្លួនគោវិលមករកសភាពល្អត្រឹមត្រូវដោយប្រើរបបចំណីដែលមានថាមពល និងប្រូតេអ៊ីនគ្រប់គ្រាន់ មានបច្ចេកទេសបីអាចគ្រប់គ្រាន់គឺ៖



១. ផ្តល់ស្មៅចស្មៅ និងស្មៅតំណៀ

២. ផ្តល់ចំណីបន្ថែមផ្សំនៅផ្ទះ





៣.រៀបចំផ្តាប់ចំបើង

## ២. ការបំបៅដោះ Milking

វាមិនជាកម្រទេដែលឃើញកូនគោអាយុច្រើនជាង៦ខែ ហើយនៅបៅដោះមេ។ មេគោមិនអាចស៊ីគ្រប់គ្រាន់ប្រសិនបើវាមិនបានទទួលចំណីបន្ថែមដើម្បីរក្សាការផលិតទឹកដោះ។ មេគោត្រូវការទាញយកចំណីបម្រុងទុកហើយវានឹងបាត់បង់សភាពរាងកាយល្អរបស់វានៅពេលទុកឱ្យកូនគោបៅដោះមេវាយូរ។ ម្ចាស់សត្វ ចាំបាច់ត្រូវផ្តាច់ដោះកូនគោដែលមានអាយុមុន៦ខែ (បំបែកមេគោនឹងកូនគោ) ដើម្បីបង្ការរាងកាយដងខ្លួនធ្លាក់ចុះអន់ថយ។ មេគោដែលស្គមមិនបង្ហាញសញ្ញារកឈ្មោលទេ នេះជាហេតុផលដែលបណ្តាលឱ្យលទ្ធភាពផលិតកម្មមានការថយចុះ។



កូនគោមានអាយុច្រើនខ្លាំងនៅជាមួយមេគោដែលស្គម



## ៣. បរាសិត (Parasitism)

ការរំខានខ្លាំងក្លាដោយព្រូនជះឥទ្ធិពលដល់លក្ខខណ្ឌដងខ្លួនប៉ុន្តែដង្កូវថ្លើមអាចបណ្តាលឲ្យលក្ខខណ្ឌដងខ្លួនមហន្តរាយខណៈពេលដែលការស្លេកស្លាំងវិវត្ត។

វាមានសារៈសំខាន់ដើម្បីទម្លាក់ព្រូនគោពីរដងក្នុងមួយឆ្នាំ នៅដើម និងចុងរដូវភ្លៀង ជាពិសេសចំពោះគោដែលស៊ីចំណីជាក្រុម និងស៊ីស្មៅនៅតំបន់សើម។



គោស្គម ស៊ីស្មៅជាក្រុម និងមានជំងឺរាគ ប្រើថ្នាំអាល់បង់ដាសុល នឹងមានប្រយោជន៍



### ៤. បា៉រ៉ាសិតក្នុងឈាម

បាបេស្យា (Babesia) ទ្រីប៉ាណូសូម៉ា (Trypanosoma) និងពួកអាណាប្លាស្មា (Anaplasma) គឺមាននៅប្រទេសកម្ពុជា។ ទ្រីប៉ាណូសូម៉ាជារឿយៗ គេរកឃើញលើគោ ប៉ុន្តែវាមិនច្បាស់ថាមានឥទ្ធិពលលើសុខភាព និងលក្ខខណ្ឌដងខ្លួនមិនល្អនោះទេ។

ក្នុងករណីលក្ខខណ្ឌរាងកាយទទួលមហន្តរាយរួមមានគ្រុនក្តៅ និងហូរទឹកភ្នែកឥតឈប់ៗ ត្រូវចាក់ថ្នាំបេរីនីល (Berenil) ដើម្បីគ្រប់គ្រងទ្រីប៉ាណូសូម៉ា។





## ២៧. ជំងឺបន្តពូជ ជំងឺរលាកស្បូន / ហូរទឹកតាមយោនី

### ១. មូលហេតុ

ជំងឺរលាកស្បូន ឬមានទឹកហូរតាមរន្ធយោនី ជាធម្មតាគេតែងសង្កេតឃើញមានហូរទឹកថ្លាតាមយោនីគឺជាការធម្មតាក្នុងកំឡុងពេលមេគោរកឈ្មោល ឬ២-៣ថ្ងៃ បន្ទាប់ពីកើតកូន ប៉ុន្តែពេលខ្លះយើងឃើញខ្ទុះក្នុងទឹកដែលហូរ ជាធម្មតាវាបណ្តាលមកពីការចម្លងមេរោគលើស្បូននោះគេហៅថារលាកស្បូន។ ស្បូនធម្មតាគឺជាកន្លែងដែលល្អស្អាត បន្ទាប់ពីកើតកូនរួច។ ស្បូនត្រូវបានឆ្លងដោយមេរោគច្រើនមកពីរន្ធយោនី ប៉ុន្តែជាធម្មតា២-៣ថ្ងៃបន្ទាប់មក ស្បូននឹងអាចកម្ចាត់មេរោគទាំងនេះនិងការពារការចម្លងដោយខ្លួនឯងបាន។ នៅពេលខ្លះការចម្លងមេរោគបានឆ្លងរួចទៅហើយ ហើយបាក់តេរីទាំងនោះនឹងវិវត្តទៅជាមេរោគបង្កដែលធ្វើឱ្យស្បូនមានការរលាក ព្រោះស្បូនមិនអាចកម្ចាត់បាក់តេរី (សុកធ្លាក់មិនអស់ និង

បញ្ហាលើផលិតកម្មអ័រម៉ូន...) វាផលិតជាខ្ទុះ និងបង្កឱ្យមានការហូរខ្ទុះចេញមកក្រៅបញ្ជាក់ឱ្យយើងដឹងថាស្បូនសត្វមានការរលាក។

### ២. រោគសញ្ញា

ជាទូទៅ ជំងឺរលាកស្បូន ឬហូរទឹកតាមយោនីបានបង្ហាញឱ្យយើងឃើញនៅពេលមានស្ថានភាពដូចជា:

- ខ្ទុះ ឬវត្ថុដែលមិនល្អអាចត្រូវបានឃើញក្នុងយោនី
- ក្លិនស្អុយកើតមានជាទូទៅ
- ឃ្លានចំណីតិចតួច។




### ៣. ការព្យាបាល

- ចាក់ថ្នាំប្រូស្តាក្លង់ឌីន ២ដងក្នុងពេលពី១១ទៅ១៤ថ្ងៃដើម្បីឲ្យហូរកម្ទេចកំទីចេញពីស្បូន វាបើកស្បូន និងជំរុញការកន្ត្រាក់ វត្ថុដែលកខ្វក់នឹងរុញចេញ(ថ្នាំអុកស៊ីតុកស៊ីនមិនអាចប្រើបានទេព្រោះថ្នាំនេះមិន"បើក"ស្បូន និងអាចធ្វើឲ្យមានការកន្ត្រាក់តែកំឡុងពេលកើតកូនទេ)
- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាតេត្រាស៊ីគ្លីន ឬទីឡូស៊ីនរយៈពេល៥ថ្ងៃ
- មិនត្រូវឲ្យអនុសាសន៍"លាង"ស្បូនជាមួយល្បាយអ៊ីយ៉ូឌីន ឬពែម៉ង់កាណាតទេ។ វាធ្វើឲ្យក្រហល់ក្រហាយ និងបរិមាណច្រើនរបស់វត្ថុរាវនឹងធ្វើឲ្យប៉ះពាល់ដល់ការមូលចូលក្នុង។

### ៤. ការការពារ

មេគោដែលប្រឈមនឹងគ្រោះថ្នាក់គឺជាមេគោដែលធ្លាប់មានបញ្ហាក្នុងកំឡុងពេលកើតកូន ដែលត្រូវការលូកដើម្បីជួយវា ពេលដែលសុកមិនធ្លាក់ ពេលលាសដោះកើតឡើង បន្ទាប់ពីកើតកូន។ ត្រូវចាក់ប្រូស្តាក្លង់ឌីននៅ២៤ម៉ោងបន្ទាប់ពីកើតកូនហើយចាក់ម្តងទៀតនៅ២អាទិត្យក្រោយមក។

## ២៨. ការមិនរកឈ្មោល

### ១. មូលហេតុ

ការមិនរកឈ្មោលមានន័យថា មេគោដែលមិនដើមមិនត្រូវការគោបា វាគឺជាការធម្មតាក្នុងកំឡុងពេលដំបូងនៃដំណាក់កាលបំបៅដោះកូនគោ។

បញ្ហាទូទៅខ្លះអាចធ្វើឱ្យមានការមិនរកឈ្មោលរយៈពេលវែងដែលយើងអាចនិយាយថាសត្វអាះ

- លក្ខខណ្ឌដងខ្លួនមិនល្អ ដែលរារាំងសកម្មភាពវដ្តរកឈ្មោលរបស់មេគោ

- ការបៅដោះដោយកូនគោបន្លាយពេលយូរពេក
- មានគីសលើអូវែ។




**២. ការព្យាបាល**

- ផ្តល់ចំណីឲ្យបានគ្រប់គ្រាន់ និងផ្តាច់ដោះទាន់ពេលនឹងជួយសម្រួលការរកឈ្មោល ប្រសិនបើគោស្ថិតក្នុងសភាពល្អ ត្រូវព្យាបាលបាល Luteal cysts ដោយប្រើប្រូស្តាក្លង់ឌីន ៥មីលីលីត្រ នៃលុយតាលីស (Lutalyse) ដើម្បីជម្រុញការរកឈ្មោលក្នុងពេលពី៣ទៅ៥ថ្ងៃ។

## ២៩. ការរកឈ្មោលឡើងវិញ

មេគោបង្ហាញវដ្តរកឈ្មោលរៀងរាល់៣អាទិត្យប៉ុន្តែមិនអាចផើមបន្ទាប់ពីបង្កាត់។ ការរកឈ្មោលឡើងវិញត្រូវបានកំណត់ថាមេគោមិនមានគភ៌បន្ទាប់ពីដាក់បាន៣ដង ឬលើសពីនេះពេលដែលវារកឈ្មោលពិតប្រាកដ។




**១. មូលហេតុ**

- រលាកស្បូន វាគឺជាការចម្លងមិនជាក់លាក់របស់ស្បូនបង្កដោយបាក់តេរីរាតត្បាតលើស្បូនបន្ទាប់ពីកើតកូន។ តាមពិតកូនមិនអាចវិវត្តបានត្រឹមត្រូវក្នុងស្បូនដែលឆ្លងជំងឺ។ ការរលាកស្បូនពេលខ្លះមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យព្រោះគោបានបញ្ចេញខ្ទុះមកក្រៅ។
- គោបាអាចអា ដូចនេះត្រូវផ្លាស់ប្តូរបាផ្សេងពេលដាក់លើកក្រោយ។

**២.ការព្យាបាល**

- ចាក់ថ្នាំប្រស្តាក្លង់ឌីន(Prostaglandins) ២ដងក្នុងពេលពី១១ទៅ១៤ថ្ងៃ

- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាតេត្រាស៊ីគ្លីន ឬទីឡូស៊ីនរយៈពេល៥ថ្ងៃ។

## ៣០. ជំងឺលាសដោះ Mastitis

លាសដោះគឺជាការរលាកក្រពេញដោះ។ ការចម្លងជំងឺ និងលទ្ធផលរបស់វាធ្វើឱ្យថយចុះផលិតកម្មទឹកដោះយ៉ាងច្រើន។

### ១. មូលហេតុ

វាបង្កដោយបាក់តេរី។ មេរោគអាចចូលតាមរយៈមុខរបួស ឬតាមរយៈបំពង់របស់ក្បាលដោះ។




### ២. រោគសញ្ញា

- ករណីលាសដោះភាគច្រើនជាប់ពាក់ព័ន្ធផ្នែក១ភាគ៤ (លើក្បាលដោះ១) របស់កន្សោមដោះ ដែលមានផលិតកម្មទឹកដោះជាធម្មតាលើផ្នែក៣ភាគ៤ដទៃទៀត
- ក្នុងករណីស្រួចស្រាវភាគទាំងបួនហើម ក្តៅ និងឡើងក្រហមហើយមានផលិតកម្មទឹកដោះតិចតួច។ គ្រុនក្តៅ អស់កម្លាំង និងការញាប់ញ័រកើតជាទូទៅ។ មេគោអាចក្រញែងខ្លួនចេញឬធាក់ពេលដែលប៉ះកន្សោមដោះព្រោះផ្នែកទាំងបួននៃដោះមានភាពងាយទទួលការឈឺចាប់។
- ក្នុងករណីមិនសូវស្រួចស្រាវនិងទម្រង់រ៉ាំរ៉ៃ គ្មានគ្រុនក្តៅ ឬសញ្ញាទូទៅ ប៉ុន្តែផលិតកម្មទឹកដោះទាប ហើយផ្នែកទាំងបួនភាគអាចល្អ។ មេគោការពារពេលដែលកូនគោព្យាយាមបៅ កូនគោឃ្លាន និងមានស្ថានភាពមិនល្អ។


ត្រួតពិនិត្យទៀងទាត់កន្សោមដោះគឺជាការអនុវត្តដ៏ល្អ។ ជំងឺដែលមានសណ្ឋានមិនសូវស្រួចស្រាវមួយភាគបួនគឺកាចសាហាវនិងមានទឹកដោះតិចតួចហូរចេញ



កូនគោបាត់បង់សភាពរាងកាយល្អដោយគ្មានសញ្ញាដទៃបង្ហាញ វាអាចជាសញ្ញាគ្មានទឹកដោះគ្រប់គ្រាន់

## ៣. ការព្យាបាល

ការព្យាបាលត្រូវអនុវត្តតាំងពីដំបូងដើម្បីទទួលជោគជ័យ ត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន(Ocytocin) ៥មីលីលីត្រ ដើម្បីធ្វើឲ្យកន្សោមដោះហូរ។ ទឹកដោះផ្នែកមួយភាគបួនដែលឈឺត្រូវច្របាច់ចេញដោយដៃ(វាមានសារៈសំខាន់ក្នុងការដាក់គោក្នុងសាឡុងព្រោះវាមានការឈឺចាប់) ពីរដងក្នុងមួយថ្ងៃ។ ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីម ជាមួយស៊ុលហ្វា ឬអាម៉ុកស៊ីលីនរយៈពេលបីថ្ងៃ។ ប្រសិនបើកន្សោមដោះរឹងត្រូវចាក់ថ្នាំដិចសាមេតាសូន ឬគុលហ្វេឌីនដើម្បីកាត់បន្ថយការរលាក។

